ប្រលោមលោកផ្នែកសញ្ចេតនា

# ផ្លូវខ្លឹមច័ន្ទក្រឹស្នា

និពន្ធដោយ ប៉ែន សេដ្ឋារិន
សាស្ត្រាចារ្យសាកលវិទ្យាល័យ អូប៊ីរិន តូក្យូ

បោះពុម្ពនៅខែកុម្ភៈឆ្នាំ២០០៣

# កំណត់អ្នកនិពន្ធ

យើងសព្វថ្ងៃនៅក្នុងសម័យកាល ដែលមនុស្សជាតិស្ថិតនៅក្នុងកាលៈទេសៈមួយ ដែលវិទ្យាសាស្ត្របានបរិច្ចាគនៅក្នុងថ្នាលនានាដ៏ច្រើន ឱ្យមនុស្សបានស្រណុកស្រួលមិនចាំបាច់នឹងប្រើកម្លាំងបាយលត់ដំសស្រាក់ស្រស្រាំជ្រុល ដូចនៅជំនាន់បូរាណ ឬមួយក៏នាំឱ្យអាយុកាលមធ្យមនៃមនុស្សជាតិបានលូតវែងក៏ពិតមែនហើយ ក៏ប៉ុន្តែ ការឱ្យតម្លៃជ្រុលពេកទៅលើការលូតលាស់នៃវិទ្យាសាស្ត្រ និងសេដ្ឋកិច្ច នាំឱ្យមនុស្សភាគច្រើនដែលនៅលើពិភពលោកយើងនេះ មានការភ័ន្តច្រឡំគិតថា ប្រទេសឬមនុស្សដែលមិនទាន់លូតលាស់ខាងវិទ្យាសាស្ត្រ ឬខាងថ្នាលអាយធី (បច្ចេកវិទ្យាពត៌មាន) គឺជាប្រទេសអន់ថយ មិនរីកចំរើនហើយប្រទេស ឬអ្នកទាំងនោះក៏ទៅជាគោលដៅនៃការមាក់ងាយពីប្រទេសឬមនុស្សដែលពូកែ ដែលលូតលាស់ខាងផ្នែកវិទ្យាសាស្ត្រ។ ខណៈនេះ យើងបានភ្លេចនូវវត្តមានរបស់សិល្បករ អ្នកកវីនិពន្ធ ទស្សនវិទូ ឬអ្នកច្បាប់ និងបុព្វជិតទាំងឡាយដែលបរិច្ចាគគ្រប់យ៉ាង ដើម្បីបំពេរអារម្មណ៍ហ្ហរហ្មងរបស់មនុស្សជាតិទាំងឡាយ ឬដើម្បីរំងាប់នូវហឹង្សានានា ឬមួយ ធ្វើឱ្យមានសណ្តាប់ធ្នាប់នៅក្នុងសង្គម ដែលជាកត្តានាំឱ្យមនុស្សជាតិអាចរស់នៅក្នុងសេចក្តីស្ងប់ស្ងាត់ សន្តិសុខសន្តិភាព ជួបជុំគ្រួសារ មិត្តភក្តិ ដែលយើងភាគច្រើនបានយល់ច្រឡំថាជាការធម្មតា។ ម្យ៉ាងទៀតដោយសារតែការយល់ច្រឡំថា សន្តិសុខ,សន្តិភាពជាវត្ថុដែលបានមកដោយមិនបាច់ខិតខំប្រឹងប្រែង ទើបមនុស្សសព្វថ្ងៃនេះ លែងសូវឱ្យតម្លៃទៅលើមិត្តភាពស្មោះត្រង់ សេចក្តីស្នេហា សេចក្តីមេត្តា សមភាព និងសេចក្តីសន្តោស ដែលជាទស្សនដ៏ខ្ពង់ខ្ពស់នៃព្រះពុទ្ធព្រះសាមណគោត្តមបន្ទាប់មកនៃព្រះបាទជ័យវរ្ម័នទី៧ ព្រះចៅក្រុងកម្ពុជានៃយើង ដែលយើងរាល់គ្នាជាខ្មែរ ត្រូវតែមានមោទនភាព ហើយយល់ថា ទស្សនវិជ្ជានេះគឺជាកេរ្តិ៍មរតកដ៏ថ្លៃថ្លា ដែលយើងគួរតែរក្សាទុកជាទ្រព្យសំរាប់ខ្លួនយើង។ ពិភពលោកកាន់តែមានភាពស្មុកស្មាញឡើងផង ទំនាស់និងជំលោះ ព្រមទាំងឱនភាពនៃសេដ្ឋកិច្ច ចេះតែកើនឡើងៗ នៅសឹងតែគ្រប់ទិសតំបន់ក្នុងលោកយើងនេះ តើអ្វីទៅ ដែលគួរឱ្យយើងអាចយកមកធ្វើជាជន្ទល់ ជាក្លឹមសារជាទឹកដមសំរាប់ឱ្យជីវិតមានន័យបាននោះ។

ចំពោះខ្ញុំ ដែលចូលចិត្តធ្វើដំណើរទៅមើលប្រទេសនានា ហើយចូលចិត្តការចុះទៅស្រាវជ្រាវដល់ទីកន្លែង ខ្ញុំតែងដឹងថា គ្រោះថ្នាក់អាចកើតមានឡើងនៅគ្រប់វិនាទីចំពោះរូបខ្ញុំ។ ខ្ញុំចូលចិត្តការស្រាវជ្រាវរាវរកការពិត តែមិនមែនជាអ្នកផ្សងព្រេង យកជីវិតដ៏មានតម្លៃទៅធ្វើជាល្បែងសំរាប់កំសាន្តឡើយ។ នៅក្នុងការពិត ដែលខុសពីឧត្តមគតិនៅវេលាខ្លះ ខ្ញុំបានធ្វើរបកគំហើញមួយគឺថាអាវុធដ៏មានតម្លៃសំរាប់ការពារខ្លួនយើងគឺ មេត្តា ករុណា ឧបេក្ខា និង មុទិតា ដែលនិយាយឱ្យស្រួលស្តាប់ទៅ គឺសេចក្តីស្នេហា សេចក្តីមេត្តា សមភាព និងសេចក្តីសណ្តោស ដែលយើងមានមុខព្រហ្មបាយន្តទាំងបួន ដែលបុព្វបុរសខ្មែរបានចារទុកយ៉ាងធំៗ កុំឱ្យយើងភ្លេចបានជាកសិណស្រាប់។

រឿងផ្នូរខ្លឹមច័ន្ទក្រឹស្នានេះ ជារឿងដែលខ្ញុំបានចងក្រងឡើងយូរយារដែរណាស់មកហើយ តែនៅរង់ចាំការតែងបញ្ចប់នូវរឿងប្រលោមលោកធុនខ្លីមួយទៀត សឹមបោះពុម្ពរួមជាសៀវភៅមួយ។ ពោលគឺគំរោងនៃរឿងបានចាប់ផ្តើមគូសវាសនៅក្នុងខួរក្បាលរបស់ខ្ញុំ តាំងពីពេលដែលខ្ញុំនៅជាម្ចាស់ភោជនីយដ្ឋាន ”អង្គរធំ”នាទីក្រុងម៉ាជីដា ប្រទេសជប៉ុន ដែលខ្ញុំបានជួយថែទាំមើលបងប្អូន

អ្នកភៀសខ្លួនខ្មែរផង ជនជាតិវៀតណាម ថៃ ឬជនជាតិផ្សេងៗដទៃទៀត ដែលមករស់នៅប្រទេសជប៉ុន ដាច់សង្វែងពីញាតិសន្តាន បងប្អូន ប្រហែលជា១៩ឆ្នាំមុន ហើយយើងមានទំនាក់ទំនងជាមួយគ្នាល្អណាស់។ អ្នកទាំងឡាយហៅខ្ញុំថា បងស្រី ហើយនៅពេលដែលខ្ញុំមានការទៅស្រាវជ្រាវសិក្សាអ្វីមួយនៅប្រទេសរបស់គេៗតែងតែជួយជ្រោមជ្រែងខ្ញុំ ដោយរូបគេផ្ទាល់ ឬក៏ដោយពឹងពាក់បងប្អូនសាច់ញាតិគេ ឱ្យជួយមើលថែទាំខ្ញុំដោយស្មោះសណាស់។ ក៏ប៉ុន្តែនៅក្នុងចំណោមជនជាតិជិតខាងយើងទាំងឡាយនោះ ក៏មានជនខ្លះដែលមិន ដឹងហើយតែងតែចោលពាក្យមិនគប្បីថា ខ្មែរយកប្រាសាទព្រះវិហារថៃ ឬក៏និយាយថា ខ្មែរភាគតិចដែលរស់នៅដែនដីសណ្តរ ឡើងចាងនៅក្នុងប្រទេសវៀតណាម មិនខ្លាចចិត្តម្ចាស់ប្រទេសជាដើម។ គួរឱ្យភ្ញាក់ទៅទៀតគឺនៅពេលដែល ជប៉ុនទៅធ្វើទស្សនកិច្ចកំសាន្តនៅប្រទេសថៃ អ្នកនាំគេដើរធ្វើទស្សនកិច្ច(ហ្គៃដ៍) តែងតែពន្យល់ថាអង្គរវត្តជារបស់ថៃ ហើយខ្មែរលួចពីថៃ។ ខ្ញុំសូមចិត្តបងប្អូនរួមជាតិរបស់ខ្ញុំ កុំឱ្យមានកំហឹង ក្នុងឋានៈយើងជាមនុស្សមានអារិយធម៌ ជាមនុស្សមានធម៌មេត្តា សេចក្តីករុណា និងសេចក្តីសណ្តោសហើយពិចារណាជាមួយគ្នានៅពេលដែលអានរឿងនេះ ចប់ចុងចប់ដើមហើយ។

ជាមួយនឹងការងារស្រាវជ្រាវរបស់ខ្ញុំៗបានចាប់អារម្មណ៍ថា ដោយសារតែអក្សរវៀតណាមបានកែប្រែពីអក្សរបែបចិន មកជាអក្សរបែបរ៉ូម៉ាំងសព្វថ្ងៃ ដោយសារអ្នកដឹកនាំគេនៅដើមសតវត្សទី២០ យល់ថាការប្រើអក្សរថ្មីនេះនាំឱ្យប្រទេសគេឆាប់ទំនើប (នេះជា មោទនភាពមួយធំណាស់ ដោយប្រទេសយើងខិតខំការពារអក្សរខ្មែរទុក)ជនជាតិវៀតណាមក្មេងៗជំនាន់ក្រោយ ពុំមានលទ្ធភាពនឹងអានកំណត់ហេតុនានា ដែលបុព្វបុរសរបស់គេចារទុកមកបាន ឡើយហើយជាលទ្ធផល មានជនជាតិ វៀតណាមច្រើនណាស់ ដែលមិនស្គាល់ប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន ព្រមទាំងពូជពង្សដើមកំណើតរបស់ខ្លួន។

ខ្ញុំធ្លាប់មិនសប្បាយចិត្ត នឹងសម្តីដែលប្រកបទៅដោយកង្វះការចេះដឹងប្រវត្តិសាស្ត្រពិតនេះ ហើយខ្ញុំតែងតែប្រាថ្នាចង់ឱ្យប្រវត្តិវិទូរយើងសិក្សាស្រាវជ្រាវពីការបង្រៀន ការអប់រំប្រវត្តិវិទ្យា ភូមិវិទ្យានៅតាមសាលានៃប្រទេសជិតខាងយើងទាំងឡាយ ហើយបើឃើញថា មិនសមហេតុសមផលទេ យើងគួរតែតវ៉ា តាមលំដាប់ការទូតដូចជាប្រទេសកូរ៉េ ឬចិនដែលទាមទារឱ្យជប៉ុនកែតម្រូវសៀវភៅសិក្សាប្រវត្តិសាស្ត្រនៃសិស្សានុសិស្សជប៉ុន ឬក៏បង្កើតឱ្យមានជាការជជែកពិភាក្សាគ្នារវាងប្រវត្តិវិទូរនៃជនជាតិសាមីខ្លួនយើងទាំងអស់។

ប្រសិនបើពុំមានការនិយាយឱ្យច្បាស់លាស់ដោយបែបវិទ្យាសាស្ត្រ ទៅលើរឿងប្រវត្តិសាស្ត្រ និងដែនដីរវាងខ្មែរនិងជនជាតិដែលនៅក្បែរៗយើងនេះទេ ទំនាក់ទំនងល្អពិតប្រាកដ ច្បាស់ជាមិនអាចដុះដាលបានរវាងជនជាតិយើងទាំងឡាយបានឡើយ។

ប្រជាជាតិ ប្រទេសជាតិចាប់ផ្តើមឡើងពីមនុស្សម្នាក់ៗ។ ខ្ញុំមិនអាចបំភ្លេចបាននូវអនុស្សាវរីយ៍ដ៏មានតម្លៃជាច្រើនរាប់មិនអស់ ដែលមិត្តបរទេសនៃប្រទេសជិតខាងយើងរបស់ខ្ញុំទាំងឡាយនេះធ្វើមកលើរូបខ្ញុំទេ។

នេះជាឧទាហរណ៍មួយតែប៉ុណ្ណោះ។ ចំពោះមិត្តអ្នកអានដទៃទៀត មិត្តច្បាស់ជាមានអនុស្សាវរីយ៍ផ្សេងទៀតមិនខានឡើយ។ ប្រសិនបើពិភពលោកយើងនេះ ឱ្យតម្លៃទៅលើមិត្តភាព សេចក្តីមេត្តា សិល្បៈវប្បធម៌ ឱ្យស្មើនឹងវិទ្យាសាស្ត្រ ហើយមិនតិះដៀលចំអកឱ្យគ្នាទៅវិញទៅមក ផ្ទុយទៅវិញជួយឈឺឆ្អាលគ្នាទៅវិញទៅមក ទៅជាកម្លាំងរបស់គ្នាទៅវិញទៅមក ដូចតួអង្គនៃ

រឿង "ផ្ទះខ្មឹមច័ន្ទក្រឹស្នា" នេះ ពិភពលោកនឹងពោរពេញទៅដោយសេចក្តីសុខក្សេមក្សាន្តជាប្រាកដ។

ខ្ញុំស្តាយណាស់ ដោយនៅពេលដែលខ្ញុំប្រុងប្រៀបនឹងបោះពុម្ពសៀវភៅនេះ ស្រាប់តែមានព្រឹត្តហេតុដ៏អាស្រូវមួយ បានកើតឡើងនៅ២៩ល្ងាចនៃខែមករា ឆ្នាំ២០០៣នេះ ដោយជនមួយចំនួនតូចដែលប្រើអំពើហិង្សា តបនឹងពាក្យសម្តីមិនសមរម្យមកលើកម្ពុជាពីសំណាក់មិត្តថៃម្នាក់ ហើយដែលមិនច្បាស់លាស់ផង។ ខ្ញុំបានគិតថា គួរតែពន្យាពេល ឬក៏គិតថានឹងមិនបោះពុម្ពសៀវភៅនេះជាស្ថាពរ ដើម្បីចៀសវាងការយល់ច្រឡំ។ ក៏ប៉ុន្តែមានកូនចិត្តមួយទៀតគិតថា ការដែលខ្ញុំធ្លាប់បារម្ភ បានកើតឡើងជាក់ស្តែង ហើយប្រសិនបើយើងទាំងអស់មិនបញ្ចេញគំនិតដើម្បីកែលំអទេ មិនអាចរកដំណោះស្រាយទេ ហើយថ្ងៃណាមួយ រឿងដដែលនឹងកើតមានឡើងទៀត។ ដូច្នេះ នេះជាឱកាសមួយល្អ ដើម្បីឱ្យយើងទាំងអស់គ្នាពិចារណារកដំណោះស្រាយពិតៗ ដើម្បីបង្ការកុំឱ្យរឿងនោះកើតមានឡើងទៀត។ ហេតុនេះហើយ ខ្ញុំគួរតែប្រមូលឱ្យអស់នូវសេចក្តីក្លាហានទាំងឡាយហ៊ានបោះពុម្ពសៀវភៅនេះ ដែលជាកសិណនៃទឹកចិត្តដែលតែងតែជាប់ជំពាក់នៅនឹងមាតុប្រទេសជានិច្ចជាកាល។ នេះក៏ជាការរកដំណោះស្រាយដោយសន្តិវិធី និងដោយអហិង្សា ហើយមិនបន្សល់ទុកនូវការសៅហ្មងទៅវិញទៅមកទៅអនាគតផងដែរ។

ខ្ញុំសូមអរគុណចំពោះមិត្តជាច្រើន ដែលបានចំណាយពេលវេលាដ៏មានតម្លៃជួយពិនិត្យនិងផ្តល់យោបល់ដល់ខ្ញុំ ព្រមទាំងលើកទឹកចិត្តខ្ញុំចំពោះការបោះពុម្ពសៀវភៅនេះ។

សូមបន់ស្រន់ឱ្យមាតុប្រទេសយើង ក្លាយទៅជាមជ្ឈមណ្ឌលនៃពុទ្ធិនៃអហឹង្សា ជាជង្រុកនៃភោគផលកសិកម្ម ឱ្យដូចនៅសម័យអង្គរ ដែលជនជាតិមានអារិយធម៌ខ្ពង់ខ្ពស់នានានៅសម័យដើម បានមកសុំរៀនជាបន្តបន្ទាប់។

ប៉ែន សេដ្ឋារិន

សាស្ត្រាចារ្យសាកលវិទ្យាល័យ អូប៊ីរិន តូក្យូ

# ជំពូកទី១

## "ស្នេហាតែងតែទទួលស្នេហាមកវិញ"

ទៅនៅវេលាដែលផ្កាក្ងោករីកក្រហមឆ្អិនឆ្អៅ នៅតាមដងវិថីដែលចងផ្ទាប់អាកាសយានដ្ឋានទៅនឹងបេះដូងនៃព្រះរាជធានីភ្នំពេញ ខ្ញុំពុំអាចមិននឹកឃើញដល់វេលាដែលខ្ញុំ និងមនុស្សជាទីគោរពស្រឡាញ់របស់ខ្ញុំបានចងក្រងអនុស្សាវរីយ៍រួមគ្នាឡើយ។

គឺជាអតីតកាល ដែលកន្លងផុតជាងដប់ឆ្នាំទៅហើយ, ហើយខ្ញុំ បានភ្លេចនូវភាពល្អិតល្អន់ដែលមាននៅវេលានោះអស់ខ្លះទៅហើយ ប៉ុន្តែវាជាអនុស្សាវរីយ៍មួយដែលខ្ញុំពុំអាចបំភ្លេចបានទាំងស្រុងទាល់តែសោះនៅក្នុងជីវិតរបស់ខ្ញុំនេះ។

វេលាដែលខ្ញុំគិតពីរឿងនោះ អារម្មណ៍របស់ខ្ញុំតែងតែវិលត្រឡប់ទៅពេលនោះវិញ ហើយចិត្តរបស់ខ្ញុំទៅជាភ័ន្តច្រឡំថា អ្វីៗទើបតែនឹងកន្លងទៅថ្មីៗ ហើយខ្ញុំតែងតែបង្ហូរទឹកភ្នែកជានិច្ច។

អនុស្សាវរីយរបស់យើង មានទុក្ខសោកក៏មាន សេចក្ដីសប្បាយ ព្រមទាំងមង្គលដ៏ធំធេងក៏មាន។

ខ្ញុំពុំដែលមានចេតនានឹងបំភ្លេច រឿងរ៉ាវទាំងនោះទេ ផ្ទុយទៅវិញខ្ញុំតែងតែចង់រំលឹកហើយរំលឹកទៀតមិនឡើយណាយ នូវវេលាដ៏ប្រកបទៅដោយ មង្គលព្រមទាំងទុក្ខសោកនោះ ដែលឥឡូវប្រៀបបាននឹងសុបិននិមិត្តមួយ របស់ខ្ញុំ។

ដូច្នេះហើយ បានជាខ្ញុំមានគំនិតថាគួរតែខិតខំសរសេរកំណត់នេះទុក។

យើងបានស្គាល់គ្នានៅក្នុងកប៉ាល់ហោះ។ កាលនោះខ្ញុំធ្វើអូតេសដឺឡែរ (អ្នកបំរើយន្តហោះ) ធ្វើការនៅអាកាសចរកម្ពុជាបានពីរឆ្នាំហើយៗមានអាយុ២២ឆ្នាំ។

លោកវិមលជាភ្ញៀវដែលជិះកប៉ាល់ហោះយើង នៅថ្នាក់ទីមួយជាលើកដំបូងដោយសារពេលនោះ អាកាសចរថៃបានត្រូវហាមឃាត់មិនអោយហោះហើរមកព្រះរាជាណាចក្រកម្ពុជាមួយរយៈ។

លោកវិមលមានរូបរាងសង្ហារ ថ្លៃថ្នូរ សមតែជាអភិជន ឬវរជនម្នាក់ដែលហាក់ដូចជាតារាមួយដួងដែលរះនៅឯវេហាដ៏ខ្ពស់។ ខ្ញុំបានដឹងថាមិត្តភក្ដិខ្ញុំជាច្រើនបានច្រួលច្រាលនឹងរូបលោក ហើយមិត្តខ្លះបានខំដើរទៅក្រវែលៗជិតលោកទាំងពុំមានការងារអ្វី។ លុះដល់វេលាដែលយើងត្រូវជូនកាហ្វេ ឬតែ ដល់ភ្ញៀវ ខ្ញុំបានរុញរទេះមកដល់កៅអីលោក ហើយលោកក៏បានហៅខ្ញុំ។ លោកបានប្រាប់ខ្ញុំថា លោកមិនស្រួលខ្លួនទាល់តែសោះ ហើយមានអាការៈដូចជារកកលនឹងញាក់។ លោកបានសុំថ្នាំអាស្ពីរីននិងទឹកមួយកែវ។ ខ្ញុំបានជំរាបសួរលោកថា តើខ្ញុំគួរប្រកាសរកវេជ្ជបណ្ឌិតមកជូនឬយ៉ាងណា? ប៉ុន្តែលោកឆ្លើយថាមិនអីទេ។ ខ្ញុំបានយកមកជូនលោក ហើយបានយកភួយពីរមកគ្របជូនលោកឱ្យលោកសម្ងំ។ យូរៗម្ដង ខ្ញុំដើរទៅជិតលោកដោយក្ដីបារម្ភពីសុខភាពរបស់លោក។ ខ្ញុំឃើញលោកសម្ងំស្ងៀមបិទភ្នែក ប៉ុន្តែប្រកបទៅដោយភាពថ្លៃថ្នូរណាស់។ ទឹកមុខលោកស្ងប់ស្ងាត់ ហាក់ដូចជាបានសេចក្ដីសុខសាន្តក្នុងចិត្តជាខ្លាំង។

បន្ទាប់ពីនោះមក នៅពេលដែលយន្តហោះប្រុងប្រៀបនឹងចុះចតហើយ គឺជាពេលដែលខ្ញុំតោងតែដើរជំរាបអ្នកដំណើរអោយដាក់ខ្សែក្រវាត់ ឬដាក់កៅអី

ឱ្យមកនៅកន្លែងដើមវិញជាដើម ខ្ញុំបានទៅជិតលោក ជំរាបសួរលោកពីជម្ងឺរបស់លោក ព្រមទាំងសួរលោកថា តើលោកត្រូវការឱ្យយើងជូនលោកទៅដល់ក្រោមឬទេ? លោកបានញញឹមហើយមានប្រសាសន៏ថា លោកបានធូរច្រើនហើយៗលោកអាចធ្វើដំណើរចុះទៅម្នាក់លោកបាន។

លោកបានអរគុណខ្ញុំ ដោយខ្ញុំបានជួយយកអាសារលោក ហើយបានហុចនាមប័ណ្ណរបស់លោកមួយសន្លឹកមកឱ្យខ្ញុំ ព្រមទាំងផ្តាំឱ្យខ្ញុំទូរស័ព្ទទៅលោកផងប្រសិនបើខ្ញុំមានឱកាសបានទៅលេងក្រុងបាងកក។ ខ្ញុំបានទទួលនាមប័ណ្ណហើយរក្សាទុកនៅក្នុងកាបូបរបស់ខ្ញុំ ប៉ុន្តែពុំដែលមានសេចក្តីក្លាហាននឹងទូរស័ព្ទទៅសាកសួរសុខទុក្ខលោកសោះ ពីព្រោះខ្ញុំគិតថា ពាក្យសម្តីដែលលោកបានពោល គឺជាការគួរសមធម្មតារបស់ភ្ញៀវ ពុំមែនជាសញ្ញេតនាមិត្តភាព ឬសញ្ញេតនា អ្វីផ្សេង ដែលខ្ញុំគួរតែធ្វើទំនាក់ទំនងជាមួយនឹងលោកទាល់តែសោះ។

វេលាមួយ នៅពេលដែលការហោះហើររបស់យើងទៅឈប់នៅបាងកក យើងទាំងអស់បានចូលទៅអង្គុយសំរាកនៅក្នុងភោសជ្ជៈដ្ឋានមួយ។ មិត្តម្នាក់ឈ្មោះ ជីវី បានស្រែកឆោឡោថា :

- មើលហ្ន៎! លោកម្នាក់នេះហើយដែលជិះកប៉ាល់ហោះយើងលើកមុននោះ!

ពួកយើងនាំគ្នាសម្លឹងទៅទូរទស្សន៏។ នេះហើយ ពិតជាហ្នឹងហើយលោកវិមល។ ខ្ញុំឃើញលោក ហាក់ដូចជាមានសាច់បន្តិច។ លោកមានទឹកមុខស្រស់ហាក់ដូចជាមានមង្គលណាស់។ ប៉ុន្តែដោយភាសាដែលលោកមានប្រសាសន៏ ជាភាសាថៃ ខ្ញុំពុំអាចយល់ឱ្យបានអស់នូវអ្វីៗដែលលោកមានប្រសាសន៏ទេ។

រូបភាពដែលឡើងព្រាលៗស្ទើរតែរលុបបាត់ទៅហើយ បានចូលមកសន្និតជាថ្មីម្តងទៀតនៅក្នុងសតិអារម្មណ៏របស់ខ្ញុំ ឱ្យខ្ញុំរំលឹកឃើញលោកឡើងវិញ។

ខ្ញុំបានសរសេរប័ណ្ណប្រៃសនីយមួយជាភាសាអង់គ្លេសថា ខ្ញុំបានឃើញលោកនៅក្នុងទូរទស្សន៏ ថាខ្ញុំត្រេកអរជាខ្លាំង ដោយបានឃើញលោកមានសេចក្តីសុខសប្បាយ ព្រមទាំងបានសាកសួរលោកថា តើលោកមានសុខភាពល្អធម្មតាឡើងវិញ ដូចដែលខ្ញុំបានឃើញលោកនៅក្នុងទូរទស្សន៏ហើយឬនៅ។

ខ្ញុំបានសរសេររួចហើយ ប៉ុន្តែមិនដាច់ចិត្តផ្ញើរសំបុត្រនោះសោះ។

សំបុត្រនោះនៅសម្ងំក្នុងកាបូបរបស់ខ្ញុំយ៉ាងយូរ រហូតដល់ពេលមួយដែលអាចចាត់បានថា ជាពេលវេលានៃការផ្លាស់ប្តូរព្រេងវាសនារបស់ខ្ញុំ។ រដ្ឋមណីជាមិត្តម្នាក់បានស្រែក សួរយើងទាំងអស់គ្នាថា មានអ្នកណាចង់ផ្ញើសំបុត្រទេ ពីព្រោះគេទៅបុស្តិ៍។ បើនរណាមានសំបុត្រឱ្យយកមក។ គ្មានអ្នកណាម្នាក់ថាមានទេនៅវេលានោះ។ មិនដឹងជានឹកឃើញយ៉ាងម៉េច ខ្ញុំបានហុតសំបុត្រនោះឱ្យរដ្ឋមណីយកទៅផ្ញើឱ្យ។

ប្រហែលជា១០ថ្ងៃក្រោយពីនោះ ខ្ញុំក៏បានទទួលសំបុត្រអេចស៊ីប្រៃសមួយពីប្រទេសថៃ នៅពេលដែលខ្ញុំកំពុងសំរាករង់ចាំការហោះហើរទៅបាងកក។

ខ្ញុំអរចម្លែក ដោយឃើញសំបុត្រដែលខ្ញុំពុំមានទម្លាប់នឹងទទួលដូចមិត្តឯទៀតៗ ដែលមានញាតិមិត្តបងប្អូននៅបរទេស។ ខ្ញុំបានសំបុត្រហើយ ក៏ប្រញាប់រកមើលឈ្មោះអ្នកផ្ញើ ប៉ុន្តែពុំឃើញសោះ។

ខ្ញុំបានចេញទៅក្រៅ ហាក់ដូចជាពុំចង់ឱ្យនរណាម្នាក់ចាប់អារម្មណ៏ ឬក៏សួរនាំ។

សំបុត្រសរសេរនៅលើក្រដាសពណ៌ខៀវផ្ទៃមេឃជិត ដូចជាចង់បង្ហាញនូវទឹកចិត្តដ៏ស្មោះស។ បេះដូងខ្ញុំលោតញាប់។ សំបុត្រសរសេរជាភាសាអង់គ្លេសនាំឱ្យខ្ញុំដឹងដោយញាណារម្មណ៏ថា គឺជាចម្លើយពីលោកវិមលដែលខ្ញុំពុំសូវជាមាន

សង្ឃឹមថានឹងបានទទួលមកវិញឡើយ។ លោកបានថ្លែងអំណរគុណខ្ញុំ ព្រមទាំងថា លោកត្រេកអរបួសពីការស្មានទៅពេលដែលលោកបានទទួលសំបុត្ររបស់ខ្ញុំ ហើយបានធ្វើសំណូមពរអោយខ្ញុំទូរស័ព្ទទៅលោក នៅវេលាដែលខ្ញុំទៅដល់ទីក្រុងបាងកក។ លោករង់ចាំខ្ញុំជានិច្ច ដោយអំណត់ជាទីបំផុត។

ខ្ញុំប្រញិបប្រញាប់បត់សំបុត្រដាក់ទៅក្នុងកាបូបទាំងសោកស្តាយ នៅពេលដែលសែហ្វប៉ាសា (មេក្រុម) ដើរតម្រង់ចូលមកបន្ទប់រង់ចាំការហោះហើរ ដើម្បីនាំពួកយើងធ្វើដំណើរទៅរកយន្តហោះ។

ពេលខ្ញុំចូលទៅក្នុងបន្ទប់វិញ មិត្តទាំងឡាយខ្លះនៅកំពុងឆ្លុះកញ្ចក់ ខ្លះនៅថែមម្សៅ ខ្លះទៀតមើលកញ្ចក់ហើយញញឹមទទេ ខ្លះនៅចងសក់នៅឡើយ។

ពេលឃើញសែហ្វប៉ាសាចូលមក ម្នាក់ៗខំប្រមែប្រមូលប្រដាប់ប្រដាដាក់បញ្ចូលទៅក្នុងកូនកាបូបរបស់ខ្លួន ហើយចាប់កូនវ៉ាលីសអូសដើរចេញស្រ សំដៅទៅរកកប៉ាល់ហោះដែលចតចាំនៅលើពីស្ទ (ផ្លូវសំរាប់យន្តហោះបើកបរនៅអាកាសយានដ្ឋាន)។ យើងរៀបចំរបស់របរផ្ទាល់ខ្លួនដាក់ទៅលើប្រអប់ថ្នាក់ ដែលនៅពីលើកៅអីអ្នកដំណើរ ដែលនៅជិតកន្ទុយកប៉ាល់ហោះ រួចហើយរៀបចំធ្វើការងាររបស់ខ្លួនរៀងៗខ្លួន។

មនីរដ្ឋ សាកល្បងទូរស័ព្ទដែលមានតួនាទីជាក្បាលមេក្រូ ជីវីពិនិត្យមើលប្រដាប់ការពារគ្រោះថ្នាក់ មិត្តដទៃទៀតមើលកៅអី ជួយ ទស្សនាវដ្តី កាសែតសំរាប់ជូនភ្ញៀវអាន និងរៀបចំអ្វីនានាឱ្យមានរបៀបរៀបរយ និងផាសុកភាពរង់ចាំអ្នកដំណើរមកដល់។

អារម្មណ៏របស់ខ្ញុំនៅតែនឹងសំបុត្ររបស់លោកវិមល។ ខ្ញុំមានចិត្តចង់តែលួចអានសំបុត្រនោះ ចង់ឃើញអក្សរអ្នកប្រុសដ៏ជាទីគោរពសារជាថ្មីទៀត ខ្ញុំច្រួលច្រាលនៅមិនសុខ ជួនកាលធ្វើឱ្យធ្លាក់នេះ ជួនកាលធ្វើឱ្យធ្លាក់នោះ ជួនទៀតទៅធ្វើឱ្យប៉ះនោះ ធ្វើឱ្យប៉ះនេះ ទាល់តែមិត្តទាំងឡាយនាំគ្នាយកដៃមកស្ទាបថ្ងាសក្រែងខ្ញុំក្តៅខ្លួន។ ជីវី បានឱ្យខ្ញុំអង្គុយស្ងៀម សំរាកបន្តិច មិត្តខ្លះថា ខ្ញុំស្លាំងណាស់។ តែខ្ញុំបានប្រកែកថាមិនអីទេ។

យើងបានទៅដល់ទីក្រុងបាងកកនៅម៉ោង២:៥៥ ហើយខ្ញុំអាចមានពេលសំរាកនៅទីនេះពីរយប់ក្រោយពីការហោះហើរឥតសំរាកបីអាទិត្យជាប់គ្នា។

មិត្តខ្ញុំដែលអាចយកថ្ងៃឈប់សំរាកបានដែរ បានមូលមតិគ្នាថា នឹងនាំគ្នាជិះឡានធំទៅឈាងម៉ាយ។

ឯរូបខ្ញុំ ដោយមានលេសថា មិនស្រួលខ្លួន ក៏សុំទោសគេទាំងអស់គ្នាថា សុំឱ្យខ្ញុំសំរាកនៅសណ្ឋាគារឱ្យមានកម្លាំងបន្តិច។ មិត្តទាំងអស់នាំគ្នាអាណិតខ្ញុំដែលពុំអាចទៅលេងសប្បាយជាមួយគេបាន។

គេទាំងអស់គ្នាបានអង្អែលក្បាលខ្ញុំ ហើយលួងលោមដោយពាក្យផ្សេងៗ។ នៅវេលាដែលមិត្តទាំងឡាយធ្វើដំណើរចាកចេញផុតទៅ ខ្ញុំបានរាវរកនាមប័ណ្ណរបស់លោកវិមល ដែលខ្ញុំបានរក្សាទុកយ៉ាងផ្ចិតផ្ចង់ ហើយទូរស័ព្ទទៅលោកទាំងបេះដូងញាប់ញ័រ ខុសសង្វាក់ធម្មតា។

ជាថៃដន្យ លោកពុំនៅទីកន្លែង ខ្ញុំក៏បានដាក់សារតាមរយៈនារីដែលខ្ញុំស្មានទៅថាជាលេខារបស់លោក។ ខ្ញុំបានជំរាបថា ខ្ញុំស្នាក់នៅសណ្ឋាគារ អាម៉ារីនអែរពត រហូតដល់ថ្ងៃស្អែក នៅបន្ទប់លេខ៦០៣១។

យប់នោះ គេបានហៅទូរស័ព្ទពីកុងទ័រទទួលភ្ញៀវនៅខាងក្រោមមកថា មានភ្ញៀវមករកខ្ញុំ។ ខ្ញុំបានទទួលទូរស័ព្ទហើយបានដឹងថា ភ្ញៀវរបស់ខ្ញុំគឺលោកវិមល

អ្នកប្រុសដែលខ្ញុំចង់ជួបផង ខ្លាចនឹងជួបផង អរផងភ័យផង មិនដឹងជាត្រូវសំរេចយ៉ាងណា។

លោកបានមកដល់ទីកន្លែងរបស់ខ្ញុំ ហើយបើខ្ញុំមិនកាត់ចិត្តខ្មាសអៀនជួបនឹងលោកនៅពេលនេះទេ ខ្ញុំប្រាកដជានឹងបាត់បង់ឱកាសដ៏ល្អ ដ៏កំរនេះជាស្ថាពរ។

គិតបែបនេះហើយ ខ្ញុំក៏ប្រមូលនូវសេចក្តីក្លាហានទាំងឡាយរបស់ខ្ញុំរៀបរយសក់ ប្តូរសំពត់អាវឆ្នូតកញ្ចក់បែរមើលខ្លួនពីស្តាំ ពីឆ្វេង ញញឹមផ្សៀងផ្សងប្រហែលជា១០នាទី ទំរាំនឹងដាច់ចិត្តចុះទៅក្រោម។

ឱ! នោះហើយព្រះអង្គម្ចាស់ដែលខ្ញុំធ្លាប់រំលឹកឃើញជាញឹកញាប់អំពីបរិយាកាសដែលពោរពេញទៅដោយភាពខ្ពង់ខ្ពស់ថ្លៃថ្នូរ ភាពផ្អែមល្ហែមស្ងប់ស្ងាត់។

ពាក្យសម្តីនិយាយចេញមកមួយៗមិនបន្ទាន់ នាំឱ្យគូដៃស្ងប់ចិត្ត ហើយមានទំនុកចិត្តលើខ្លួនឯង។ លោកវិមលបោះដំណើរទន់ភ្លន់ ដូចរាជសីហ៍តម្រង់មករកខ្ញុំ។ ខ្ញុំលើកដៃសំពះលោក លោកបន្ទន់ខ្លួនសំពះខ្ញុំ ហើយចាប់ដៃខ្ញុំជាគារវកិច្ច ។

លោកវិមលសម្លឹងមើលខ្ញុំ សរសើរសំពត់ខ្មែរពណ៌ខ្មៅដែលមានប៉ាក់ជាយដោយអំបោះ ពណ៌លឿងក្រហមបៃតងដែលម្តាយចិញ្ចឹមខ្ញុំប៉ាក់សំរាប់ខ្ញុំ។

យើងបានចូលទៅអង្គុយនៅភោជនដ្ឋាន ដែលនៅជាប់នឹងឡប់ប៊ី។ យើងអង្គុយទល់មុខគ្នា នៅក្បែរយើងមានទឹកផុសកញ្ច្រោលទាបៗ ប្តូរពណ៌ទៅតាមភ្លើងដែលប្តូរពណ៌ចុះឡើងៗ ហូរតាមប្រឡាយដែលមានកូនដុំគ្រួសសិប្បនិមិត្តគ្រប់ពណ៌តំរៀបពីក្រោម។ ភ្លើងអគ្គិសនីនៅទីនេះមិនភ្លឺចិញ្ចាចឡើយ។ ទីដែលយើងអង្គុយនេះ ហាក់ដូចជាបានទទួលពន្លឺពីភ្លើងពណ៌ ដែលប្តូរចុះឡើងៗសំរាប់បញ្ចាំងឱ្យគ្រួសសិប្បនិមិត្តមានជីវិតរស់រវើក នាំឱ្យឃើញមុខរបស់យើងសំលៀកបំពាក់របស់យើងចាំងពណ៌ស្រទន់ដែរ។

លោកវិមលលើកដៃ ហៅនារីអ្នកបំរើដែលស្លៀកពាក់សំលៀកបំពាក់ជាតិថៃទងវង ពានា ស្បែតូចប្រហែលជាប្រាំធ្នាប់។

យើងហៅភេសជ្ជៈមួយម្នាក់។ លោកហៅកាហ្វេខ្មៅ ខ្ញុំហៅសូដាក្រូចឆ្មារ។ លោកវិមលអង្គុយយ៉ាងសមរម្យ ញែកជើងលោកបន្តិចនិងដាក់កែងដៃទាំងពីររបស់លោកទៅលើភ្នាក់កៅអី។ លោកមានប្រសាសន៍មួយៗថា :

- ខ្ញុំសូមអរគុណនាងណាស់ ពីចិត្តដ៏ល្អរបស់នាងដោយនាងបានជួយយកអាសារខ្ញុំ។

ខ្ញុំភ្ញាក់ព្រើតដោយឃើញលោកចេះភាសាខ្មែរ។ សំនៀងនៅមានបែបបទជាថៃ ប៉ុន្តែគឺជាភាសាខ្មែរដ៏ពិរោះទន់ភ្លន់ ត្រឹមត្រូវតាមក្បួនខ្នាតនិងបទវេយ្យាករណ៍។

- ចាំទេលោក នេះជាការងាររបស់នាងខ្ញុំទេ វាពុំមែនជាអាការៈដែលលោកត្រូវតែដឹងគុណខ្ញុំឡើយ។

ខ្ញុំបង្អង់មួយសន្ទុះទើបនិយាយបន្តថា :

- នាងខ្ញុំឯនេះទេ ដែលសូមអរគុណលោកដោយលោកបានប្រើប្រាស់យន្តហោះយើងខ្ញុំ។

យើងទាំងពីរនាក់នៅស្ងៀមមួយសន្ទុះ។ ដោយពុំឃើញលោកមានប្រសាសន៍ថាម៉េច ខ្ញុំក៏បន្តថា :

- នាងខ្ញុំមិននឹកស្មានថា លោកចេះភាសាខ្មែរស្ទាត់បែបនេះទេ។

ខ្ញុំនិយាយហើយក៏លើកកែវភេសជ្ជៈរបស់ខ្ញុំបំរុងនឹងទទួលទាន។ លោកវិមលក៏បានតបថា :

- ខ្ញុំទើបតែនឹងចាប់រៀនដែរទេ ប៉ុន្តែដោយវាជាការចាំបាច់ផង ហើយភាសាយើងប្រហាក់ប្រហែលនឹងគ្នាផង ខ្ញុំក៏អាចប្រើបានខ្លះៗ។ ប៉ុន្តែនៅយឺតណាស់ដោយអាយុខ្ញុំក៏ជ្រេណាស់ទៅហើយផង។

ខ្ញុំពុំអាចស្មានបានពីអាយុរបស់លោកវិមលបានទេ។ ប៉ុន្តែខ្ញុំពុំមានហេតុផលអ្វីនឹងដឹងឡើយ។

លោកប្រុសនេះខ្ពង់ខ្ពស់ណាស់ ប្រសិនជាគេនៅខ្លួនមួយទៅវិញ មានតែគេស្អប់នារី ឬមួយគេមានបញ្ហាអ្វីមួយនៅក្នុងសរីរាង្គរបស់គេ ឬបើមិនដូច្នេះទេ មានតែគេមានបញ្ហាអ្វីមួយក្នុងគ្រួសារ?

មិនដឹងជាហេតុអ្វី ឬកម្មផលអ្វី បានជានាំឱ្យខ្ញុំខំគិតពីរឿងនេះដល់ថ្នាក់នេះ។ ប្រហែលជាឃើញខ្ញុំភ្លឹកភ្លាំងយូរក៏មិនដឹង លោកវិមលក៏ដកយកប័ណ្ណប្រៃសនីយ៍ដែលខ្ញុំបានផ្ញើទៅជូនពីក្នុងហោប៉ៅក្នុងនៃអាវធំរបស់លោកមកមើល ហើយមានប្រសាសន៍ហាក់ដូចជាគេនិយាយតែម្នាក់ឯង :

- ខ្ញុំមិនទាន់ស្គាល់ឈ្មោះនាងច្បាស់ទេ។ តើនាងឈ្មោះអ្វី? ច័ន្ទ,បូ,រេយ...

ខ្ញុំនៅស្ងៀមមួយសន្ទុះ ទំរាំនឹកថាតើត្រូវនិយាយពីអ្វី។

- ចាំ! ខ្ញុំឈ្មោះច័ន្ទបុរីលោក។

- ឈ្មោះនាងល្អណាស់។ នៅស្រុកនេះមានទីកន្លែងមួយឈ្មោះចន្ទះប៊ូរី។ ខ្ញុំគិតថា ឈ្មោះនោះអាចក្លាយពីពាក្យច័ន្ទបុរីនេះក៏ពុំដឹង។ ភាសារបស់យើងមានដើមកំណើតពីសំស្ក្រិត បាលីដូចគ្នា រួចហើយថៃនិងខ្មែរមានទំនៀមទំលាប់ដូចគ្នាច្រើនកន្លែងណាស់។ ជាពិសេសទំនៀមទំលាប់ភាគច្រើនមានលំនាំពីព្រះរាជាណាចក្រខ្មែរ ដែលធ្លាប់តែជាព្រះរាជាណាច័ក្រដ៏រុងរឿងនៅទ្វីបអាស៊ីយើងនេះ។

- នាងខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ដែលបានឱ្យតម្លៃមកប្រទេសខ្ញុំ។

ខ្ញុំនិយាយទាំងស្រងូតស្រងាត់ ដោយប្រទេសកម្ពុជាដ៏កំសត់របស់ខ្ញុំ ឈប់មានឈ្មោះក្រអូប ឈប់ថ្កុំថ្កើងដូចអតីតកាល ហើយផ្ទុយទៅវិញ ល្បីតែខាងវេទនា ខ្លោចផ្សារ កាប់ចាក់សម្លាប់គ្នា ឥតបាយ សុំទានបរទេស រត់ចោលស្រុកទេស ជាដើម។

លោកវិមលអាចយល់ចិត្តខ្ញុំបានយ៉ាងច្បាស់ លោកមានប្រសាសន៍ថា:

- ច័ន្ទបូរី យើងរួមកម្លាំងគ្នាកសាងកម្ពុជាឡើងវិញ...

ខ្ញុំក៏ងើយមុខមើលមុខលោក ដោយមិនសូវយល់ពីន័យដែលលោកមានប្រសាសន៍។

ភ្នែករបស់យើងបានទង្គិចគ្នាយ៉ាងខ្លាំង។ ខ្ញុំបានដាក់ភ្នែកចុះមុន។ ខ្សែភ្នែកលោកស្រទន់ដូចពន្លឺព្រះច័ន្ទ ប៉ុន្តែមានកម្លាំងខ្លាំង ស្ទើរតែអាចសង្កើញខ្ញុំឱ្យខ្ញុំតក់ស្លុត ឱ្យខ្ញុំញ័រអស់ទាំងសព្វសិពាង្គកាយ។ យើងនៅស្ងៀមទាំងពីរនាក់មួយសន្ទុះ។

បន្ទាប់មក លោកវិមលក៏មានប្រសាសន៍មុន :

- ខ្ញុំឈ្មោះវិមន់ សាក់សិទ្ធី។ បើអានជាសំនៀងខ្មែរគឺ វិមល សាក់សិទ្ធិ។ ខ្ញុំនឹងទៅកាន់កាប់ការងារជាអ្នកធ្វើកម្មវិធីអប់រំនៅអង្គការអ៊ុយណេស្កូ ប្រចាំប្រទេសកម្ពុជាឆាប់ៗនេះ។ ពេលខ្ញុំទៅនៅប្រទេសកម្ពុជា សូមនាងមេត្តាណែនាំខាងកើត ខាងលិចផង។

ខ្ញុំញញឹមដោយភ្ញាក់ផ្អើលផង ដោយត្រេកអរហួសពីការស្មានផង :

- ចាសលោក ។

- តើនាងធ្លាប់បានដើរធ្វើទស្សនកិច្ចនៅទីក្រុងទេពនៅកន្លែងណាខ្លះហើយ?

លោកសួរខ្ញុំ ។

- ចាសលោក នាងខ្ញុំបានត្រឹមតែដើរមើលអីវ៉ាន់ក្បែរៗអាកាសយានដ្ឋានតែប៉ុណ្ណោះទេ មិនដែលបានទៅឯណាឆ្ងាយទេ ។

ខ្ញុំឆ្លើយត្រង់ ។

- ស្អែកនេះ បើនាងមានពេលខ្ញុំនឹងនាំនាងដើរមើលក្រុងទេព ដើម្បីឱ្យនាងបានឃើញកន្លែងសំខាន់ៗខ្លះ ។

នៅថ្ងៃបន្ទាប់ លោកវិមលបានមកចាំខ្ញុំនៅឡប់ប៊ីនៅវេលាម៉ោង៩ព្រឹក ។ យើងជិះរថយន្តនិស្សាំងអ៊ិចស៊ីត្រេលរបស់លោក ធ្វើដំណើរតាមអូតូរូត ដែលមានរថយន្តជាច្រើន ។ ដោយផ្លូវជាប់ យើងបាននិយាយសារសងគ្នាជាប់រហូត ។

- នាងធ្វើការនៅអាកាសចរណ៍កម្ពុជាយូរហើយឬ?

- ចាសលោក, ខ្ញុំធ្វើបានពីរឆ្នាំហើយ ។

- តើនាងស្រឡាញ់ការងារនេះទេ?

- ចាសលោក, ចំពោះនារី ការងារនេះវាល្អប្រសើរសឹងតែជ្រុលទៅហើយ ។ ប៉ុន្តែដោយខ្ញុំនេះ ធ្លាប់បានជំទាស់នឹងគោលបំណងម្តាយ ដែលចង់ឱ្យខ្ញុំធ្វើគ្រូជួនកាលដូចជាចង់សាកល្បងទៅប្រឡងគ្រូលមើលដែរ...

លោកវិមលគ្រលៀសភ្នែកមើលមកខ្ញុំ ។

- ការងារនាង ជាការងារដែលទាមទារឱ្យមានការអត់ធ្មត់ខ្លាំងណាស់ ។ ការបំរើភ្ញៀវក្តី ការងារផ្សេងៗទៀតក្តី សុទ្ធសឹងតែត្រូវការឱ្យនាងមានសុខភាពមាំទាំ ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ។ បើប៉ះចំភ្ញៀវល្អ ជាសំណាងល្អ តែបើប៉ះលើភ្ញៀវមិនល្អ ខ្ញុំជឿថាមិនជាការងារដែលស្រួលទ្រាំទ្រប៉ុន្មានទេ ។ នាងនៅក្មេងមែនតែនាងមានការអត់ធ្មត់ មានចិត្តល្អប្រពៃគួរឱ្យសរសើរណាស់ ។ តើឪពុកម្តាយនាង ធ្វើការអ្វី?

ខ្ញុំហាក់ដូចជាទីទើនឹងជំរាបលោកវិមលណាស់ ។ ឪពុកម្តាយខ្ញុំបានស្លាប់នៅជំនាន់ប៉ុលពតនៅវេលាដែលខ្ញុំមានអាយុ៣ឆ្នាំ ។ ឪពុកខ្ញុំធ្វើវេជ្ជបណ្ឌិត ហើយម្តាយខ្ញុំធ្វើសាស្ត្រាចារ្យបង្រៀនភាសាបារាំង ។ ខ្ញុំបានចិញ្ចឹមមកធំប៉ុននេះដោយសារមេត្តាធមិរបស់ម៉ែកឿងជាមេដោះខ្ញុំ ដែលគ្មានបានរៀនសូត្រចេះដឹងអ្វីច្រើនទេ ។

ម៉ែកឿងបានទទួលការអង្វរករអំពីម្តាយឪពុករបស់ខ្ញុំ ឱ្យជួយបីបាច់ថែរក្សាខ្ញុំយកតែបុណ្យទៅចុះ ។ ឪពុកម្តាយខ្ញុំបានទុកខ្សែមាសព្រមទាំងចិញ្ចៀនពេជ្រដ៏មានតម្លៃឱ្យម៉ែកឿងលក់ចិញ្ចឹមខ្ញុំ ។ ប៉ុន្តែម៉ែបានថែរក្សារបស់ទាំងនោះ ទុកឱ្យខ្ញុំគ្មានឱ្យបាត់បង់អ្វីមួយឡើយ ។ គិតដល់នេះហើយខ្ញុំក៏ឆ្លើយថា :

- ចាសលោក ខ្ញុំគ្មានឪពុកទេមានតែម្តាយ ។ ម្តាយខ្ញុំលក់ដូរមិនសូវជាធូរធារទេ ។

លោកវិមលងក់ក្បាល ពុំដឹងជាលោកគិតអំពីអ្វីទេ ។ យើងបានចុះពីផ្លូវអូតូរូតចេញទៅដល់ផ្លូវបំបែក ចូលទៅទីប្រជុំជននៃទីក្រុងបាងកកដែលមានរថមកពីផ្លូវផ្សេងបន្ថែមទៅទៀត តែចរាចរីតតែស្ទះ ។ រថរបស់យើងកំរើកតើមៗទំរាំនឹងបានមួយហត្ថៗ ។ តាមផ្លូវ មានកុមារយកភួងផ្កាម្លិះមកលក់ឱ្យយើង ឬមនុស្សមកសុំជូតឡានដើម្បីរកកំរៃ ។ លោកវិមលបានទិញផ្កាមួយភួងហើយនិយាយថា :

- ផ្កានេះសំរាប់ព្រះជាម្ចាស់និងនារីរូបស្រស់ ប្រកបដោយបេះដូងថ្លាឆ្វង់ឥតមន្ទិល ដូចព្រះនាងមាយា ព្រះមាតានៃព្រះពុទ្ធ ឬព្រះនាងម៉ារីយ៉ា ព្រះមាតារបស់ព្រះគ្រីស្ត ។

រួចហើយលោកបានហុចផ្កានោះមកខ្ញុំ ។

- សូមអ្នកនាងអញ្ជើញ

ខ្ញុំរួញរាណាស់ ពីព្រោះខ្ញុំមិនអាចតាំងខ្លួនបានថា ខ្លួនស្អាតស្អំមានបេះដូងថ្លាឆ្វង់ ឥតមន្ទិលដូចព្រះនាងទាំងពីរបានឡើយ ។ ខ្ញុំជាមនុស្សដែលពោរពេញទៅដោយកិលេស សេចក្តីលោភលន់ ចង់មានចង់បាន ចង់ឡើងឋានៈ្តរសក្តិ ចង់ឱ្យគេស្រឡាញ់ ។ ខ្ញុំផ្ទាំងមួយសន្ទុះមើលទៅលោក ។ លោកវិមលញញឹម ហើយមានប្រសាសន៍ថា :

- នាងសមរម្យនឹងទទួលផ្កានេះណាស់ ។

- សូមអរគុណលោក ។

ខ្ញុំទទួលកូនកម្រងផ្កាពីលោកមកក្តោបថ្នមៗក្នុងដៃទាំងពីរ ។ ខ្ញុំពុំដឹងជាត្រូវនិយាយថាម៉េច ក្រៅពីនៅស្ងៀម ភ្នែកសំឡឹងទៅមុខត្រង់តែប៉ុណ្ណោះ ។

- ច័ន្ទបុរី សូមនាងយល់ថា មនុស្សមិនអាចវិនិច្ឆ័យខ្លួនឯងដោយខ្លួនឯងបានទេ ។ គឺមានតែអ្នកផ្សេងឯនោះទេ ដែលអាចដាក់ពិន្ទុឱ្យបុគ្គលដទៃបាន ។

ខ្ញុំមិនមានពាក្យអ្វីសំរាប់ឆ្លើយទៅលោកវិញបាន ក៏នៅស្ងៀមរហូតដល់លោកឈប់រថ ។

- ដល់ហើយនាង ។

លោកវិមលចតរថហើយ ក៏នាំខ្ញុំឡើងទៅលើគេហដ្ឋានឈើបុរាណមួយ ។

- នេះជាភោជនីយដ្ឋានមួយ ដែលខ្ញុំតែងតែមកញ៉ាំញឹកញាប់ណាស់ ។

- ចាំ លោក

- ទីនេះមានរបស់ម្យ៉ាងដែលទាក់ទាញចិត្តខ្ញុំជាខ្លាំង នាងដឹងថាអ្វីទេ?

ខ្ញុំមិនទាន់ទាំងបានឆ្លើយផង យើងបានឡើងទៅដល់លើគេហដ្ឋានដែលពុំមានបរិយាកាសជាភោជនីយដ្ឋានបន្តិចសោះ ។ នៅចំពីមុខយើងមានកៅអីឈើវែងមួយ ក្រាលពូកពណ៌ក្រហម មានខ្នើយស្រោមពណ៌លឿងទុំឆ្នៅបីម្ខាង១ជាកំណល់ខ្នង ។ នៅចំហៀងខាងឆ្វេងកៅអីនោះ មានដើមឈើមួយធំខ្ពស់ស្ទើរតែទល់ដំបូល ដាំក្នុងផើងធំមួយដែលនៅចំពីមុខឡប់ឡែឈើឆ្លាក់ក្បាច់ក្រឡោតប្រៀបបាននឹងរចនាបថបន្ទាយស្រី ។ នៅលើឡប់ឡែនោះមានស្បែកធំឆ្លាក់រូបឥសី ដែលប្រៀបបាននឹងស្បែកដែលគេសំរាប់ជើតក្នុងល្ខោនស្បែកបុរាណ និងឆាយាលក្ខណ៍មនុស្សម្នាក់ដែលទំនងជាស្តេច ឬក៏មេទ័ពសំខាន់របស់គេ ។ នៅចំពីមុខនោះមានកៅអីភ្នាក់ឈើពីរ ដែលមានកែបក្រហមដាក់អមសងខាងតុបួនជ្រុងមួយ ដែលមានផ្កាស្រស់មួយថូយ៉ាងធំលំអពីលើ ។ នៅលើពិដានមានស្បៃស្តើងពណ៌ពងមាន់ស្រាល និងប្រផេះស្រាល ដែលអាចជារបស់សិប្បនិមិត្ត ឬក៏ត្បាញដោយដៃនៃសិល្បករចំណាន បន្តោងលើធ្នឹមទាំងឡាយ ប្រៀបបាននឹងទឹករលកអង្កាញ់ៗនៅវេលាដែលខ្យល់ផាត់មក ។

អ្នកបំរើបាននាំយើងចូលទៅអង្គុយនៅតុមួយ ដែលនៅក្បៀនដាច់ពីគេពីឯង ។ យើងបានទទួលកន្សែងជូតដៃហើយ លោកវិមលក៏មានប្រសាសន៍ថា :

- អម្បាញ់មិញ ខ្ញុំរកជំរាបនាងពីអ្វីដែលខ្ញុំជាប់ចិត្តជាងគេនៅហាងនេះ ។ ខ្ញុំនឹងហៅមកជូននាងណាំ ។

- ចាំ លោក ។

នៅពេលនេះខ្ញុំគ្មានយោបល់អ្វីឡើយ មានតែប្រគល់ភារកិច្ចជូនលោកវិមល ឱ្យលោកហៅអាហារនានាតែប៉ុណ្ណោះ ។

អ្នកបំរើបានយកភេសជ្ជៈម្យ៉ាង ពណ៌ក្រហមឆេះ ដូចផ្កាវំយោល មកដាក់នៅមុខយើងទាំងពីរនាក់ ។ លោកវិមលអញ្ជើញខ្ញុំឱ្យទទួលទាន ។

- នាងពិសារទៅមើល ។ នាងមុខជានឹងយល់ពីចិត្តរបស់ខ្ញុំពុំខានទេ ។

ខ្ញុំក្រេបភេសជ្ជៈដ៏ត្រជាក់ មិនរាវដូចភេសជ្ជៈធម្មតា ។

- ទឹកឪឡឹក!

- បាទត្រូវហើយ ។

លោកវិមលហាក់ដូចជា សប្បាយចិត្តជាខ្លាំង ដោយឃើញខ្ញុំសប្បាយរីក រាយ ។

- ឃើញឆ្ងាញ់ទេអ្នកនាង?

- ចាំ , អស្ចារ្យណាស់!

ខ្ញុំសើចជាមួយលោកវិមល ដែលហាក់ដូចជាមានអារម្មណ៍ល្អពិសេស ។ គឺជាពេលវេលាដែលប្រកបទៅដោយសុភមង្គលក្រៃលែងចំពោះខ្ញុំ ។ បន្ទាប់មក យើងបានទទួលទានអាហារចំឡែក១នានា ដូចជាសំឡរតុមយាំបង្គារ ឆាក្ដៅ ដាក់ម្រះព្រៅជាមួយនឹងសាច់ជ្រូកចិញ្ច្រាំ ញុំត្រីមឹកដ៏ហឹរជាដើម ។ ម្ហូបថៃច្រើនមានដាក់វ៉ាន់ស៊ុយជំនួសជីនានា ដែលគេច្រើនប្រើនៅក្នុងម្ហូបខ្មែរនិងយួន ។

លុះយើងទទួលទានអាហាររួចហើយ យើងបានធ្វើដំណើរទៅសារមន្ទីជាតិដែលមានពិល្បដ៏ច្រើន ។ ពិល្បទាំងនេះមានឆ្លាក់នៅលើជញ្ជាំងនៃប្រាសាទនានានៅអង្គរ ។ យើងបានទៅមើលវត្តអារាមរបស់គេ ដែលមានមនុស្សទៅជាជ្រួកជ្រាក់ ខុសពីវត្តអារាមរបស់យើង ហើយវិហាររបស់គេធំ មានបិទកំទេចកញ្ចក់ពណ៌តាំងពីជើង ដល់ចុង មានសភាពចិញ្ចាចចិញ្ចែងណាស់ ។ មានជនជាតិបរទេសទៅមើល ក៏ច្រើនសន្ធឹកសន្ធាប់ ។ នៅក្នុងបរិវេណនៃវិហារវត្តមួយក្នុងចំណោមវត្តពីរ ដែលខ្ញុំបានមើលនោះ មានគំរូប្រាសាទអង្គរវត្ត ដែលមានទំហំប្រហែល ៥ម៉ែត្របួនជ្រុង ។ លោកវិមលឥតមាននិយាយពន្យល់អ្វីទាំងអស់ដល់ខ្ញុំ ។ ខ្ញុំក៏ពុំហ៊ានសាកសួរលោកដែរ ខ្ញុំគ្រាន់តែឆ្ងល់ក្នុងចិត្តចម្លែក ។ តើគេចង់បង្ហាញពីអ្វីក្នុងការដែលគេបានសាងសង់គំរូនេះ ។ បន្ទាប់មក យើងបានទៅមើលផ្ទះរបស់ជីមថុមសុន អាទិទេពនៃសូត្រថៃ ព្រមទាំងភណ្ឌាគារធំ១ពីរបី ។

ខ្ញុំពុំបានទិញអ្វីទេ ពីព្រោះខួរក្បាលរបស់ខ្ញុំហាក់ដូចជាឈប់ស្ងៀមគាំង លែងធ្វើការងារមួយរយៈកាល ហើយវង្វេងវង្វាន់ដូចជាកំពុងតែស្ថិតនៅក្នុងសុបិននិមិត្ត ។ គឺជាពិភពមួយដែលធំទូលាយ សំបូណ៌សប្បាយចិញ្ចាចចិញ្ចើមណាស់ ។

ខ្ញុំធ្លាប់ដើរមើលផ្សារនានា ដែលដាក់តាំងលក់នៅវាលកប៉ាល់ហោះដុំម្ញើងច្រើនលើក ច្រើនសារណាស់ ។ ប៉ុន្តែនៅតែភ្លឹកភ្លាំងនឹងទំនិញដ៏ច្រើនសន្ធឹកសន្ធាប់នៃទីផ្សារទាំងនេះ ដែលមានលក់របស់របរចែកទៅតាមសណ្ឋាននាជាន់ នីមួយ១ ។ ជាទូទៅ ហាងទាំងឡាយមាន ៨ជាន់ ទូលាយល្វឹង ។ នៅជាន់ក្រោមគេច្រើនលក់ចំណីម្ហូបអាហារ ដែលដាក់ក្នុងទូកញ្ចក់ប្រកបដោយអានាម័យគ្រប់គ្រាន់ ។

លោកវិមលបាននាំខ្ញុំត្រឡប់មកសណ្ឋាគារវិញនៅវេលាព្រលប់ ។ បើតាមតែការដើរដ៏ច្រើនដោយស្បែកជើងខ្ពស់បែបនេះ ខ្ញុំគួរតែដួលស្រូសដោយសេចក្ដីហត់នឿយ ផ្ទុយទៅវិញ ខ្ញុំហាក់ដូចជាពុំមានសេចក្ដីនឿយហត់សោះ សឹងតែថាសុំតាមលោកទៅទីដែលលោកទៅ ព្រោះនេះជាលើកទីមួយហើយដែលខ្ញុំមានសេចក្ដីកក់ក្ដៅក្នុងចិត្តបែបនេះ ។

សេចក្ដីស្ងប់នេះ ខុសពីសេចក្ដីស្ងប់ដែលម៉ែកឿងរបស់ខ្ញុំ តែងតែផ្ដល់មក ឱ្យខ្ញុំ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំជាកុមារីតូច ឬជាទេពអប្សរ ជារបស់ថ្លៃថ្លា,,,របស់ដ៏មានតម្លៃខុសពីសព្វដង។ ខ្ញុំទៅជាមានអារម្មណ៍ស្ងួតស្ងប់ ភិតភ័យខ្លាចក្រែងតែខ្ញុំភ្ញាក់ពីដំណេក ហើយសុបិននិមិត្តនេះនឹងរលុបបាត់ទៅជាមួយនឹងរស្មីព្រះអាទិត្យដូចជាដុំហិម(ទឹកកក) ដែលត្រូវតែរលាយរលត់ដោយសារតែកម្ដៅនៃព្រះអាទិត្យបែបនោះឯង។

ថ្ងៃបន្ទាប់ ប្រហែលជាដោយសារការហត់នឿយដោយការដើរពីម្សិលក៏មិនដឹង ឬក៏ដោយសារខ្ញុំពុំចង់ក្រោកដោយភ័យខ្លាចសុបិននិមិត្តដ៏ល្អនេះស្វាងក៏មិនដឹង ខ្ញុំបានគេងរហូតដល់ពេលដែលទូរស័ព្ទលាន់ឡើង។

ខ្ញុំលើកទូរស័ព្ទ ហើយនិយាយហាក់ដូចជាកំពុងតែយល់សប្តិនៅឡើយ។ សម្លេងពីចុងម្ខាងនៃគ្រឿងចក្រដ៏តូចនេះលាន់ឮស្រទន់ ហាក់ដូចជាសម្លេងភ្លេងសំរាប់បំពេរកំដររក្សត្រីយ៏ឱ្យទ្រង់ផ្ទុំបានសុខក្សេមក្សាន្ត។

- ជំរាបសួរ អ្នកនាងច័ន្ទបុរី។

-ឱ! ចាំ, លោក, លោកវិមលឬ?

ខ្ញុំសប្បាយចិត្តណាស់ ទោះជាសម្លេងដែលកំពុងតែនិយាយមករកខ្ញុំនេះជាការពិតក្ដី ជាការស្រមៃក្ដី ជាសុបិននិមិត្តក្ដី ជាអ្វីក៏បានដែរ ពីព្រោះពាក្យសម្ដីនេះស្រទន់ពិរោះណាស់ ហើយទោះបីជានៅក្នុងប្រលោមលោកដ៏ល្បី គឺរឿងសុផាត របស់លោករីមគិន ដែលបានទូន្មានថា កុំឱ្យជឿពាក្យផ្អែមពិរោះរបស់មនុស្សប្រុសយ៉ាងណាក្ដី ក៏ពុំអាចឱ្យខ្ញុំទទួលយកមកទុកជាគតិ ជាការប្រៀនប្រដៅ កុំឱ្យចូលទៅក្នុងអន្ទាក់នៃព្រាន ឬក៏គិតថា លោកវិមលគឺជាព្រាន ដែលរកទាក់រូបខ្ញុំឱ្យចូលទៅក្នុងអន្ទាក់របស់លោក សំរាប់តែជាការសប្បាយមួយពេលរបស់លោកទាល់តែសោះ។ ផ្ទុយទៅវិញ ការទទួលនូវបដិសណ្ឋារកិច្ចកក់ក្ដៅ ការយកចិត្តទុកដាក់ដ៏ផ្អែមល្ហែមនេះ នាំឱ្យបេះដូងដែលរងារ ដែលធ្លាប់តែខ្វះនូវអ្វីម្យ៉ាងដ៏តូចឆ្មារមើលសឹងតែមិនឃើញនេះ បានត្រូវបំពេញ បានត្រូវធ្វើឱ្យស្ងប់ស្ងាត់បាត់ភ័យព្រួយ ហើយបានទទួលនូវសេចក្ដីសុខក្សេមក្សាន្តរកពាក្យអ្វីមកពន្យល់ឱ្យត្រូវក៏ពិបាក។

- នាងកំពុងតែសំរាន្តទេដឹង? ឱ្យខ្ញុំសូមអភ័យទោស បើខ្ញុំរំខានដំណេកនាង។ ខ្ញុំខិតខំកុហកលោក ថាខ្ញុំភ្ញាក់យូរហើយៗរវល់តែអង្គុយភ្លឹក នឹកថាជិតដល់វេលាដែលត្រូវចូលធ្វើការវិញហើយៗពីពេលនេះទៅ តោងតែធ្វើការ គ្មានពេលសំរាកផង តើខ្លួនអាចទ្រាំទ្របានឬអត់។ យើងបាននិយាយគ្នាជាច្រើន ហាក់ដូចជាមិត្តភក្ដិដ៏ជិតស្និទ្ធ ដែលធ្លាប់ស្គាល់គ្នា រាប់អានគ្នាជាយូរយារណាស់មកហើយ។ ខ្ញុំហាក់ដូចជាជឿទុកចិត្តលោកវិមលកាន់តែខ្លាំង ដោយពាក្យសម្ដីរបស់លោកមួយម៉ាត់ៗ សុទ្ធសឹងតែជាពាក្យត្រឹមត្រូវ ណែនាំក្នុងផ្លូវល្អ ទោះបីខ្ញុំដឹងថាលោកជាជនជាតិមួយ ដែលខ្ញុំពុំអាចជឿឱ្យអស់ពីជំរៅចិត្តថាជាមិត្តដោយសុទ្ធចិត្តក្ដី ក៏ពាក្យសម្ដីដែលហូរចេញមកមួយៗពីមាត់បុរសដែលចារិតស្លូតមានដួងចិត្ត ប្រកបទៅដោយសុទិទ្ធិនេះ មានកម្លាំងដ៏ខ្លាំងក្លា អាចក្ដោបអាចក្រសោបបេះដូង ព្រមទាំងតួអង្គសិរីរាង្គខ្ញុំទាំងមូល។ ខ្ញុំចាប់ពណ៌នាពីសេចក្ដីបារម្ភរបស់ខ្ញុំ នៅពេលដែលខ្ញុំលែងមានកម្លាំងមាំមួន លែងមានសម្រស់ ដែលយុវវ័យផ្ដល់ជារង្វាន់តែក្នុងមួយរយៈពេល។ លោកវិមលមិនសើចទេ លោកបែរជាសរសើរខ្ញុំថា ហេតុអ្វីបានជាខ្ញុំគិតដល់ខណៈបែបនោះ? ហើយគឺជាការចម្លែកមួយចំពោះលោក តាំងពីលោកបានស្គាល់ បានមានទំនាក់ទំនងជាមួយនឹងយុវជនមក។ លោកបានមានប្រសាសន៍ថា យុវជនក្នុងលោកសព្វថ្ងៃនេះ រួមទាំង

យុវជនថៃភាគច្រើន គេហាក់ដូចជាលែងសូវគិតពីអនាគត ហើយចង់តែសប្បាយមួយឆាវឱ្យអស់ដៃ ហើយពុំសូវមានយុវជនឯណា ដែលព្រួយបារម្ភពីជីវភាពនាអនាគតកាល ដូចខ្ញុំអញ្ចឹងទេ។ ខ្ញុំបានជំរាបលោកថា ខ្ញុំជាកូនកំព្រា បានរស់មកធំប៉ុណ្ណេះ ដោយសារតែសេចក្ដីមេត្តារបស់ម្ដាយចិញ្ចឹម ដែលស្រឡាញ់ខ្លួន ប្រៀបបាននឹងកូនបង្កើតរបស់គាត់។ ប្រសិនបើអ្នកម្ដាយនេះមិនបានមេត្តា ហើយបោះបង់ចោល ឬមួយក៏វាយធ្វើបាបប្រើប្រាស់ទុកខ្លួនជាខ្ញុំបំរើដាច់ថ្លៃរបស់គាត់ ក៏រូបខ្លួនដែលនៅតូច ដែលគ្មានទីពឹងពំនាក់ ក៏ច្បាស់ជានឹងចេះតែខិតខំទ្រាំដោយយល់ថានេះ ជាព្រេងវាសនា ហើយច្បាស់ជាឥឡូវនេះខ្លួនប្រហែលជាកំពុងតែអង្គុយលក់នំតាមផ្លូវក៏មិនដឹង កំពុងតែរស់នៅក្នុងបនរបស់ស្ត្រីពេស្យាយ៉ាងវេទនា ក៏មិនដឹង។ បំណាច់នឹងបានទទួល មេត្តាធម៌ដ៏ធំធេងហើយ បានមកស្គាល់នូវពិភពដ៏សុខសាន្តស្ទើរតែជឿមិនបាននេះ ទើបចង់ថ្នៃជីវិតរបស់ខ្លួនឱ្យបានរឹងប៉ឹង ហ្នឹងថ្កល់ ដើម្បីឱ្យម្ដាយចិញ្ចឹមបានហ្នឹងហ្នចិត្តផងខ្លួន១ឯងមានជីវភាពជាមនុស្ស ម្នាបែបនេះយូរអង្វែងផងហើយបើអាចធ្វើបាន។ ហើយកន្លែងការងារខ្ញុំសព្វថ្ងៃនេះដូចជាមិនហ្នឹងហ្នទេ។ បើខ្ញុំមានជីវភាពគ្រាន់បើ ខ្ញុំអាចជួយជាកម្លាំងដល់ក្មេងកំព្រាឯទៀត១ ដែលពុំមានម្ដាយឪពុកទំនុកបំរុងផងដែរ។

លោកវិមលស្ដាប់ខ្ញុំនិយាយដោយស្ងៀមស្ងាត់។ មួយសន្ទុះលោកក៏មានប្រសាសន៍ថា :

- ខ្ញុំយល់ចិត្តនាងណាស់។ នៅក្នុងក្រុមហ៊ុននាងសព្វថ្ងៃ មានបុគ្គលិកដែលប្រព្រឹត្តអំពើពុករលួយ ទាំងមិនដឹងថា អំពើនេះវានឹងច្របាច់ករបស់ខ្លួនឯងនៅអនាគតដ៏ខ្លីឡើយ។ បើនាងយល់ថា នាងមានក្ដីបារម្ភ ហើយចង់រកការងារដែលហ្នឹងហ្នរសំរាប់រូបនាងផ្ទាល់ នឹងរូបម្ដាយនាង សូមនាងធ្វើតាមគំរោង ដែលនាងគូរទៅចុះ។ ក្នុងឋានៈជាមិត្តនាងម្នាក់ បើខ្ញុំអាចធ្វើអ្វីដែលជាប្រយោជន៍ដល់នាងបាន ខ្ញុំរីករាយនឹងធ្វើជានិច្ច។

# ជំពូកទី២

ខ្ញុំបានឆ្លងឆ្លើយតាមសំបុត្រជាមួយលោកវិមលមួយរយៈ ហើយចាប់មានចិត្តចង់បន្តការរៀនសូត្រដើម្បីប្រឡងចូលនិស្សិតសាស្ត្រាចារ្យ។ ប៉ុន្តែមុនពេលដែលខ្ញុំប្រឡង ក្រុមហ៊ុនរបស់ខ្ញុំបានកាត់បុគ្គលិកចេញជាបណ្ដើរៗ ហើយខ្ញុំក៏ជាមនុស្សម្នាក់ ដែលត្រូវតែចាកចេញពីក្រុមហ៊ុនដែរ។ ខ្ញុំតោងតែនៅផ្ទះរៀន បណ្ដើរជួយលក់ដូរម៉ែខ្ញុំដែលចាស់ហើយបណ្ដើរ។

មានថ្ងៃមួយ ខ្ញុំចាំបានថា នៅមុនថ្ងៃដែលខ្ញុំប្រឡងនិស្សិតសាស្ត្រាចារ្យ លោកវិមលបានមករកខ្ញុំនៅរាន ដែលខ្ញុំអង្គុយលក់ឥវ៉ាន់ជាមួយម៉ែរបស់ខ្ញុំ។ លោកវិមលបានទៅរកខ្ញុំឯផ្ទះ ហើយបានគេអ្នកជិតខាង នាំមករកខ្ញុំឯទីផ្សារ។ ខ្ញុំអររកអ្វីប្រៀបពុំបាន វេលាដែលខ្ញុំបានឃើញលោកខំស្វះស្វែងមករកខ្ញុំ។

ខ្ញុំណែនាំលោកឱ្យបានស្គាល់ម៉ែខ្ញុំ។ ម៉ែកឿងអរអ្វីសែនអរ ស្ទុះចុះពីលើគ្រែសំរាប់លក់មកត្រហេបត្រហប ដៃមួយលើកក្រមាដែលធ្លាក់ គ្រវាត់ទៅលើស្មាវិញ ដៃមួយទៀតរុញថ្នាំចុកដែលនៅក្នុងមាត់។ ដោយម៉ែធាត់ស្សៀច មើលទៅឃើញក្បាលដែលកោរឥតមានសក់ និងកដ៏ធំសម្បូណិទៅដោយផ្នត់សាច់ពណិខ្មៅរាងក្រហម អ្នកដែលជួបម៉ែជាដំបូងច្បាស់ជាទទួលអារម្មណ៍ចង់សើចក៏មិនដឹង។ ប៉ុន្តែចំពោះខ្ញុំវិញ តួអង្គទាំងអស់របស់ម៉ែ មើលទៅពោរពេញទៅដោយសេចក្ដីកក់ក្ដៅ សេចក្ដីសណ្ដោស ទៅដោយទឹកចិត្តដ៏ទូលាយល្វឹងល្វើយជាងមហាសាគរ ថ្លាឆ្វង់ជាងស្រះហិមពាន្ត ដូចកំណាព្យមួយវគ្គរបស់លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ដែលសរសេរថា :

"ស្រះហិមពាន្តភ្លឺយ៉ាងណា ក៏គង់ភ្លឺថ្លានៅមិនដល់
ស្នេហាមាតាថ្លាឥតខ្វល់ ព្រោះគ្មានកិច្ចកលមកក្បៀកកើយ។
ជ្រៅហើយធំផងមហាសមុទ្រ គង់គេឆ្លងផុតបានដល់ត្រើយ។
គុណម្ដាយ នេះវិញគ្មានត្រើយឡើយ ជ្រៅហើយធំផង ឆ្លងមិនផុត។"

- ឱ! ហ្នឹងហើយឬ លោកម្ចាស់ដែលអ្នកនាងតូចរំលឹកមិនដាច់នោះ។

ម៉ែកឿងស្ទុះមកចាប់ដៃលោកវិមល មើលមុខលោកមិនដាក់ភ្នែកប្រហែលជាប្រាំនាទី។ លោកវិមលញញឹម ហើយហាក់ដូចជាមានអារម្មណ៍ល្អណាស់។ ខ្ញុំរវល់តែភ្លឹកមើលអ្នកទាំងពីរ ភ្លេចគិតថាមានភ្ញៀវមករកទិញឥវ៉ាន់អស់ រលីង។

រានរបស់យើងលក់ចំណី មាននំចក្កច័ន្ទ នំគោហែរ នំសែសយ នំរ៉ោយ យិបយ៉ត ត្រៀបកូរ សង្ខ្យាល្ពៅជាដើម។ ដោយសារទឹកដៃម៉ែកឿងពិសេសចម្លែក រានរបស់យើងតែងតែមានភ្ញៀវឥតដាច់ ខ្លះគេពិសារអង្គុយ ខ្លះទៀតគេឱ្យយើងខ្ចប់ឱ្យគេយកទៅផ្ទះ។ ក្នុងមួយថ្ងៃៗ យើងលក់មិនសូវដែលសល់ទេ។

វេលាដែលខ្ញុំកំពុងចូកនំជូនភ្ញៀវហើយរវល់មួយសន្ទុះ ម៉ែកឿងបានរត់មកជួយខ្ញុំរហូតទាល់តែរវើលដៃបន្តិច ទើបខ្ញុំបែរទៅរកលោកវិមល។ ខ្ញុំឃើញលោកញញឹមសម្លឹងមើលមកខ្ញុំមិនដាក់ភ្នែក។

- ឱ! ខ្ញុំសូមទោស លោក។ លោកអញ្ជើញពិសារលមើលទេ?

លោកវិមលដាក់បង្គុយទៅលើជើងម៉ាឈើ ចាស់ឡើងរលោងស្រិលទៅហើយៗផ្សៀងផ្អងមើលមុខចំណីរបស់យើង។ រួចហើយលោកក៏ពិសារនំសែសយមួយ។

- អស្ចារ្យណាស់។ នេះជាលើកទីមួយរបស់ខ្ញុំហើយ ដែលខ្ញុំបានទទួលទាននំឆ្ងាញ់បែបនេះ។

ខ្ញុំជឿថា ពាក្យនេះមិនមែនជាពាក្យបញ្ចើចបញ្ចើរទាល់តែសោះ។ ខ្ញុំត្រេកអរជាខ្លាំង ញញឹមទៅម៉ែកឿង។ ម៉ែកឿងនិយាយថា :

- អ្នកនាងតូច កូនទៅផ្ទះមុនចុះ ទីនេះពិបាកណាស់ មិនសមរម្យនឹងលោកទេ។ ថ្វីត្បិតតែវានរបស់យើងតូច ក៏ខ្ញុំតែងតែគិតពីរឿងអនាម័យ ហើយខ្ញុំតែងតែសំអាត មិនឱ្យក្រដាសដែលភ្ញៀវជូតមាត់ហើយទម្លាក់ទៅក្រោម នៅរាយនាំឱ្យទើសទាល់ភ្នែកទាល់តែសោះ។ ព្រោះខ្ញុំធ្លាប់រៀនពីអានាម័យនៅសាលា ផងធ្លាប់ចុះឡើងក្រុងបាងកកដែលរីកចំរើនជាងស្រុកយើងឆ្ងាយ ហើយនិងធ្លាប់តែមានគំនិតថា អ្វីដែលគួរតែរៀនពីគេក៏គ្មានអ្វីដែលគួរឱ្យគិតថា ជាការអន់ថយថោកទាបទាល់តែសោះ។ ផ្ទុយទៅវិញ ភាពឡឹតមិនព្រមរៀនសូត្រពីគេហើយក្អេងក្អាងថាខ្លួនគ្រាន់បើទាំងគ្មានកម្លាំង ទាំងខ្សោយឯនោះទេ ដែលជាការខ្មាសអៀន ដែលគួរឱ្យចៀសវៀង។

ខ្ញុំសូមទោសម៉ែខ្ញុំ ហើយណែនាំលោកវិមលទៅផ្ទះរបស់យើង។ ផ្ទះល្វែងនេះយើងបានទិញពីគេ នៅពេលដែលម៉ែខ្ញុំនាំខ្ញុំចូលមកភ្នំពេញដំបូង។ វាស្ថិតនៅជាន់ទី៣ នៃផ្ទះល្វែងមួយជួរនៅម្តុំផ្សារចាស់។ គឺជាផ្ទះល្វែងដ៏ចាស់ ហើយក្រខ្វក់ខ្លាំងណាស់។ ដោយអ្នកដែលចូលមកនៅទីក្រុង ជាប្រជាជន ដែលមានកំណើតនៅជនបទ ហើយមិនស្គាល់ពីរបៀបរស់នៅក្នុងទីក្រុងព្រមទាំង មិនសូវដឹងថាអ្វីទៅដែលហៅថាស្អាត អ្វីទៅដែលហៅថាក្រខ្វក់ ម៉ែខ្ញុំតោងតែនាំខ្ញុំសំអាតកខ្វើក ឥតមាត់ក ក្នុងរយៈពេលដ៏យូរអង្វែង តែម៉ែតែងតែប្រាប់ខ្ញុំថាកុំឱ្យមើលបំណាំឱ្យសោះ។ តោងតែធ្វើ ហើយមិនត្រូវរអ៊ូរទាំឡើយ។ អ្វីដែលយើងធ្វើ ជាកុសលសំរាប់មនុស្សក្តី សត្វក្តី អ្វីក្តី សុទ្ធតែត្រូវបានព្រះជាម្ចាស់លោកមើលពីលើមកឃើញទាំងអស់។ រហូតមកដល់ពេលដែលខ្ញុំដឹងក្តីប៉ុណ្ណោះ



ទង្វើរបស់ខ្ញុំជាច្រើន សុទ្ធសឹងតែជាលទ្ធផលនៃការប្រៀនប្រដៅនៃម៉ែខ្ញុំ ដែលខ្ញុំធ្វើតាមដោយគ្មានចម្ងល់ គ្មានសំណួរ ទាល់តែសោះ។ បុណ្យនៅទីវត្តអារាមក៏ម៉ែធ្វើ បុណ្យជាកុសលសំរាប់មនុស្សម្នាជិតខាងក៏ម៉ែធ្វើ ម្ល៉ោះហើយ នរណាម្នាក់ក៏ស្រឡាញ់ម៉ែ ហើយស្រឡាញ់មកដល់ខ្ញុំផងដែរ។ នៅមានទំនៀមទំលាប់ខ្លះ ដែលពិបាក គឺការចែរចូវចង់បានឱ្យខ្ញុំឆាប់មានគូស្រករ។ តែម៉ែពូកែណាស់។ ម៉ែតែងតែនិយាយថា ម៉ែបង្កើតរបស់ខ្ញុំមានតំរិះវិជ្ជាខ្ពង់ខ្ពស់ ណាស់ដូច្នេះម៉ែតោងតែគោរពសិទ្ធិរបស់ខ្ញុំហើយម៉ែមិនអាចបង្ខំខ្ញុំបានទេ។

ខ្ញុំបាននិយាយប្រាប់ម៉ែជាច្រើន ពីលោកវិមល ហើយម៉ែតែងតែសួរថា តើខ្ញុំស្រឡាញ់លោកឬ? ប៉ុន្តែខ្ញុំពុំអាចដឹងពីចិត្តរបស់ខ្ញុំបានទេ។ ទីមួយ ខ្ញុំពុំដឹងថាលោកនៅលីវឬក៏មានគ្រួសារនៅឡើយផង។ ទីពីររស់នៅលើពិភពអន្តរជាតិការរាប់អានមនុស្ស មិនមែនសុទ្ធតែផ្ទាប់ទៅនឹងសេចក្តីស្នេហាឡើយ ហើយបើយើងរំពឹងជ្រុលពេកក៏នឹងនាំឱ្យខកចិត្តខ្លាំង ដូច្នេះមានតែរង់ចាំកាលទេសៈដោយអំណត់អត់ធ្មត់តែប៉ុណ្ណោះ។ ប្រសិនបើជាគូ ក៏គង់តែនឹងជួប ហើយបើមិនមែនជាគូ គ្រាន់តែជាមិត្តភក្តិ ក៏ជានិស្ស័យមួយដ៏ល្អដែរ ។

ផ្ទះរបស់យើង មានតែបន្ទប់មួយ ដែលឃាំងដោយវាំងនន ផ្ទៃពណ៌ផ្កាឈូកហើយមានគំនូរផ្កាដែលសែហ្វប៉ាសាឱ្យជាកាដូមកខ្ញុំ ហើយប្រហែលជាមានតម្លៃច្រើនក្រៃលដែរបើតាមខ្ញុំស្មាន។ បងសែហ្វដឹងថា ខ្ញុំចូលចិត្តការរចនាផ្ទះឱ្យមានរមនីយភាពណាស់។ ពិតមែនហើយ ទោះបីជាយើងក្រីក្រក្តី ក៏ខ្ញុំតែងតែមានចិត្តមួយចង់រស់នៅក្នុងវិមាន ដោយធ្លាប់ឮម៉ែរៀបរាប់ពីជីវភាពដ៏ត្រកុំត្រកាល នាសម័យមួយដែលខ្ញុំពុំដែលស្គាល់ ព្រោះខ្ញុំស្គាល់តែជំនាន់ ប៉ុលពតដែលគ្មានសេចក្តីរុងរឿង គ្មានសិល្បៈ គ្មានសេចក្តីសប្បូរសប្បាយ ។

ខ្ញុំអញ្ជើញលោកវិមលឱ្យអង្គុយលើកៅអី ដែលដាក់អមសងខាងតុសរសេរសំរាប់ខ្ញុំរៀនជារៀងរាល់ថ្ងៃ។ ផ្ទះយើងឥតមានគ្រឿងសង្ហារឹមអ្វីឱ្យសមល្មមអាចហៅឈ្មោះបានថាជាសាឡុងឡើយ តែលោកវិមលលាន់មាត់សរសើរថាផ្ទះខ្ញុំមានផាសុកភាព ហើយប្រកបទៅដោយសុភមង្គលណាស់ ដោយមានលំអទៅដោយផើងផ្កា ផើងឈើចម្រុះពណ៌ដូចជាឧទ្យាន។ ទោះបីនេះជាពាក្យសម្តីសរសើរជាផ្លូវទូត ក៏ជាពាក្យសម្តីដែលធ្វើឱ្យខ្ញុំសប្បាយរីករាយ ជាជាងឥតមានពួអ្វីដែរ។ ខ្ញុំដឹងថា ផ្ទះអភិជន ឬផ្ទះអ្នកមានធំទូលាយ មានគ្រឿងសង្ហារឹមច្រើន មានរបស់តុបតាំងកំប៉ិកកំប៉ុកគ្រប់មុខ គ្រប់ធុន។ ប៉ុន្តែឱ្យសួរថា តើអ្នកទាំងអស់នោះ គ្រប់គ្រាន់ក្នុងចិត្តរបស់គេទេ ? ប្រហែលជាចម្លើយដែលបកមកវិញច្បាស់ជា មិនគួរឱ្យគាប់ចិត្តអ្នកសួរទេ។ ឯរូបខ្ញុំវិញ ខ្ញុំនៅមានបារម្ភតែម្យ៉ាងគត់គឺ តើការប្រឡងរបស់ខ្ញុំនឹងបានជោគជ័យតាមសេចក្តីប្រាថ្នារបស់ខ្ញុំនិងម៉ែរបស់ខ្ញុំ ឬអត់។ បើបំណងរបស់ខ្ញុំបានសំរេច ហើយខ្ញុំនឹងបានធ្វើគ្រូនៅវិទ្យាល័យ ខ្ញុំច្បាស់ជាអាចសំរាលបន្ទុករបស់អ្នកមានគុណរបស់ខ្ញុំបានច្រើនហើយៗថែមទាំងមានកិត្តិយសមិនបារម្ភខ្លាចគេពោលថា ឥតមានបង្អែកទៀតឡើយ។ សង្គមខ្មែរនាសម័យណាក៏ដោយ ហាក់ដូចជាមិនទាន់ជាសង្គមដែលមានអំណោយផលដល់នារីភេទនៅឡើយទេ។ ហើយបើយើងទន់ខ្សោយមិនតស៊ូបន្តិចទេ ជួនកាលការផ្តល់យោបល់ខ្លះនៃអ្នកជិតខាង ដែលពុំសូវមានការចេះដឹង ឬគិតគូរវែងឆ្ងាយ នឹងទៅជាសម្ពាធនៃផ្លូវចិត្តនៃយើង ដែលគេយល់ថា ជាជនដែលគេអាណិតអាសូរ។ ខ្ញុំមិនសូវចូលចិត្តឱ្យគេអាណិតអាសូរខ្ញុំបែបនេះទេ ខ្ញុំចង់ឱ្យគេរាប់អានខ្ញុំបែបដូចលោកវិមល ដែលផ្តល់ជំនួយជាគំនិតស្មោះត្រង់ និងជន្ទល់ខាងផ្លូវចិត្តដ៏ធំធេងឥតព្រំដែនបែបនេះ។ ត្រូវហើយអ្នកដែលពោរពេញទៅដោយពុទ្ធិចង់បង្រួបខ្លួនឯងដោយពុទ្ធិ។ អ្នកដែលគិតខ្លីចង់ទទួលតែលាភសក្ការៈភ្លាមៗព្រោះពុំយល់តម្លៃនៃពុទ្ធិ នៃតិរិះ ដែលជាគ្រឹះជាមូលដ្ឋាន ជាដើមកំណើតនៃលាភសក្ការៈដ៏ថ្លៃថ្នូរឡើយ។

ខ្ញុំចាក់ទឹកពីក្នុងក្អម ដែលខ្ញុំអប់ផ្កាម្លិះ ហើយលបបង់ផ្សងមួយកូនដុំ ឱ្យឡើងក្រអូបត្រជាក់។ ទឹកនេះជាទឹកដែលយើងទិញពីទីផ្សារមក ដែលគេហៅថាទឹកបរិសុទ្ធ តែយកមកដាំឱ្យពុះ ហើយទុកឱ្យត្រជាក់។ គឺជាការរស់នៅម្យ៉ាងដែលជិតនឹងការរស់នៅបូរាណដែរ ដោយសារម៉ែខ្ញុំក្តី ខ្ញុំផ្ទាល់ក្តី ចូលចិត្តរបស់ដែលគេយល់ថាបូរាណាចារ្យនេះឯងតែម្តង។

លោកវិមលទទួលទឹកពីខ្ញុំ ហើយលោកក្រេបយ៉ាងឆ្ងាញ់។

- ឱ! ឆ្ងាញ់មែន ទឹកនេះ។ បានហើយសូមនាងកុំរវីរវល់ពេក បើការមកលេងរបស់ខ្ញុំ វាក្លាយទៅជាបន្ទុកចំពោះនាង នាំឱ្យរំខាននាង ខ្ញុំមិនរីករាយទាល់តែសោះ។

- ទេ លោក , លោកអញ្ជើញមកម្តងម្កាល។ កម្រណាស់នឹងបានលោកអញ្ជើញមកលេងដល់ផ្ទះបែបនេះ។ បើខ្ញុំដឹងមុនអី ខ្ញុំច្បាស់ជានឹងឱ្យម៉ែរៀបចំម្ហូបឆ្ងាញ់ទទួលលោកមិនខានទេ។ បើលោកមានពេលវេលា ល្ងាចនេះយើងនឹងរៀបចំបាយទឹកទទួលលោក។ ម៉ែខ្ញុំពូកែធ្វើម្ហូបណាស់។

- ខ្ញុំអាចស្មានបាន នៅពេលដែលខ្ញុំទទួលទានបង្អែមនៅឯផ្សារបាត់ទៅហើយ។ ឥឡូវនេះ នាងប្រហែលជាកំពុងតែរវល់ប្រុងប្រៀប ដើម្បីការប្រឡងនិស្សិតសាស្ត្រាចារ្យមិនលែងឡើយ។ ច័ន្ទបុរីខ្ញុំមានដំណឹងល្អមួយ ចង់ឱ្យនាងបានសប្បាយចិត្តជាមួយខ្ញុំដែរ។

- រឿងអ្វីលោក? ខ្ញុំលើកដៃប្រណម្យយ៉ាងតឹងអន្ទះសារ ចង់ដឹងពីរឿងដែលលោកវិមលនឹងប្រាប់បន្តិចទៀតនេះ។

- ខ្ញុំនឹងមកកាន់ដំណែងនៅអ៊ុយណេស្កូ ភ្នំពេញ ចាប់ពីខែក្រោយនេះហើយ។ ឥឡូវនេះ កំពុងតែគិតគូររឿងផ្ទះសម្បែង។ ដល់រកផ្ទះបាន ខ្ញុំសូមអញ្ជើញនាងឱ្យមកលេងផ្ទះរបស់យើងផង។

- ឱ! ចាំលោក។

ខ្ញុំហាក់ដូចជា មានកង្វល់នឹងពាក្យ "យើង" នេះណាស់។ លោកវិមលច្បាស់ជាមានគ្រួសារហើយ។ ប្រាកដណាស់មើលយ៉ាងម៉េចក៏ឃើញថា លោកមិនមែនជាមនុស្សនៅលីវកើតដែរ។ បើគិតពីអាយុ ក៏សក្តិសមតែមានគូស្រករ ហើយបើនិយាយពីរូបរាង ក៏លោកមានរូបស្អាតថ្លៃថ្នូរ ថែមទាំងមានកិត្តិយសណាស់។ ខ្ញុំទៅជាក្តុកក្តួលក្នុងចិត្តជាខ្លាំង។ សម្តីខ្ញុំទៅជាញ័រ។ ខ្ញុំមិនអាចដឹងថា លោកវិមលចាប់អារម្មណ៏មកលើការញាប់ញ័រនេះ ឬយ៉ាងណាទេ តែលោកប្រហែលជាចម្លែកនៅក្នុងចិត្ត ឬក៏លោកអាចយល់ចិត្តខ្ញុំបានជាប្រាកដ ព្រោះលោកពុំមែនជាមនុស្សដំឡូងមូល ដែលមិនយល់ត្រឹមតែចិត្តក្មេងស្រីល្អិតល្អោចប៉ុនៗនេះនោះឡើយ។ លោកបញ្ជាក់ភ្លាមថា លោកនឹងរស់នៅជាមួយកូនស្រីម្នាក់អាយុ ៨ ឆ្នាំ។ ម្តាយនាងតូចនិង លោកកំពុងតែមានវិបត្តិជាមួយគ្នា ហើយកំពុងតែឡើងសាលា ដើម្បីលែងលះគ្នា។ ខ្ញុំហាក់ដូចជាត្រេកអរបន្តិច ទោះបីជាដឹង ថាលោកជាឪពុករបស់ក្មេងស្រីម្នាក់ក្តី ក៏ហាក់ដូចជា មិននាំឱ្យមានកង្វល់ធំដុំក្នុងការរាប់អានជាមិត្តគ្នារវាងខ្ញុំនឹងលោក។ ខ្ញុំដឹងច្បាស់ថា នារីនៅក្នុងលោកមិនថានារីសញ្ជាតិណាជាសញ្ជាតិណាទេ ច្បាស់ជាមិនសប្បាយចិត្តនឹងឃើញស្វាមីរបស់ខ្លួនរាប់អាននារីក្មេងឯណាឡើយ។ នៅពេលដែលលោកប្រមើលឃើញថាខ្ញុំដូចជាបានស្ងប់ចិត្តបន្តិច លោកក៏ញញឹម ហើយមានប្រសាសន៍តិចៗ ថា :

- ខ្ញុំដូចជារាងចាល ហើយគិតថាមិនចង់មានគ្រួសារទៀតទេ។ កូនស្រីខ្ញុំដែលធ្លាប់តែរស់ក្នុងការទំយើរពិបាកចិញ្ចឹមណាស់នាង។ ឃើញនាងចេះគិត ខ្ញុំគោរពនាងណាស់។ នេះហើយជាកូនចៅនៃពូជពង្សដែលធ្លាប់សាងសង់ប្រាសាទបុរាណ និងមានវប្បធម៌ចាស់ទុំ។ ខ្ញុំគិតថា ខ្ញុំនឹងបានរៀនសូត្រពីនាង ហើយប្រសិនបើនាងមានពេលវេលា ខ្ញុំចង់ឱ្យនាងឆ្លៀតឱកាសមកបង្រៀនភាសាខ្មែរដល់កូនស្រីរបស់ខ្ញុំផង។

- ខ្ញុំសូមអរគុណលោកជាខ្លាំង។ តាមធម្មតាខ្ញុំឮថា ជនជាតិថៃចូលចិត្តមើលងាយជនជាតិខ្មែរណាស់ ដោយសារតែយើងមានសង្គ្រាមមិនចេះចប់។ ពួអ្នកខ្លះគេថា ជនជាតិថៃដាក់បណ្តាសារគ្នាថា ឱ្យកើតជាខ្មែរ ព្រោះគេថាខ្មែរជានរកទាំងរស់។ ចុះលោកម៉េចក៏លោកគិតមិនដូចជនជាតិថៃឯទៀតៗអញ្ចឹង?

- ច័ន្ទបុរី ខ្ញុំមិនដឹងថាត្រូវសូមទោសនាងនិងជនជាតិខ្មែរប៉ុណ្ណាទើបសមទេ។ ជនជាតិយើងខ្ញុំល្ងិតល្ងង់ជ្រុល ហើយគិតតែពីឡឹតថាខ្លួនខ្ពង់ខ្ពស់ ដោយពុំចេះប្រវត្តិសាស្ត្រត្រឹមត្រូវ។ ហើយម្យ៉ាងទៀតបើនិយាយឱ្យពិតទៅទៀត សេដ្ឋកិច្ចយើងកំពុងតែស្រុតចុះខ្លាំង ហើយបើកុំតែបានទីផ្សារខ្មែរខ្លះ ក៏យើងពិបាកនឹងបញ្ចេញផលិតផលរបស់យើងលក់ឱ្យអស់ដែរ។ ត្រូវហើយ ប្រទេសខ្មែរក៏ត្រូវការការជ្រោមជ្រែងផ្នែកសេដ្ឋកិច្ចពីថៃដែរ។ ហើយរឿង សង្គ្រាមទៀតសោតពុំមែនជាកំហុសរបស់ប្រជាជនខ្មែរ ឬក៏ដោយសារតែជនជាតិខ្មែរទៅឆក់ប្លន់នរណា ឬក៏ខ្ជិលធ្វើការទើបទទួលផលអាក្រក់នេះឯណា គឺជាអស្មិមានះដ៏ថោកទាប គិតតែពីប្រយោជន៏ផ្ទាល់ខ្លួននៃប្រទេសមហាអំណាច ដែលយកជើង

ជាន់ឈ្លីលើជនជាតិខ្មែរដើម្បីតែផលល្អរបស់គេឯនោះទេតើ។ ជាចៃដន្យទង្វើខ្មៅងងឹតនេះវាប្រព្រឹត្តទៅលើជនជាតិខ្មែរ។ បើយើងជាអ្នកចេះគិត យើងច្បាស់ជាអាចព្រឹក្សាលភ័យបារម្ភ ហើយជួយឈឺចាប់ខ្មែរដែលជាអ្នកភូមិផងរបងជាមួយមិនខានទេ។ តែនេះគឺ មកពីយើងខ្វះការត្រិះរិះ ទើបយើងចេះតែការមើលងាយគេតែម្យ៉ាង។ សូមនាងមេត្តាផ្សព្វផ្សាយនូវពុទ្ធិ នូវសេចក្ដីមេត្តាដូចដែលនាងតែងតែនិយាយជាមួយខ្ញុំ ធ្វើមកលើខ្ញុំឱ្យអ្នកផ្សេងៗឯទៀតបានយល់ផង។

- ទេ លោក. យើងខ្ញុំនេះមិនដឹងជាមានអ្វីបង្រៀនដល់លោកទេ។ អ្វីដែលយើងមានសុទ្ធតែបុរាណប្រើការមិនកើតទេនៅសម័យវិទ្យាសាស្ត្រនេះ។

- នេះហើយ ដែលពួកមនុស្សសម័យថ្មីតែងគិត។ វប្បធម៌របស់នាងចាស់ជាងវប្បធម៌ពួកយើង។ ប្រទេសកម្ពុជានៅមានអ្វីដែលពួកយើងបានបាត់បង់អស់ទៅហើយ។ ដោយហេតុនេះហើយ បានជាខ្ញុំតែងតែមានបំណងខ្ជាប់ខ្ជួនចង់ឱ្យកូនស្រីខ្ញុំមករៀនសូត្រនៅទីនេះ ដើម្បីឱ្យគេក្លាយទៅជា មនុស្សចាស់ទុំម្នាក់ប្រកបទៅដោយសុភនិច្ច័យ។

ខ្ញុំហាក់ដូចជាពិបាកយល់ និងជឿពីជម្រៅចិត្តណាស់ចំពោះពាក្យសម្ដីជនជាតិថៃ តួយ៉ាងលោកវិមលដ៏ចម្លែកនេះ។ ប៉ុន្តែដោយខ្ញុំធ្លាប់ជឿជាក់ថា ជនជាតិខ្ញុំជាជនជាតិមានមេត្រ្យត ហើយពិតជាធ្លាប់មានវប្បធម៌ខ្ពង់ខ្ពស់មែន ផងខ្ញុំក៏សុខចិត្តទទួលថា ជាពាក្យសម្ដីដ៏ស្មោះត្រង់នៃមនុស្សម្នាក់ ដែលមានគំនិតជឿនលឿន មានមនុស្សធម៌។

# ជំពូកទី៣

ខ្ញុំបានប្រឡងជាប់សញ្ញាប័ត្រនិស្សិតសាស្ត្រាចារ្យផ្នែកភូមិវិទ្យា និងប្រវត្តិ វិទ្យា ជាប់តាមសេចក្ដីបំណង និងតាមសេចក្ដីបន់ស្រន់របស់ម៉ែខ្ញុំដោយ សុវត្ថិភាព។ លោកវិមលបានអញ្ជើញម៉ែ និងខ្ញុំទៅទទួលទានអាហារនៅភោជនីយដ្ឋានបស្ចឹមប្រទេសមួយនៅជិតវត្តភ្នំ ជាការជូនពរជ័យ និងការលើកទឹកចិត្តដល់ម៉ែនិងរូបខ្ញុំ និងជាការសរសើរដល់យើងម្ដាយកូនទាំងពីរ ដែលតែងតែខិតខំប្រឹងលើកទឹកចិត្តគ្នាទៅវិញទៅមក ដែលលោកជាអ្នកក្រៅមើលមកឃើញថា ជាទង្វើគួរឱ្យរំភើប ហើយនាំឱ្យទៅជាកម្លាំង ជាឋាមពលថ្មីសំរាប់ណែនាំលោកឱ្យខិតខំប្រឹងប្រែងនៅចំពោះមុខឧបសគ្គនានា ដែលតែងតែមានជាប្រចាំ នៅពេលដែលយើងខិតខំរស់ដោយសុចរិត និងដោយ សមាជីវៈរបស់ ខ្លួន។

ការតុបតែងលំអក្ដី ការបំរើអាហារ បរិយាកាសទាំងមូលព្រមទាំងចំរៀងដែលគេចាក់ក្ដី ពោរពេញទៅដោយភាពស្ងប់ស្ងាត់ហ្នឹងហ្នរណាស់ តែចំពោះម៉ែ ខ្ញុំគាត់ហាក់ដូចជាពិបាកនឹងអង្គុយឱ្យស្ងៀម ឱ្យបានស្ងប់ចិត្តណាស់។ គាត់ហាក់ដូចជារអើល១ ដោយសារទិដ្ឋភាពទាំងឡាយនេះវាថ្មីស្រឡាងពេក ហើយខ្ញុំអាណិតម៉ែខ្ញុំណាស់។

លោកវិមលហាក់ដូចជាយល់ចិត្តខ្ញុំ លោកខិតខំរិះរកពាក្យសប្បាយរីករាយមកនិយាយជាមួយម៉ែ។ ពីព្រោះលោកពុំមានបំណងអ្វីនឹងនាំពួកយើងឱ្យមកលំបាក ដើម្បីលោកសើចលេងជាការកំសាន្តបែបពួកមនុស្សច្រឡោងខាមខ្លះឡើយ។ លោកមានប្រសាសន៍ថា ការមកពិសារម្ហូបបរទេសបែបនេះ វាជាការលំបាកមួយនៅពេលដែលយើងមិនទាន់ធ្លាប់ តែគួរទទួលទានដើម្បីឱ្យដឹងថាម្ហូបគេមានរសជាតិដូចម្ដេចដែរ ទទួលទានបាន ឬមិនបាន មិនជាបញ្ហាអ្វីទាំងអស់ គ្រាន់តែគិតថា កូនប្រុសម្នាក់នាំមកឱ្យម៉ែដឹងពីម្ហូបបរទេស។ ម៉ែសើចអៀនហើយថា នេះបើកុំតែកូនឯង កុំអីម៉ែមិនយកកើ្តមកចោលកណ្ដាលខ្មាស់បែបនេះទេ។ ប៉ុន្តែម៉ែក៏មានគំនិតជឿនលឿន ចង់ស្គាល់ចង់ភ្លក្សម្ហូបបារាំងម្ដងដែរ។

ម៉ែខ្ញុំមិនចេះពិសារដោយកាំបិតនិងសមទេ បើស្លាបព្រានិងសម វាជាទំនៀមទម្លាប់ខ្មែរ អាចចេះតែពពីមពពាម ហើយមានឱកាសអាចក្រេបជញ្ជក់រសជាតិម្ហូបអាហារចម្លែកបានខ្លះ ដល់តែឱ្យប្រើសមកាំបិត រវល់តែបញ្ជូនអារម្មណ៍ទៅកាន់កាំបិត កាន់សម ភ្លេចគិតពីតួអង្គសំខាន់ជាងគេ គឺម្ហូបអស់រលីង។

ប្រាកដណាស់នៅពេលដែលយើងត្រឡប់ទៅដល់ផ្ទះវិញ ហើយខ្ញុំសួរម៉ែពីម្ហូបដែលម៉ែពិសារ ម៉ែគ្មានចាំអ្វីបន្តិច តែខ្ញុំចាំច្បាស់ថា ម៉ែបានជំរាបលោកវិមលថាម្ហូបគេឆ្ងាញ់ចម្លែកណាស់។ មិនតែប៉ុណ្ណោះ ម៉ែថែមទាំងថែមគ្រឿងថែមល្បោយទៀតថា ថ្ងៃណាមួយម៉ែនឹងច្នៃគ្រឿងផ្សំដែលម៉ែអាចរកបាន ធ្វើម្ហូបបែបនេះនៅផ្ទះយើងហើយ អញ្ជើញលោកវិមលមកពិសារសាកថែមទៀត។ ម៉ែនិយាយយ៉ាងវាហីថា ត្រឹមតែធ្វើម្ហូបប៉ុន១នេះ ទៅក្រអ្វី នឹងធ្វើ?ស្ដាយលុយអើយស្ដាយ។ ម៉ែថាបែបនេះ នៅពេលដែលដឹងថា លោកវិមលចាយលុយជិតមួយរយដុល្លា សំរាប់បាយមួយពេលនេះ។

ខ្ញុំឃើញថាម្ដាយចិញ្ចឹមខ្ញុំ ទោះបីជាគាត់មិនបានទៅរៀននៅសាកលវិទ្យាល័យ ឬក៏ទៅសាលាជាន់ខ្ពស់ឯណាមួយក្ដី ក៏គាត់មានលក្ខណៈប្រសើរមួយគឺការពូកែក្នុងទំនាក់ទំនងជាមួយនិងមនុស្ស និងចេះដឹងក្នុងការរស់នៅក្នុងសង្គមណាស់។

ខ្ញុំតែងតែជិះកង់ឌុយរ៉ាដែលម៉ែខ្ញុំទិញ ជាចំណងដៃ ក្នុងការប្រឡងនិស្សិតសាស្ត្រាចារ្យជាប់។ ពីផ្ទះរបស់យើងទៅសាលារបស់ខ្ញុំៗអាចដើរទៅដល់ ដោយប្រើពេលវេលា ២៥ នាទី ទៅ ៣០នាទី តែបើខ្ញុំជិះកង់ខ្ញុំអាចចំណេញបាន១៥នាទី សំរាប់ជួយធ្វើការនានាក្នុងផ្ទះបានដែរ។

លោកវិមលបានពឹងខ្ញុំឱ្យជួយបង្រៀនភាសាខ្មែរកូនស្រីលោក។ នាងតូចឈ្មោះ វីរៈផាន។ វេលាដែលខ្ញុំសួរនាងពីឈ្មោះឪពុកនាង នាងតូចតែងតែនិយាយថា ឪពុកនាងឈ្មោះ ច័ន្ទក្រឹស្នា។ ខ្ញុំឆ្ងល់ហើយបានជំរាបសួរលោក។ លោកវិមលមានប្រសាសន៍ថា ភរិយាលោកដែលជាមិត្តរួមថ្នាក់នៅសាលាបឋមសិក្សា តែងមានទម្លាប់ហៅលោកបែបនេះ ដោយហេតុថាផ្ទះលោកលក់វត្ថុបុរាណហើយនៅក្នុងចំណោមទំនិញទាំងឡាយ ឈើក្លឹមច័ន្ទក្រឹស្នាមានឈ្មោះល្បីរហូតដល់គេឱ្យឈ្មោះក្រៅលោកថា កូនក្លឹមច័ន្ទក្រឹស្នា។ ខ្ញុំបានជំរាបលោកថា ឈ្មោះវិមលក៏ល្អ ហើយឈ្មោះក្លឹមច័ន្ទក្រឹស្នាក៏ល្អដែរ។ នៅវេលាដែលខ្ញុំដឹងថា លោកវិមលមានឈ្មោះមួយផ្សេងទៀត ខ្ញុំក៏តែងតែលួចហៅលោកជាមួយនឹងកូនស្រីលោកថា លោកឪពុកក្លឹមច័ន្ទក្រឹស្នា។

ខ្ញុំបង្រៀននាងវិរៈផាន មួយអាទិត្យតែបីដងទេ ប៉ុន្តែនៅពេលដែលលោកវិមលមានការជាប់រវល់ទៅជប់លៀង ហើយត្រូវត្រឡប់មកផ្ទះយឺត លោកតែងតែទូរស័ព្ទមកប្រាប់ សុំឱ្យខ្ញុំនៅជួយមើលនាងតូច ឬ បើខ្ញុំមិនអាចនៅបាន ទេ ខ្ញុំអាចទុកនាងឱ្យនៅតែឯងហើយត្រឡប់ទៅផ្ទះបាន។ ប៉ុន្តែខ្ញុំមិនហ៊ានដាច់ចិត្តឱ្យកុមារីតូចនេះនៅផ្ទះដ៏ធំល្វឹងល្វើយតែឯកឯងសោះ។ ម៉ែខ្ញុំតែងតែនៅជាប់ជាមួយខ្ញុំជានិច្ច ហើយម៉ែតែងតែប្រាប់ខ្ញុំថា ប្រសិនបើម៉ែប្រហែសទុកខ្ញុំឱ្យនៅតែឯង ហើយបើមានអ្វីកើតឡើងជាយថាហេតុដល់រូបខ្ញុំ ម៉ែច្បាស់ជានឹងស្តាយក្រោយ ហើយបោកក្បាលខ្លួនឯងសម្លាប់ខ្លួនមិនលែងឡើយ។ ត្រង់នេះហើយ ដែលខ្ញុំចេះតែមិនដាច់ចិត្តទុកនាងតូចឱ្យនៅតែឯង។ ខ្ញុំតែងតែអានសៀវភៅរឿង ឬសៀវភៅរូបឱ្យនាងតូចស្តាប់រហូតដល់នាងគេងលក់ រួចហើយខ្ញុំក៏ចាប់សៀវភៅរបស់ខ្ញុំមករៀន ទំរាំតែលោកវិមលត្រឡប់មកវិញ លោកជូនឡានខ្ញុំ ប្រហែលជា ១០នាទី ទៅដល់មុខផ្ទះខ្ញុំ។

លោកវិមលតែងតែមានប្រសាសន៍ប្រាប់ខ្ញុំពីវិជ្ជាអប់រំ លោកបានឱ្យខ្ញុំខ្ចីសៀវភៅស្តីពីការអប់រំនៅប្រទេសនានា ដែលគួរឱ្យចាប់អារម្មណ៍ជាខ្លាំង។ លើសពីនេះ ដោយខ្ញុំពុំសូវចេះភាសាអង់គ្លេស លោកបានយកសៀវភៅនោះធ្វើជាអត្ថបទសំរាប់បង្រៀនខ្ញុំឱ្យខ្ញុំចេះ ឱ្យខ្ញុំភ្លឺស្វាង ហាក់ដូចជាបានចេញទៅសិក្សានៅឯសាកលវិទ្យាល័យបរទេសណាមួយ។ ការរៀនសូត្រនេះ ជួនកាលប្រព្រឹត្តទៅនៅក្នុងក្លឹបអន្តរជាតិ ជួនកាលទៅនៅសួនកុមារ ដោយយើងដាក់ឱ្យនាងតូចវីរៈផានជិះជំនិះតូចៗ តាមនាងចង់។ តាមរយៈលោកវិមល ខ្ញុំបានដឹងថា ស្រុកយើងវិវត្តទៅមុខបន្តិចម្តងៗហើយ ហើយបន្តិចទៀតអនាគតដ៏ភ្លឺស្វាងមួយច្បាស់ជានឹងចូលមកសណ្ឋិតនៅជាប់លាប់នឹងប្រទេសនេះ ជាប្រាកដឥតសង្ស័យ។

ដោយកាលពីនៅពីក្មេង ខ្ញុំពុំដែលស្គាល់ល្បែងក្មេង មិនដែលស្គាល់សួនកុមារ អ្វីៗដែលខ្ញុំបានឃើញ បានជួបប្រសព្វនៅពេលនេះ ធ្វើឱ្យខ្ញុំសប្បាយរីករាយ ណាស់ ហើយខ្ញុំតែងតែជំរាបលោកវិមលដោយត្រង់ឥតលាក់លៀមទាំងអស់។

ចំពោះភ្នែកលោកវិមលក្រៅពីនាងតូចវិរៈផាន ខ្ញុំដែលធំហួសពីពេញក្រមុំស្លូកនេះ ក៏ប្រហែលជាមិនមានន័យអ្វីឱ្យលើសពីកុមារីម្នាក់ឡើយ។ ភ្នែកដែលលោកមើលមកខ្ញុំ និងភ្នែកដែលលោកសម្លឹងទៅនាងតូចវីរៈផាន ស្រទន់ដូចគ្នា។

ត្រូវហើយ លោកវិមលមិនមែនជាបុរសនៅទំនេរទេ។ នៅការិយាល័យរបស់លោក មាននារីបរទេសម្នាក់ពីរខិតខំតាមលោករហូតមកដល់ផ្ទះ ហើយម្រិកម្រក់ដាក់លោក ស្និទ្ធស្នាលជ្រុលហួសជាមួយលោក ហើយខ្ញុំមិនអាចដឹងបានថាលោកមានការចាប់អារម្មណ៍ទៅលើគេឬអត់ទេ។ ប៉ុន្តែចំពោះរូបខ្ញុំៗដឹងថាខ្លួនខ្ញុំនេះបុរាណណាស់ ហើយខ្ញុំទៅជាលែងសង្ឃឹមថា នឹងទទួលសេចក្ដីស្នេហាពីលោកទាល់តែសោះ។ ខ្ញុំឃើញអ្នកដែលមកលេងជាមួយលោកសុទ្ធតែជានារីដែលមកពីស្រុកជឿនលឿន និយាយអង់គ្លេសហូរដូចទឹកមើលទៅហាក់ដូចជារុងរឿងណាស់។ ឯខ្ញុំប្រហែលជាពិបាកនឹងទៅតាមជំនុំចំណោមនៃសង្គមអ្នកមានការអប់រំខ្ពង់ខ្ពស់ទាំងនេះបានណាស់។ ខ្ញុំបានគិតដូច្នេះមែន ប៉ុន្តែនៅក្នុងចិត្ត ខ្ញុំតែងតែចង់តាក់តែងធ្វើឱ្យរូបខ្លួនឯងចិញ្ចាចចិញ្ចែង ទៅដោយការអប់រំខ្ពង់ខ្ពស់ ចេះភាសាបរទេសបីបួន អាចប្ដូរយោបល់ជាមួយនឹងអ្នកសិក្សាទាំងឡាយ អាចនិយាយការពារផលប្រយោជន៍ប្រទេសជាតិរបស់ខ្លួន នៅលើស្រទាប់អន្តរជាតិ ជំនួសអស់លោកបរទេសទាំងឡាយនេះណាស់។ គេជាអ្នកសិក្សាស្រាវជ្រាវឯកទេសមែន តែគេពុំមែនយល់ជ្រៅឬក៏គិតពីប្រយោជន៍ខ្មែរជាជាងប្រយោជន៍ផ្ទាល់របស់គេ ឬប្រទេសរបស់គេទេ។ ទាំងនេះលោកវិមលឧស្សាហ៍មានប្រសាសន៍ប្រាប់ខ្ញុំណាស់។

ធាតុអាកាសខែមេសានៅទីក្រុងភ្នំពេញក្ដៅសឹងតែទ្រាំពុំបាន តាំងពីមានការប្រើម៉ាស៊ីនត្រជាក់ស្ទើរតែគ្រប់ទីកន្លែងនៅក្នុងក្រុងដ៏តូចចង្អៀតនេះមក។ នៅវេលាបែបនេះ លោកវិមលច្រើនតែនាំនាងតូចទៅកំពង់សោមដែលមានខ្យល់អាកាសបរិសុទ្ធ ហើយឃ្លាតឆ្ងាយពីជំនុំចំណោមនៃមនុស្សនានា។

លោកតែងតែសួរខ្ញុំថា តើខ្ញុំអាចទៅជាមួយលោកបានទេ ពីព្រោះនាងវីរៈផានហាក់ដូចជាចូលចិត្តលេងជាមួយខ្ញុំជាងលេងជាមួយលោក។ ខ្ញុំទទួលសេចក្ដីអញ្ជើញរបស់លោកម្ដងម្កាលដែរ ព្រោះខ្ញុំចង់ឱ្យឪពុកកូនទាំងពីរមានឱកាសនៅជួបជុំគ្នាផង ហើយខ្ញុំតោងតែនៅក្បែរម៉ែដែលចាស់ហើយបន្តិចបន្តួចផង។

ទីក្រុងកំពង់សោម ជាទីរមនីយមួយ ដែលមិនទាន់មានទេសចរស្គាល់គ្រប់គ្នាដូចអង្គរវត្តទេ។ ខ្ញុំសំគាល់ឃើញថា លោកវិមលមិនសូវចូលចិត្តងូតទឹកឡើយ។ លោកឱ្យយើងទាំងពីរលេងជាមួយគ្នា ឯលោកវិញអង្គុយមើលសៀវភៅស្ងប់ស្ងាត់តែម្នាក់ឯង។ បើខ្ញុំឡើងមកជិតលោកៗសួរយោបល់ខ្ញុំ ដូច្នេះមិនដឹងពីអង្កាលទេ ខ្ញុំស្រាប់តែចេះបញ្ចេញយោបល់របស់ខ្លួនឯង ហើយចាប់ចង់ចេះចង់ដឹងពីការអប់រំនៅប្រទេសអាស៊ីដូចប្រទេសកម្ពុជាដែរ។ ខ្ញុំហ៊ានសួរលោក នូវអ្វីដែលខ្ញុំមិនដឹង ដោយខ្ញុំជឿជាក់ថា លោកមិនដែលបដិសេធ ឬក៏សើចចំអកចំពោះការមិនយល់មិនដឹងរបស់ខ្ញុំឡើយ ផ្ទុយទៅវិញ លោកហាក់ដូចជាសប្បាយចិត្តនឹងពន្យល់ នឹងនិយាយឱ្យយើងស្ដាប់លោកចំហមាត់។ ខ្ញុំសង្កេតឃើញថា ឪពុកម្ដាយខ្លះប្រកាន់មិនឱ្យកូនបរិភោគ ចំណីដែលគេធ្វើលក់នៅតាមផ្លូវទេ តែលោកវិមលវិញ លោកចូលចិត្តហៅរបស់ដែលគេធ្វើលក់នៅមាត់សមុទ្រ ហើយពិសារជាមួយនឹងខ្ញុំ ពោលគឺ យើងពុំមានចាំបាច់នឹងអៀនអន់ឬលាក់គំនួច ឬក៏រៀបចំឫកពារជាអ្នកខ្ពង់ខ្ពស់អ្វីទាំងអស់។ ខ្ញុំពុំមានការទើសទាល់ ឬរៀបឫកឱ្យហត់ឥតអំពើឡើយនៅចំពោះបុរសដែលខ្ញុំគោរពស្រឡាញ់ជាងនរណាៗទាំងអស់នេះសោះឡើយជាលើកដំបូង ក្រៅពីម៉ែ ដែលស្រឡាញ់ថែទាំខ្ញុំ។ វេលាខ្លះលោកទាញដៃកូនស្រីលោកព្រមទាំងដៃខ្ញុំ រត់លើឆ្នេរខ្សាច់

ដ៏សក្បុស ហើយចម្លែកទៅទៀត គឺលោកចូលចិត្តច្រៀងបទ សក្រវ៉ាទ៍។ ខ្ញុំចង់តែសើចចំពោះបុរសនេះ ដែលចូលចិត្តអ្វីដែលចាស់បូរាណ។ លោកស្គាល់ឈ្មោះផ្កា ឈ្មោះដើមឈើ ហើយលោកតែងតែប្រាប់ជាឈ្មោះថៃដល់នាង វិរៈផាន ហើយសួរឈ្មោះជាខ្មែរពីខ្ញុំ។ ខ្ញុំតែងតែកោតសរសើរលោក នៅក្នុងចិត្ត របស់ខ្ញុំថាមន្ត្រីនេះពិតជាអ្នកសិក្សាអប់រំពិតប្រាកដមែន។

រដូវក្តៅបានកន្លងទៅ ហើយរដូវវស្សាបានចូលមកផ្លាស់ប្តូរវេនរបស់ខ្លួនយ៉ាងទៀងទាត់ទៅតាមច្បាប់នៃធម្មជាតិ។ លោកវិមលបានមកកាន់ការងារអ៊ុយណេស្កូនៅប្រទេសកម្ពុជាបានរយៈពេលជិតមួយឆ្នាំហើយ។

នៅថ្ងៃមួយ លោកត្រឡប់មកដល់ផ្ទះយឺត នៅម៉ោងជាង ៨ ទៅហើយ នៅពេលដែលមានភ្លៀងធ្លាក់ជោគជាំ។ លោកហាក់ដូចជាហត់នឿយណាស់ តែលោកចេះតែចចេសជូនខ្ញុំទៅផ្ទះ។ ខ្ញុំជំរាបថា ថ្ងៃនេះ ខ្ញុំអាចជិះស៊ីក្លូទៅបាន តែលោកមិនព្រមទាល់តែសោះ។

វេលាដែលយើងចូលទៅអង្គុយនៅក្នុងរថ ស្រាប់តែលោកមានប្រសាសន៍ថា លោកងងឹតមុខណាស់។ ខ្ញុំអាចស្មានបានថា លោកកំពុងតែពិបាកខ្លាំង ខ្ញុំគ្រាហ៍លោកចូលទៅក្នុងគេហដ្ឋានវិញ ហើយបានដឹងថា លោកក្តៅខ្លួនខ្លាំងណាស់។ រួចហើយលោកចាប់ក្អកជាខ្លាំង។ ថ្មីៗនេះ ខ្ញុំឃើញលោកឧស្សាហ៍ក្អក ក៏ចេះតែគិតថា លោកប្រហែលជាផ្តាសាយហើយ។

ខ្ញុំបានដាក់លោកឱ្យសំរាន្ត រកខ្មើយទឹកកកមកស្អំក្បាល ថ្ងាស។ វេលាយប់នោះ ខ្ញុំពុំបានទទួលទានដំណេកមួយស្រឡេតឡើយ។ លុះព្រឹកឡើង នៅពេលដែលខ្ញុំកំពុងតែលុបលាងមុខ បំរុងនឹងត្រឡប់ទៅផ្ទះវិញ លោកវិមលបានដើរធីងធោងចូលមក ហាក់ដូចជាបំរុងនឹងចូលបន្ទប់ទឹក។

ខ្ញុំភ្ញាក់ព្រើត ប្រញាប់ទៅជួយគ្រាហ៍លោក។ ខ្ញុំដាក់លោកឱ្យចូលអង្គុយ ហើយរង់ចាំនៅខាងក្រៅ។ វេលាដែលខ្ញុំគ្រាហ៍លោកទៅរកគ្រែវិញ លោកសុំខ្ញុំឱ្យដាក់លោកឱ្យអង្គុយលើកៅអីសាឡុង។ លោកគ្រវីក្បាលយឺតៗ។ ខ្ញុំដឹងថា លោកកំពុងតែធ្លាក់ទៅក្នុងសេចក្តីអស់សង្ឃឹមយ៉ាងធំធេងណាស់។ ខ្ញុំអង្គុយលើកៅអីនៅចំពីមុខលោកស្ងៀម។ ខ្ញុំមិនហ៊ានស្រដីអ្វីទេ ទុកឱ្យលោកមានប្រសាសន៍ដោយខ្លួនលោក។ មួយសន្ទុះមក លោកក៏មានប្រសាសន៍ថា :

- ច័ន្ទបុរី ! ខ្ញុំស្តាយណាស់ ។ ខ្ញុំគិតថាខ្លួនខ្ញុំនិងនាង អាចទៅជាស្ពានសំរាប់ចម្លងមិត្តភាពរវាងថៃ និងខ្មែរបាន។ ខ្ញុំធ្លាប់រៀនប្រវត្តិសាស្ត្រនៅមហាវិទ្យាល័យហើយទើបនឹងបានដឹងនៅពេលនោះ។ គឺជាលើកដំបូងហើយក្នុងជីវិតខ្ញុំដែលខ្ញុំបានដឹងថា ជនជាតិខ្ញុំបានយល់ច្រឡំយ៉ាងខ្លាំងទៅលើខ្មែរ។ សូមនាងអភ័យទោស ប្រវត្តិវិទូរយើងសរសេរប្រវត្តិសាស្ត្រដែលមានលក្ខណៈមិនសមស្របនឹងវិទ្យាសាស្ត្រ ហើយលុះយើងទៅសាកលវិទ្យាល័យស្រាវជ្រាវតាមឯកសារជនជាតិអឺរ៉ុបនិងអាមេរិកទៅទើបបានដឹងច្បាស់ថា អ្វីដែលយើងបានរៀនមកនៅពីតូចនាំឱ្យយើងយល់ច្រឡំថា ខ្មែរលួចដីយើងហើយយើងចេះតែប្រាថ្នាទាមទារយកមកវិញដោយត្រឹមត្រូវ និងយុត្តិធម៌។ ខ្ញុំចង់ឱ្យរដ្ឋាភិបាលខ្មែរតវ៉ាតាមផ្លូវទូតតាមស្ថានទូតថៃ ឱ្យគេកែតម្រូវការសិក្សាប្រវត្តិសាស្ត្រនៅតាមបឋមសិក្សានិងមធ្យមសិក្សាថៃ ដើម្បីចៀសវាងការយល់ច្រឡំតទៅទៀតរវាងប្រជាជនយើងទាំងពីរ។ បន្តិចទៀត នៅពេលដែលទៅជាអាស៊ាន១០ (ពេលដែលខ្ញុំចាប់សរសេររឿងនេះ យើងពុំទាន់ចូលអាស៊ាននៅឡើយទេ) ខ្ញុំប្រាថ្នាឱ្យការងារនេះបានសំរេច ហើយឱ្យប្រជាជនថៃដឹងការពិតឱ្យគេស្រឡាញ់

ខ្មែរដោយសុទ្ធចិត្ត ។ ហើយខ្មែរក៏នឹងស្រួលប្រើវិធីការទូតការពារបូរណភាពទឹកដីខ្លួនដោយសន្តិវិធីនិងដោយប្រសិទ្ធភាពដែរ ។

- ឱ! ខ្ញុំពុំដែលដឹងទេ ។

- ហ្នឹងហើយៗ នេះជាកត្តាដែលនាំឱ្យជាតិយើងទាំងពីររាប់អានគ្នាតែបបូរមាត់ខាងក្រៅ ហើយបើគ្មានការកែប្រែទេ អ្វីៗនឹងនៅតែអញ្ចឹង ហើយសន្តិភាពនៅក្នុងតំបន់នឹងមិនមានឡើយ ។ សន្តិភាពនេះហើយ ជាប្រភពនៃសេចក្តីសុខសប្បាយរបស់ប្រជាជនយើង កូនចៅយើងគ្រប់ៗជំនាន់តទៅមុខរៀងទៅ ។

- អញ្ចឹងលោកយល់ថាកំហុស ឬការយល់ខុសទាំងឡាយមានប្រភពច្រើននៅលើបងប្អូនថៃឬ?

- ភាគីខ្មែរក៏មានកំហុសដែរ ។ ប្រជាជនធម្មតាភាគច្រើនឥតកំហុសទេ ។ តែអ្នកខ្លះនិងមន្ត្រីរាជការខ្លះ តោងតែកែប្រែចិត្តលោភៈភ្លេចគិតប្រយោជន៍ជាតិខ្លះទើបបាន ។

វេលាដែលមានប្រសាសន៍ដល់នេះហើយ លោកក៏ក្អកយ៉ាងខ្លាំង ។ ខ្ញុំរីតខ្នងជូនលោកមួយសន្ទុះ ។ នៅពេលដែលលោកបានធូរបន្តិច លោកមើលម៉ោងហើយបន្តថា :

- ថ្ងៃនេះនាងត្រូវទៅសាលារៀន ខ្ញុំសូមឱ្យនាងអភ័យទោសដោយនាំឱ្យនាងអត់ងងុយ ហើយខាតបង់ពេលវេលាដ៏ច្រើនរបស់នាង ។

- ចាំ ទេលោក ។

ខ្ញុំមិនអាចនិយាយអ្វីតទៅទៀតបានទេ នៅពេលដែលខ្ញុំឃើញលោកវិមលប្រកាន់សុជីវធម៌មិចំពោះខ្ញុំខ្លាំងពេក ។ លោកមានទម្លាប់នឹងប្រើពាក្យសម្តីពិរោះពិសារណាស់ ព្រោះលោកមិនដែលមាក់ងាយ ឬគិតថាខ្ញុំក្តីម្តាយខ្ញុំក្តីជាអ្នកមានឋានៈតូច ឬមិនចេះដឹងឡើយ ។ តែយើងបានទៅជាមិត្តដ៏ស្និទ្ធស្នាលនឹងគ្នាហើយទេតើ ហេតុអ្វីបានជាថ្ងៃនេះលោកគួរសមហើយដូចជាខ្លាចចិត្តខ្ញុំខ្លាំងម្ល៉េះ? ខ្ញុំឈ្ងោកមុខមួយសន្ទុះ ។

- ច័ន្ទបុរី! ខ្ញុំមិនដែលជំរាបនាងទេ ពីព្រោះខ្ញុំនៅមានចំណងជាមួយប្រពន្ធខ្ញុំមិនទាន់ដាច់ស្រេចនៅឡើយផង ហើយរូបខ្ញុំនេះមានជម្ងឺប្រចាំកាយមើលមិនជាផង ។ ខ្ញុំសឹងតែភ្លយមាត់ជំរាបនាងច្រើនដងហើយ ...

ខ្ញុំងើយមុខមើលលោក ពីព្រោះខ្ញុំមិនយល់ពិតប្រាកដថាលោកចង់ថាអ្វីទេ ។ តែខ្ញុំអាចដឹងខ្លះៗបានដោយទង្វើនានាថ្មីៗនេះ ដែលខ្ញុំប្រមើលឃើញថា លោកវិមលហាក់ដូចជាឱ្យតម្លៃចម្លែកមកលើខ្ញុំ ជួនកាលទៀតលោកធ្វើមុខស្រងូតហាក់ដូចជាចង់មានប្រសាសន៍រឿងសំខាន់សម្ងៀមណាស់ចំពោះខ្ញុំ ។ តែខ្ញុំបារម្ភណាស់ចំពោះពាក្យលោកដែលថា លោកមានជម្ងឺមើលមិនជា ។ លោកវិមលសម្រូតខ្លួនលោកថ្នមៗចុះពីកៅអី ព្រមទាំងដកអ្វីមួយពីប្រអប់តូចមួយ ដែលខ្ញុំដឹងថា ជាខ្សែដៃនៅពេលក្រោយមក មើលមកខ្ញុំដោយភ្នែកស្រទន់ ប៉ុន្តែប្រកបទៅដោយកម្លាំងចម្លែកមួយ ដែលធ្វើឱ្យខ្ញុំខ្លាចស្ទើរតែសន្លប់បាត់ស្មារតី ។

វេលានោះ ស្រាប់តែស្នូរកណ្តឹងទ្វារលាន់ឡើងហាក់ដូចជាសម្លេងបិសាចកំណាចដែលមកជ្រែកសុភមង្គលរបស់យើងទាំងពីរ ។ ដំបូង ខ្ញុំស្ទុះទៅបើកទ្វារព្រោះនឹកថា ដើម្បីបន្ធាយពេលវេលាឱ្យខ្ញុំអាចរៀបចំចិត្តកុំឱ្យរំជើបរំជួលខ្លាំងពេក ។ វេលានោះ ខ្ញុំមិនមានកូនគំនិតឯណាសូម្បីតែប៉ុនចុងក្រចកសោះ ថាទង្វើនេះជាបុព្វហេតុនាំឱ្យខ្ញុំលែងបានឮសេចក្តីពិត សេចក្តីរាយរាប់ពីអនាគតកាលរបស់យើងជាស្ថាពរសោះឡើយ ។ ពេលនោះខ្ញុំចាំច្បាស់ថា ខ្ញុំឆ្ងល់យ៉ាងខ្លាំងដោយជាពេលព្រលឹមម៉ោង៦ ព្រឹកនៅឡើយទេ តើនរណាគេមានការទាំងព្រឹក

ព្រហាមបែបនេះ។ នារីរូបស្អាតដែលមានសភាពស៊ីវីល័យបានដើរចូលមក លាំង១ ទាំងភាពសង្ហារ។ នាងស្លៀកសំពត់ខើចស ហើយពីលើអាវពណ៌ផ្កាឈូក មានអាវធំពណ៌ក្រហមឆេះ។ នាងចងកូនកន្សែងមួយ នៅក។ លោកវិមល ឡើងភ័ន្តភាំង។

- វ៉ាចានី !

- ចាំ! បងនៅទីកន្លែងសមរម្យទេតើ? ហើយនេះអ្នកបំរើឬ?

ដោយខ្ញុំស្តាប់ ភាសាថៃបានខ្លះៗដែរ ខ្ញុំក៏ខិតខំស្មានថា នេះគឺជាភរិយារបស់លោកវិមលហើយ។ ត្រូវហើយរបៀបស្លៀកពាក់ត្រឹមត្រូវជានារីខ្មែររបស់ខ្ញុំច្បាស់ជាត្រូវនារីស៊ីវីល័យទាំងឡាយនៅក្នុងលោកនេះ យល់ឃើញបែបនេះគ្រប់គ្នាមិនខានឡើយ។ ខ្ញុំពុំដែលខឹងចំពោះការយល់ច្រឡំរបស់មនុស្សឡើយ ផ្ទុយទៅវិញ ខ្ញុំធ្លាប់បានម៉ែឱ្យដំបូន្មានឱ្យចេះគិត ចេះវិនិច្ឆ័យ ចេះអត់ឱនឱ្យអ្នកដែលគ្នាមិនដឹង។ ហើយម្យ៉ាងទៀតជាមួយនឹងការរាប់អានរវាងខ្ញុំនិងលោកវិមល ខ្ញុំក៏បានរៀនសូត្រនូវការសន្តោសអត់ទោសទៅលើមនុស្សជាច្រើនហើយដែរ។ ខ្ញុំធ្វើជាមិនយល់ ហើយប្រុងប្រៀបចាកចេញទៅដោយខ្លាចម៉ែបារម្ភ ផង។ តែលោកវិមលឃាត់ខ្ញុំ ព្រមទាំងនិយាយទៅកាន់អ្នកស្រីវ៉ាចានីថា :

- សូមទោសវ៉ាចានី សូមមេត្តាចាំមួយភ្លែត ។ អ្នកនាងច័ន្ទបុរីជាភ្ញៀវសំខាន់របស់ខ្ញុំណាស់។

រួចហើយលោកបែរមកនិយាយជាភាសាខ្មែរមកកាន់ខ្ញុំថា :

-អ្នកនាង ថ្ងៃនេះខ្ញុំមិនអាចជូននាងទៅទេ តែខ្ញុំនឹងទាក់ទងនាងតាម ទូរស័ព្ទ។ ភរិយាខ្ញុំមកទទួលវីរៈផានទៅបាងកកវិញហើយៗដោយក្តីមេត្តា នាងនឹងព្រមឱ្យខ្ញុំទៅជាមួយដល់បាងកក ទំរាំនឹងបងស្រីខ្ញុំមកយកទៅមន្ទីពេទ្យតែម្តង។

- លោក, លោកឈឺអ្វី? ខ្ញុំបារម្ភណាស់។ លោកឥតបានប្រាប់អ្វីខ្ញុំបន្តិច សោះ។ ក្រែងយើងជាមិត្តដ៏ល្អរវាងគ្នាឬ?

ខ្ញុំមិនអាចទប់ទឹកភ្នែករបស់ខ្ញុំមិនឱ្យធ្លាក់មកទាល់តែសោះ។ ពេលនោះ អ្នកស្រីវ៉ាចានីបានចៀសទៅឈរឯឆ្ងាយពីយើង ដោយការអង្វរពីលោកវិមល។ ខ្ញុំឃើញលោកវិមកខិតខំទប់ទឹកភ្នែករបស់លោក។ ក៏ប៉ុន្តែ លោកពុំអាចទប់សំឡេងរបស់លោកមិនឱ្យញ័របានទេ។

- អូនច័ន្ទបុរីរបស់បង។ បងធ្លាប់ខិតខំទប់ចិត្តកុំឱ្យស្រឡាញ់អូន ពីមួយថ្ងៃទៅមួយថ្ងៃ។ ប៉ុន្តែសេចក្តីស្នេហារបស់បងមិនដែលរលុបឬស្រក ចុះទៅម្តងណាឡើយ។ បងគោរពភាពចាស់ទុំ ការដឹងខុសដឹងត្រូវរបស់អូន។ បងបានទៅពិនិត្យពេទ្យហើយដឹងថាជម្ងឺមហារីកសួតដែលបងបានវះកាត់ពីពីរឆ្នាំមុន បានចាប់ផ្តើមលាប់មកវិញ ហើយបងតោងតែទៅបាងកកដើម្បីព្យាបាល។ ប្រសិនបើទឹកដោះម្តាយថ្លៃ បងមានសំណាងបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ហើយបងស្ថិតនៅក្នុងភាពជាបុរសលីវ តើអូនទទួលបងជាគូស្រកររបស់អូនទេ?

ខ្ញុំរំភើបចិត្តក្រៃលែង រហូតដល់គ្មានពាក្យឯណាឆ្លើយ។ ខ្ញុំបើកទ្វារចេញទៅក្រៅដើរធេងធោង ដោយសុភមង្គលក្នុងចិត្តដ៏ធំធេងដោយបានទទួលការសារភាពនៃសេចក្តីស្នេហាពីបុរសជាទីគោរព ស្នេហារកអ្វីមកប្រៀបប្រដូចពុំបាននេះ។ ទឹកភ្នែកប្រកបដោយក្តីអំណរនិងទុក្ខសោកដ៏ជ្រាលជ្រៅរបស់ខ្ញុំ បានរមៀលចុះមកជាបន្តបន្ទាប់។ ខ្ញុំលើកដៃហៅស៊ីក្លូជិះសំដៅទៅផ្ទះ។ នៅក្នុងចិត្ត ខ្ញុំគិតថា ពីពេលនេះទៅ តើបងវិមលនឹងទៅជាយ៉ាងណា?

ព្រះជាម្ចាស់អើយ សូមលោកមេត្តាជួយសង្ស្រារជាទីស្រឡាញ់របស់ខ្ញុំនេះ ឱ្យឆាប់បានជា ហើយទោះបីជាគេបានវិលទៅជួបប្រសព្វជាមួយនឹងភរិយាគេ វិញ ក៏មិនជាអ្វីដែរ ពីព្រោះខ្ញុំប្រាថ្នាសេចក្ដីសុខ សេចក្ដីសប្បាយរបស់គេ របស់នាងតូចវិរៈផាន។ សេចក្ដីសុខរបស់គេ គឺក្ដីសុខក្នុងចិត្តរបស់ខ្ញុំ។ ខ្ញុំប្រាកដជាគិតបែបនេះ។ ចំពោះរូបខ្ញុំ ដែលពុំទាន់មានចំណងខ្លាំងក្លាជាមួយបងវិមល នៅឡើយ ខ្ញុំអាចលះបង់បាន ហើយនឹងរង់ចាំនូវគូគ្រងដែលនឹងចូលមកដល់នៅវេលាណាមួយ ឬមួយនៅលីវបែបនេះរហូតមួយជីវិតក៏គ្មានបញ្ហាអ្វីដែរ។ ពេលឮខ្ញុំនិយាយបែបនេះ គេស្ដាប់មកឮ ច្បាស់ជាគិតថា ខ្ញុំនិយាយឱ្យឃើញថាតែខ្លួនល្អ។ ប្រសិនបើខ្ញុំមានសេចក្ដីស្នេហាឥតព្រំដែនទៅលើបុរសនេះ ខ្ញុំតោងតែប្រវេប្រវាប្រទាញប្រទង់ឆក់លោកតាមកម្លាំង យកលោកមកដាក់ខាងខ្ញុំ ឱ្យខាងតែបាន ឱ្យខាងតែឈ្នះ។ ប៉ុន្តែ តើនោះអាចហៅថា សេចក្ដីស្នេហាបានដែរឬទេ? នៅពេលដែលខ្ញុំខិតខំរៀនចិត្តសាស្ត្រនៅមហាវិទ្យាល័យគរុកោសល្យ ខ្ញុំបានអានសៀវភៅរបស់ចិត្តវិទូរស្ស៊ីសម្នាក់ឈ្មោះកាលយង់ ដែលបានវិភាគអំពីទឹកចិត្តប្រច័ណ្ឌឬច្រណែនរបស់បុរសស្ត្រីនានា នៅក្នុងលោកនេះ។

គេអាចនិយាយបានដែរថា ទឹកចិត្តច្រណែនប្រច័ណ្ឌនេះកើតច្រើនចំពោះគូស្នេហាភរិយា ឪពុកម្ដាយបងប្អូន មិត្តភក្តិ។ នៅពេលដែលយើងស្រឡាញ់អ្នកណាម្នាក់ យើងតែងតែមានចិត្តចង់នៅជិតអ្នកនោះ តាមតែពេលវេលាអនុញ្ញាតិឱ្យបាន។ រួចហើយ យើងក៏ចង់ឱ្យអ្នកដែលយើងស្រឡាញ់នោះមានចិត្តដូចយើងដែរ។ ហើយប្រសិនបើទឹកចិត្តអ្នកនោះបែរទៅរកអ្នកផ្សេងក្រៅពីយើងទៅវិញ យើងច្បាស់ជាមិនស្ងប់ចិត្តប៉ុន្មានទេ។ យើងនឹងមានកំហឹង មានការក្ដៅក្រហាយ មានការច្រណែនប្រច័ណ្ឌ ហើយសញ្ចេតនាផ្សេងៗទៀតក៏កើតមានឡើងនៅក្នុងចិត្តរបស់យើង ដូចជាខ្យល់គួចមិនអាចឱ្យយើងអត់ឱនដល់ដៃគូបានឡើយ។

ក៏ប៉ុន្តែការច្រណែន ឬប្រច័ណ្ឌខ្លះ ពុំមានទំនាក់ទំនងទាល់តែសោះទៅនឹងសេចក្ដីស្នេហា។ ជួនកាលយើងច្រណែនអ្នកដែលមានរបស់ដែលមានតម្លៃ ឬដែលមានឋានៈបុណ្យសក្តិខ្ពស់ជាងយើង ដែលជាមនុស្សមានសមត្ថភាពដូចឬក៏ពុំខុសអ្វីពីអ្នកនោះផង។ នៅក្នុងកត្តា ឬវេលាដែលគិតថាដូចគ្នានេះ ច្រើនតែមានកំហុស។ ពីព្រោះថា មនុស្សច្រើនតែឱ្យតម្លៃទៅលើខ្លួនឯង ខ្ពស់ជាងសមត្ថភាព ឬអ្វីដែលខ្លួនមាន ជាងការវាយតម្លៃពីក្រៅ។ ហើយនៅពេលដែលយើងយល់ឃើញថា លោកយើងនេះមានតែភាពអយុត្តិធម៌ ហើយពុំខិតខំកសាងខ្លួនឱ្យកាន់តែប្រសើរទេ ទង្វើនេះនាំឱ្យរូបយើងផ្ទាល់នឹងកាន់តែធ្វើដំណើរទៅរកសេចក្ដីពិបាកទាំងផ្លូវកាយ ទាំងផ្លូវចិត្តរហូតដល់នាំឱ្យទៅជាមានជម្ងឺក៏មាន។ បើយើងប្រៀបធៀបកត្តានេះ ទៅនឹងកត្តាដែលថាយើងប្រច័ណ្ឌ ដោយសារតែមានសេចក្ដីស្នេហាទៅលើគូដៃវិញ យើងអាចឃើញថាសញ្ចេតនាច្រណែនប្រច័ណ្ឌនេះ មិនមែនកើតឡើងដោយសារតែយើងមានសេចក្ដីស្នេហាដ៏ជ្រាលជ្រៅទៅលើគូដៃទេ គឺវាគ្រាន់តែជាចំណង់ដែលចង់ "បាន" "ចង់យក" មនុស្សនោះមកធ្វើជារបស់ផ្ទាល់ផ្ដាច់មុខរបស់ខ្លួនតែប៉ុណ្ណោះ។ ពោលគឺ ខ្លួនមិនចង់ឱ្យរបស់ដែលមានតម្លៃនេះ ធ្លាក់ទៅលើដៃបុគ្គលណាផ្សេងនោះតែប៉ុណ្ណោះ។ ខ្ញុំបានចាប់អារម្មណ៍ទៅលើពាក្យរបស់ចិត្តវិទូកាលយង់ ត្រង់កន្លែងដែលលោកបានសរសេរថា "ស្នូលនៃការច្រណែនប្រច័ណ្ឌគឺកង្វះនៃសេចក្ដីស្នេហា"។

## ជំពូកទី៤

ខ្ញុំបានទទួលសំបុត្រពីលោកវិមលមួយពីបាងកកមក។ គឺជាសំបុត្រដ៏ធម្មតា។ ថ្វីបើលោកបានសរសេរថា លោកស្ដាយណាស់ដោយមិនបានជូនខ្សែដៃអនុស្សាវរីយ៍បញ្ចាំចិត្ត ដែលលោកបានបំរុងទុកសំរាប់ខ្ញុំមែន តែក្រៅពីនេះអត្ថន័យរបស់សំបុត្រឥតមាននិយាយពីសញ្ចេតនាបុរស-ស្ត្រីសោះឡើយ។ លោកបាននិយាយពីរឿងទំនាក់ទំនង ពីប្រវត្តិសាស្ត្រខ្មែរ-ថៃ។ លោកបានរំលឹកខ្ញុំពីរឿងប្រាសាទព្រះវិហារដែលជនជាតិថៃនៅតែយល់ច្រឡំមិនអស់មិនហើយ ព្រោះទ្វារចូលប្រាសាទបែរទៅរកថៃ ហើយដោយសារតែប្រទេសយើងទាំងពីរមិនព្រមនិយាយឱ្យច្បាស់លាស់នៅលើលំដាប់ថ្នាក់វិទ្យាសាស្ត្រ ជាបទសិក្ខាសាលា ដោយអ្នកឯកទេសខាងប្រវត្តិសាស្ត្រនិងភូមិវិជ្ជានៃជនជាតិយើងទាំងពីរ។ ទាក់ទងទៅនឹងប្រាសាទនេះ នៅខែមិថុនាឆ្នាំ១៩៦២ តុលាការក្រុងឡាហេ (ហាក) ប្រទេសហុឡង់ដ៏ បានកាត់ក្ដីដោយយោលទៅតាមការងារទូតដ៏ស្ងប់ស្ងាត់ របស់ឯកឧត្ដម ដាកហាម៉ាសូលដ៏ (Dag Hammarskiold) ដែលវេលានោះ លោកជាអគ្គលេខាទូទៅនៃអង្គការសហប្រជាជាតិឱ្យខ្មែរឈ្នះ។ លោកហាម៉ាសូលដ៏ជាជនជាតិស៊ុយអែដ ដែលជាទស្សនវិទូនៃសន្តិភាព ដែលតែងតែគិតអំពីអ្វីទៅដែលហៅថាសណ្ដាប់ធ្នាប់សង្គម។ ប្រសិនបើគេប្រើកងទ័ព ដើម្បីទ្រទ្រង់សណ្ដាប់ធ្នាប់នៅក្នុងសង្គម ដើម្បីកសាង "សន្តិភាព" តើសន្តិភាពអាចនឹងកើតមានឡើងឬទេ? លោកមិនបានឱ្យរុស្សីនិងអាមេរិកចូលពាក់ព័ន្ធក្នុងរឿងនេះទេ ហើយកោះហៅតែសាមីខ្លួនខ្មែរនិងថៃ ឱ្យឡើងតុលាការអន្តរជាតិ ដោយខ្លាចក្រែងវិវាទក្លាយទៅជាធំ រហូតដល់ទៅជាសង្គ្រាម ព្រោះវេលានោះ នៅប្រទល់ដែនខ្មែរថៃ មានការប្រើកម្លាំងទ័ពបន្តិចៗទៅហើយ។ លោកវិមលបានឱ្យខ្ញុំចាប់អារម្មណ៍ទៅលើលោកហាម៉ាសូលដ ទៅលើការចេះប្រើផ្លូវទូត ដើម្បីចៀសវាងសង្គ្រាម ដោយសារយើងជាប្រទេសមានកម្លាំងខ្សោយ។

ខ្ញុំឆ្ងល់ថា ហេតុអ្វីក៏លោកវិមលសង្ឃឹមមកលើខ្ញុំខ្លាំងម្ល៉េះ? លោកសរសេរថា ប្រសិនបើយើងមានសំណាងអាចរៀបការជាស្វាមីភរិយាពេញច្បាប់ យើងទាំងពីរនាក់ ច្បាស់ជាអាចរួមកម្លាំងគ្នា រកប្រយោជន៍ជូនប្រទេសយើងទាំងពីរ ហើយនឹងនាំសន្តិភាពមកជូនទឹតំបន់នេះ តាមសមត្ថភាពរបស់យើងមិនខាន។

សាក្ខីភាពជាច្រើន ដូចជាការពិតនៃប្រវត្តិសាស្ត្រ ពោលគឺនៅឆ្នាំ១០៨០ ថៃជាពូជសាសន៍មួយស្ថិតនៅយូណាន់នៅឡើយទេ ហើយដងភ្នំដងរែកវេលានោះជាតំបន់កណ្ដាលនៃព្រះរាជាណាចក្រកម្ពុជា។ ពិតហើយថៃនិងវៀតណាមតែងតែឆ្លៀតពីជើង ពីកើត ជានិច្ចដើម្បីចៀរដីខ្មែរយកទៅធ្វើដីខ្លួន។ ប៉ុន្តែអ្វីៗសុទ្ធតែត្រូវបានដោះស្រាយទៅតាមច្បាប់អន្តរជាតិទាំងអស់រួចទៅហើយ នៅជំនាន់អាណានិគមក្ដី ជំនាន់ក្រោយមកទៀតហើយក្ដី ចុះហេតុអ្វីបានជាចេះតែមានរឿងហេតុមិនចេះចប់មិនចេះហើយបែបនេះ? យើងគួរគិតដែរ ថាមកពីគេមើលស្រាលមកលើយើងដែលគ្មានអ្វីជាជំហរ។ តើអ្វីទៅជាជំហរនោះ? រំពឹងលើអន្តរាគមន៍អន្តរជាតិឬ? ទេ ,មានតែយើងខ្លួនយើងទេ ដែលជាទីរំពឹងលើខ្លួនយើងនោះ។ កិត្តិយសជាតិ គឺកិត្តិយសយើងជាខ្មែរ បើគេមើលស្រាលលើជាតិយើងៗខ្លួនយើងក៏ពុំមានកិត្តិយស ឬមុខមាត់នឹងដើរលំហែធ្វើឬកខ្ពង់លើដីគេទាំងមិនហ៊ានបញ្ចេញប្រាប់គេថា ខ្លួនមកពីស្រុកណានោះឡើយ។

លោកវិមលបានរៀបរាប់ប្រាប់ខ្ញុំពីជម្ងឺរបស់លោក។ គឺជម្ងឺមហារីកសួត ដែលនាំឱ្យមានការឈឺចាប់ខ្លាំងក្លាណាស់។ លោកពុំដែលនឹកឃើញថា នឹងខិតខំព្យាបាលទេ ពីព្រោះថា ជាតិជាជម្ងឺមហារីកនេះ គ្មានផ្លូវថានឹងបានជាទេ ក្នុងលំដាប់វិទ្យាពេទ្យសម័យនេះ។ ទោះជាខិតខំព្យាបាលក៏បានត្រឹមតែពន្យាជីវិតពីមួយខែ ទៅមួយត្រីមាស ឬមួយឆ្នាំយ៉ាងយូរតែប៉ុណ្ណោះ។ ហើយការពន្យាជីវិត ដោយការព្យាបាលនេះពិបាកនឹងទ្រាំទ្រណាស់។ គេតោងចាក់ថ្នាំទប់ទល់នឹងមហារីក ដែលនាំឱ្យរងាស្ទើររឹងថ្គាម នាំឱ្យជ្រុះសក់ជាដើម។ ប៉ុន្តែឥឡូវនេះលោកព្រមសាកល្បង ក្រែងលោព្រះជាម្ចាស់លោកមេត្តាផ្តល់ជីវិតថ្មីមួយទៀតដោយអច្ឆរិយៈ ដើម្បីបន្តការងារមួយជាមួយនឹងខ្ញុំ។

ខ្ញុំល្ងង់ណាស់ មិនដែលមានចំណេះវិជ្ជាពីជម្ងឺមហារីកនេះឡើយ។ ខ្ញុំបានទិញសៀវភៅវិជ្ជាពេទ្យមកអាន ដើម្បីឱ្យអាចយល់ពីជីវភាពប្រយុទ្ធនឹងជម្ងឺរបស់បងវិមល។

ខ្ញុំបានជំរាបបងវិមលឱ្យផ្ញើររូបថតទាំងឡាយ មកឱ្យខ្ញុំបានឃើញផង ដោយខ្ញុំពុំអាចទៅឃើញផ្ទាល់បាន ហើយខ្ញុំចង់រួមសុខទុក្ខទាំងឡាយជាមួយបងវិមល ចង់យំជាមួយបងវិមល ចង់សើចជាមួយបងវិមល ចង់ចែករំលែកអ្វីៗទាំងពីរនាក់។ ជាដំបូងបងវិមលមិនយល់ព្រមទាល់តែសោះ។ ទឹកចិត្តដ៏ថ្លាឆ្វង់ ដូចស្រះហិមពាន្តធំធេងដូចមហាសាគរ ដែលខ្ញុំធ្លាប់ស្គាល់ របស់បងវិមល រឹតតែនាំឱ្យខ្ញុំខិតខំគិតពីការខំទ្រាំតែឯងរបស់គាត់ ហើយខ្ញុំទៅជាមានទុក្ខសោកយ៉ាងខ្លាំង។ ខ្ញុំបានផ្ញើររូបថតដែលខ្ញុំបានចេញបង្រៀននៅវិទ្យាល័យមួយនៅក្នុងក្រុងដោយខ្ញុំត្រូវបន្តវិជ្ជានៅមហាវិទ្យាល័យអក្សរសាស្ត្រហើយជំរាបគាត់ថា ខ្ញុំបារម្ភពីគាត់ខ្លាំងណាស់ ព្រោះមិនដឹងពីសភាពពិតរបស់គាត់ ហើយខិតខំតែគិត។ បងវិមលបានតបមកខ្ញុំវិញថា ខ្ញុំស្គមច្រើនណាស់ ហើយមិនស្អាតដូចមុនទេ។

ខ្ញុំតោងតែខិតខំញុំាំឱ្យច្រើនទើបល្អ។ ជាមួយនឹងសំបុត្រនោះ គាត់បានផ្ញើររូបថតមួយដែលគាត់បានជ្រុះសក់អស់ ហើយឡើងស្គមស្លក់ស្លេកស្លាំង។ ខ្ញុំបានយំជាខ្លាំងនៅពេលដែលខ្ញុំឃើញរូបថតនោះ។ ទឹកមុខដែលធ្លាប់តែថ្លៃថ្នូរ បានក្លាយទៅជាផតស្គមស្គាំងគួរឱ្យអាណោចអាធម្មក្រៃលែង។ មានរូបមួយទៀតលោកថតជាមួយនឹងនាងតូចវិរៈផានដែលសើចញញឹមយ៉ាងស្រស់ ដោយនាងពុំយល់អ្វីនៅឡើយ ឬមួយក៏នាងស៊ាំនឹងរូបភាពបែបនេះរបស់បិតានាងទៅហើយក៏មិនដឹង។ ហើយរូបនោះ ធ្វើឱ្យខ្ញុំរឹតតែក្តុកក្តួល រំជើបរំជួលក្នុងចិត្ត ជាអនេក។

យើងទាំងពីរនៅឆ្ងាយពីគ្នាមែន តែយើងបានសរសេរសារស័ព្ទនូវទឹកចិត្តរបស់យើងប្រាប់គ្នាទៅវិញទៅមក យើងសរសេរពីអ្វីដែលយើងឃើញ អ្វីដែលយើងឮ ហាក់ដូចជាខ្ញុំកំពុងនៅជិតបងវិមល ហើយបងវិមលក៏កំពុងតែនៅក្បែរខ្ញុំបែបនោះឯង។

នៅវេលាចូលឆ្នាំរោង នាងតូចវិរៈផានបានសរសេរប័ណ្ណជូនពរមួយមកខ្ញុំ។ វេលានោះ នាងបានអាយុ ១0ឆ្នាំហើយ ហើយរៀននៅសាលាអន្តរជាតិ។

នាងសរសេរជាភាសាអង់គ្លេស ព្រមទាំងប្រាប់ខ្ញុំថា នាងនៅចាំចំរៀងខ្មែរដែលខ្ញុំច្រៀងឱ្យនាងស្តាប់ រឿងព្រេងដែលខ្ញុំនិទានឱ្យនាងស្តាប់ តែនាងភ្លេចភាសាខ្មែរអស់ច្រើនណាស់។ នាងចង់មកលេងស្រុកខ្មែរម្តងទៀត។ ប៉ុន្តែច័ន្ទក្រីស្មាឈឺខ្លាំងណាស់ ប្រហែលជាពុំអាចទៅលេងជាមួយនាងបានក្នុងពេលឆាប់ៗនេះទេ ។

ខ្ញុំខំរកនឹកពីអនុស្សាវរីយ៍នានារវាងខ្ញុំនឹងនាងតូចវិរៈផាន។ នាងបានសរសេរនៅក្នុងសំបុត្រនាង ពីរឿងតូចមួយរបស់ជប៉ុន ដែលបកប្រែមកជាភាសាខ្មែរ ដែលខ្ញុំបានទៅខ្ចីពីបណ្ណាល័យនៃអង្គការក្រៅរដ្ឋាភិបាលមួយ ដែលរៀបចំដោយជនជាតិខ្មែរនៅជប៉ុន រួមជាមួយនឹងជនជាតិជប៉ុន។ រឿងនោះ ឈ្មោះរឿងចៅស្ដេក្ដោបនៃព្រៃបូណាបូណា។ នៅពេលដែលខ្ញុំអានដល់ត្រង់កន្លែងដែលសត្វដង្កូវនិងសត្វព្រៃទាំងឡាយ ដែលរងគ្រោះដោយសារខ្យល់ព្យុះសង្ឃរា ទៅសុំចែកស្លឹកស្ដេពីស្ដេក្ដោប វេលានោះស្ដេក្ដោបនិយាយថា : "បើរូបខ្ញុំនេះអាចជួយស្រោចស្រង់បងបាន ខ្ញុំត្រេកអរ នឹងជួយណាស់ "។

ថាហើយ ស្ដេក្ដោបក៏បកស្លឹករបស់ខ្លួនមួយសន្លឹកហុចឱ្យទៅដង្កូវ។ ដង្កូវបានថ្លែងអំណរគុណច្រើនដងចំពោះស្ដេក្ដោប មុននឹងត្រឡប់ទៅផ្ទះវិញ។ ស្ដេក្ដោបក៏ត្រេកអរខ្លាំងណាស់ដែរ ដោយឃើញដង្កូវសប្បាយចិត្តនឹងអំណោយរបស់ខ្លួនបែបនេះ។ វេលានោះ លោកវិមលដែលលបចោលភ្នែកមកយើងទាំងពីរយូរហើយ បានដើរមកជិតយើងហើយនិយាយថា :

- សៀវភៅនេះមានអត្ថន័យល្អណាស់។ ដង្កូវរងគ្រោះដោយសារខ្យល់ព្យុះសង្ឃរា ស្ដេក្ដោបសប្បាយចិត្តនឹងជួយដង្កូវ ដង្កូវដឹងគុណស្ដេក្ដោប ថ្លែងអំណរគុណច្រើនដងចំពោះស្ដេក្ដោប ៗក៏សប្បាយចិត្ត។ ផ្ទុយទៅវិញ នៅពេលដែលដង្កូវមកសុំស្លឹកស្ដេក្ដោប ហើយស្ដេក្ដោបដេញដង្កូវ ឬមើលងាយដង្កូវថាសត្វសុំទាន មានដៃមានជើងនឹងគេដែរ ម្ដេចក៏រហេមរហាម ឬក៏មាក់ងាយដោយវិធីណាមួយ លោកយើងនេះពុំអាចហៅថា "ស្ថានមនុស្ស" បានឡើយ។ ស្រុកកាន់ព្រះពុទ្ធសាសនាដូចស្រុកថៃ ស្រុកខ្មែរ តោងតែសម្បូណ៌ទៅដោយមនុស្សបែបស្ដេក្ដោបនេះ ទើបអាចហៅថា "ប្រជារាស្ត្រដែលមានស្នាមញញឹម ប្រកបទៅដោយជំនឿ" ពិតប្រាកដមែន។

ខ្ញុំបានយល់ទាំងអស់ នូវអ្វីដែលលោកចង់មានប្រសាសន៍។ លោកវិមលចង់អប់រំនាងវិរៈផាន។ មនុស្សគ្មានការត្រិះរិះ តែងតែមើលងាយគេ ដោយគិតថាការដែលគេមកពឹងពាក់ខ្លួន គឺដោយសារតែខ្លួនមាន ខ្លួនខ្ពង់ខ្ពស់ជាងដៃគូ ហើយខ្លួនក៏ចាប់ឡើតចាប់មើលងាយគេ ហើយយល់ច្រឡំថា ដៃគូតូចទាប។ ខ្ពង់ខ្ពស់ឬមិនខ្ពង់ខ្ពស់ គឺពាក្យសម្ដី និងកាយវិការរបស់ខ្លួនចំពោះដៃគូឯនោះ ទេ។ ជនជាតិដែលមានវឌ្ឍនធម៌ ដែលប្រកបទៅដោយអារីយធម៌ និងពុទ្ធិមិនមែនសំដៅលើប្រទេសដែលអ្នកនោះនៅ ចេះធ្វើរថ គ្រឿងចក្រ ឬលូតលាស់ខាងបច្ចេកទេសទេ គឺភារៈប្រកបទៅដោយមេត្តាធម៌ មនុស្សធម៌ នៃជននោះទេ ដែលគេឱ្យតម្លៃ។ ជាការពិតណាស់ អ្នកដែលបានធ្វើរបកគំហើញវិទ្យាសាស្ត្រ ឬវិជ្ជាពេទ្យជាដើម ដែលជាគុណប្រយោជន៍សំរាប់មនុស្សជាតិក៏តោងតែត្រូវទទួលការលើទឹកចិត្ត ឱ្យកាន់តែខិតខំស្រាវជ្រាវតទៅទៀតដែរ ពីព្រោះគឺជាការបរិច្ចាគដ៏ធំទូលាយរបស់អ្នកនោះ ចំពោះមនុស្សជាតិទាំងមូល។

លោកវិមលបានសរសេរមកឱ្យខ្ញុំរៀបរាប់ជំរាបលោក ពីទិដ្ឋភាពនានានៅជិតការិយាល័យ អ៊ុយណេស្កូ ពីទេសភាពនានានៅតាមផ្លូវទៅកំពង់សោម ដែលលោកស្រឡាញ់ពេញចិត្ត ព្រមទាំងទេសភាពតំបន់អង្គរដែលមានរហាត់ទឹក។

ខ្ញុំខិតខំរំលឹកពីទីកន្លែងដែលយើងឧស្សាហ៍ដើរកំសាន្តជាមួយគ្នា។ យើងច្រើននាំគ្នាដើរកំសាន្ត ឬជិះកាណូត តាមទន្លេធំ (ទន្លេមេគង្គ) ទៅបាក់ខែងដើម្បីឱ្យបានឃើញទេសភាពនិងជីវភាពប្រជាជន ដែលលោកវិមលសប្បាយនឹងឃើញ។ នៅរដូវទឹកឡើងវេលាមេឃស្រទំ ខ្យល់ទន្លេបក់មកធ្វើឱ្យយើងរងារ

សឹងតែទ្រាំមិនបាន។ លោកវិមលថតទូកនេសាទ ថតអ្នកនេសាទដ៏ច្រើនដែលកំពុងតែវាយសំណាញ់ដ៏ធំជាមួយគ្នា ពីទូកដែលចតនៅក្បែរច្រាំង។ បន្ទាប់មកគេនាំគ្នាចុះទៅក្នុងទឹក រង់ចាំឱ្យត្រីចូលសំណាញ់នឹងអាលគេនឹងទាញវា ប្រមូលវា។ នៅឯច្រាំងឯនោះ កុមារតូចស្គមម្នាក់ ប្រទាញប្រទង់អូសគោ ស១ពីរចុះពីលើមកតាមជំរាលចោតដៃមានកាន់រំពាត់។ លោកវិមលខំតម្រង់ប្រដាប់ ថតប្រើកែវយឺតទាញឱ្យអាចថតកុមារបាន។ លោកគ្រូវិក្បាលបណ្ដើរ និយាយរាងដូចជាសរសើរហួសពីការស្មានថា :

- ឱ! ចុះកូនក្មេងនេះក៏មានឋាមពលម្ល៉េះ? ខ្ញុំបណ្ដើរតែឆ្ពតូចមួយដើរលេងក៏ហាត់ គឃ្លូរ ចុះទំរាំតែក្មេងនេះ ដែលដឹកនាំគោដល់ទៅពីរធំ១បែបនេះ។

ខ្ញុំស្ដាប់លោកមានប្រសាសន៍មិនស្រដីអ្វីទេ។ លោកវិមលស្រឡាញ់ទេសភាពនៅវេលាព្រះអាទិត្យរះ ស្រឡាញ់វេលាដែលព្រះអាទិត្យហៀបអស្ដង្គត ហើយលោកតែងតែគន់មើលទិដ្ឋភាពដ៏ស្រងេះស្រងោច ព្រមទាំងញញឹមនៅពេលដែលលោកឃើញកុមារ ឬកសិករទាំងឡាយងូតទឹកជាមួយ ហើយដុសខ្លួនឱ្យសត្វចតុបាទរបស់ខ្លួន ហើយលោកតែងតែពោលប្រាប់នាងវិរៈផានថា "កូនមើល គេស្រឡាញ់សត្វគេ ដូចឪពុកស្រឡាញ់កូនអញ្ចឹង។ តើកូនគិតថាណាមួយជាឪពុក ណាមួយជាកូន?" នាងវិរៈផានឆ្លើយថា "ក្របីជាឪពុកនាង ហើយនាងជាមនុស្សដែលកំពុងតែដុសលាងសត្វនោះ"។ លោកគ្រូវិក្បាលហួសចិត្ត សើចមករកខ្ញុំ។

ទន្លេមេគង្គជាទន្លេដែលពោរពេញទៅដោយភាពក្សេមក្សាន្ត។ យើងគ្រាន់តែអង្គុយលើកៅអីថ្មមើល ក៏អាចឃើញនូវនាដកម្មទាំងឡាយដូចជា គេកំពុងតែអង្គុយទស្សនាល្ខោន ដែលតុបតែងឆាកដោយសិល្បករ ប្រកបទៅដោយទេពកោសល្យអស្ចារ្យណាម្នាក់។ វេលាដែលមេឃស្រទំ មានពពកក្រាស់ ឱបក្រសោបជើងមេឃ ដែលមានពណ៌លឿងចម្លែក ផ្ទៃទន្លេទាំងមូលក៏ហាក់ដូចជាមានពណ៌ប្រាក់បន្តិច ប្រផេះបន្តិច ខៀវព្រលៃតបន្តិច មើលទៅនាំឱ្យអារម្មណ៍នឹករឭកស្រុកកំណើតចំឡែក។

ទេសភាពមួយទៀត ដែលលោកវិមលស្រឡាញ់អស្ចារ្យមួយដែរគឺ ទេសភាពដែលមានរហាត់ទឹក វិលយឺត១នៅតំបន់អង្គរ។ រហាត់ទឹកដ៏ធំ វិលនៅក្រោមស្លឹកឈើស្លឹកព្រៃបៃតងខ្ចី ដែលលាងសំអាតដោយទឹកភ្លៀង ដែលទើបនឹងរាំង។ ព្រះសុរិយាទំលាក់រស្មីដ៏ស្រទន់ពីលើ ត្រូវនឹងខ្យល់ដែលផាត់ល្ហៀក១។ ពេលវេលានៅទីនេះ រំកិលខ្លួនថ្នម១ ឥតបង្ហំប្រកបទៅដោយសេចក្ដីស្ងប់ស្ងាត់ក្សេមក្សាន្តគ្មានទីបញ្ចប់។

វាលស្រែខ្មែរនៅរដូវស្ទូងមានទឹកពេញព្រៀប មានសន្ទូងពណ៌ខៀវ ស្រងាត់ដុះចេញពីទឹកថ្លាឆ្វង់។ ទីខ្លះដែលមិនទាន់ស្ទូងរួច គេឃើញកសិករស្វាមីភរិយាដែលចងក្រមានៅក្បាល ឱនងើប១ ដោតសន្ទូង។

ឯកុមារ១វិញ នៅពេលដែលគេចេញពីរៀន ឬក៏ជួយធ្វើការងារម្ដាយឪពុកគេរួចហើយ គេតែងតែនាំគ្នាទៅងូតទឹកហក់ពីលើដៃស្ពានទៅក្នុងស្ទឹង ដាំទិងជ្រមុជលេង ដេញគ្នាឥតមានកង្វល់អ្វីឡើយ។

ខ្ញុំមិនដែលគិតថា ការរៀបរាប់ពីទេសភាពក្ដី ការរៀបរាប់ពីទិដ្ឋភាពជុំវិញទីកន្លែងធ្វើការរបស់លោកក្ដី ការថតរូបផ្ញើរទៅលោកក្ដី ជាការលំបាកដល់ម្ដងណាឡើយ។ ផ្ទុយទៅវិញ នៅពេលចេញពីធ្វើការក្ដី ពេលចេញពីរៀនក្ដី ជួនកាលខ្ញុំទាញម៉ែខ្ញុំដែលទើបនឹងលក់បង្អែមអស់ ឱ្យទៅដើរលេងមាត់ទន្លេម្ដុំកន្លែងដែលលោកវិមលធ្វើការ ថតរូបម៉ែផ្ញើរទៅលោកក៏មាន ផ្ញើររូបដែល

មានផ្កាក្ងោកនៅពីក្រោយក៏មាន ផ្ញើររូបនៅទីដែលខ្ញុំធ្លាប់ថតជាមួយនាងវិរៈផាននៅមាត់ត្រពាំងទឹក ដែលមានផ្កាព្រលិតពណ៌ផ្កាឈូកដិត រីកស្គុះស្គាយលាយឡំទៅដោយផ្កាស្មោរពណ៌លឿង និងផ្កាត្រកួនស្វាយដោយអន្លើក៏មាន។

ទោះបីទីកន្លែងនោះ ជាទីកន្លែងតែមួយក្តី យោលទៅតាមរដូវ ដែលយើងមិនសូវជាចាប់អារម្មណ៍ពីវត្តមាន បរិយាកាសនៃទីកន្លែងនោះ ផ្លាស់ប្តូរផ្សេងគ្នាទាំងអស់។

ប៉ុន្តែជាធម្មតា យើងពុំសូវចាប់អារម្មណ៍ ឬយកចិត្តទុកដាក់សង្កេតទេ ដូច្នេះហើយទើបបានជាយើងពុំអាចធ្វើរបកគំហើញនោះឃើញឡើយ។

លោកវិមលតែងតែពិនិត្យពិច័យរូបថតនីមួយៗ ដែលខ្ញុំផ្ញើរទៅជូនលោក ហើយសរសេរផ្ញើរតបមកវិញជានិច្ចថា រដូវនេះព្រះអាទិត្យមានពន្លឺខ្លាំងក្លា ណាស់ ឬមួយក៏ រូបថតដែលថតនៅព្រះលានវាលមេរុនៅថ្ងៃនេះខែនេះ មើលទៅឃើញដូចជាស្រងេះស្រងោចណាស់ ជាដើម។

គ្មានហេតុផលអ្វីផ្សេងទេ គឺលោកវិមលមិនអាចចេញពីបន្ទប់ជម្ងឺរបស់លោកតែប៉ុណ្ណោះ។

ម្ល៉ោះហើយ លោកសប្បាយនឹងមើលរូបថត ដើម្បីស្រង់ញាណារម្មណ៍ពិតប្រាកដពីរូបនោះ។ លោកបានសរសេរអរគុណខ្ញុំ នៅគ្រប់ពេលដែលលោកបានទទួលសំបុត្រនិងរូបថតពីខ្ញុំ។ លោកសរសេរថា ក្នុងនាមជាមន្ត្រីនៃ អ៊ុយណេស្កូ ដែលមានភារកិច្ចរៀបចំកម្មវិធីនៃការសិក្សាអប់រំរបស់ប្រទេសកម្ពុជា លោកស្រឡាញ់ទេសភាពប្រទេសនេះណាស់។ គឺជាទេសភាពដែលប្រទេសជាច្រើននៅក្នុងពិភពលោកបានបាត់បង់។ លោកតែងតែមានអារម្មណ៍រលឹកស្រុកទេសជាពន់ពេក នៅពេលដែលលោកឃើញទេសភាពទាំងនេះ។ ហើយលោកអង្វរខ្ញុំកុំឱ្យខ្ញុំយល់ច្រឡំខុស ថាជាទឹកចិត្តដែលហួងហែងចង់បានប្រទេសកម្ពុជា មកធ្វើជាកម្មសិទ្ធថៃឱ្យសោះ ព្រោះលោកមិនយល់ច្រឡំខុសដូចជនជាតិថៃខ្លះ ដែលមិនចេះប្រវត្តិសាស្ត្រ ហើយជឿតាមប្រវត្តិវិទូរថៃដែលសរសេរប្រាសចាកការពិតថា ជនជាតិដែលរស់លើដីកម្ពុជាសព្វថ្ងៃ សុទ្ធតែជាថៃ ឬក៏គិតថា ដែនដីនេះថៃធ្លាប់កាន់កាប់ក្រោមឱវាតខ្លួនជាដើម ដែលសុទ្ធសឹងតែជាគំនិតចង្អៀតចង្អល់ប្រាសចាកគុណធម៌។ ពិភពលោកសព្វថ្ងៃនេះ ចូលទៅដល់សម័យមួយ ដែលមនុស្សតោងតែគិតសាកល។ ពិភពអឺរុបគេបង្កើតសហគមន៍អឺរុប យោលទៅលើគំនិតរស់ជាមួយគ្នា តែអាស៊ីនៅចង្អៀតចង្អល់ណាស់។ ប្រទេសធំជាងគេបន្តិច ចាប់ផ្តើមតែពីចង់ត្រួត តែចង់ធំ គិតតែថាពូជសាសន៍ខ្លួនគ្រាន់។

គឺជាគំនិតដែលគួរឱ្យលះបង់ណាស់។ លោកធ្វើការនៅក្នុងអង្គការអន្តរជាតិបែបនេះ លោកតែងតែចង់ឱ្យអាស៊ី មានអ្នកដឹកនាំដែលមានខួរក្បាលជឿនលឿន។

សង្ឃឹមឱ្យថៃ ឱ្យវៀតណាម ចោលគំនិតចង្អៀតចង្អល់របស់គេ ក៏ពិបាកសង្ឃឹម។

ដោយខ្ញុំជានិស្សិតដែលរៀនខាងប្រវត្តិសាស្ត្រនិងភូមិសាស្ត្រ ខ្ញុំខិតខំអានសៀវភៅ ដំណើរឆ្ពោះទៅទិសខាងលិច ជាដើមរបស់សាស្ត្រាចារ្យនួនឃឿន ដើម្បីឱ្យអាចយល់ពីរឿងជម្លោះឥតឈប់ឈររវាងសៀម-យួន និងខ្មែរនេះ។ បញ្ហាគឺ ហាក់ដូចជាក្លាយទៅជា "ធម្មជាតិ" មួយបាត់ទៅហើយ ចំពោះការជម្រុលពីក្រៅដូចជាទឹកជំនន់នេះ។ ទោះបីជានៅក្នុងចំណោមប្រជាជនយួនឬសៀមទាំងឡាយមានមនុស្សល្អតួយ៉ាងលោកវិមលក៏ដោយ។ ហេតុអ្វីបានជាអាចថាដូច្នេះកើត? លោកនួនឃឿនបានសរសេរវិភាគថា បុព្វហេតុគឺមកពី

ដោយសារតែឋាមពលនៃជនជាតិរបស់ប្រទេសជិតខាងយើងទាំងនេះផង ដោយសារតែការវិវឌ្ឍន៍នៃបណ្ដាជនរបស់គេឆាប់ផង និងកង្វះខាតនៃដែនដីដែលមានជីវជាតិ សំរាប់ចិញ្ចឹមបណ្ដាជនដែលកើននោះផង។ បើគិតពីកត្តាដ៏សែនធម្មជាតិទាំងនេះ អ្វីដែលខ្មែរយើងតោងតែមានគឺ កត្តាមនុស្សផង ពង្រីកកម្លាំងសេដ្ឋកិច្ចដែលយើងត្រូវតែសង្កត់ធ្ងន់ទៅលើគឺកសិកម្មនេះឯងតែម្ដងផង។ ព្រោះយើងមានដីល្បប់នៃទន្លេមេគង្គ ទឹកដ៏បរិបូណ៌ និងកំដៅព្រះអាទិត្យ ដែលជាធនធានធម្មជាតិ។ សាស្ត្រាចារ្យនួនឃឿនបានប្រាថ្នាឱ្យមានការអប់រំកសិករខ្មែរទៅតាមបច្ចេកទេសនិងវិទ្យាសាស្ត្រទំនើប។ លោកព្រមទាំងបានសង្កត់ទៀតថាកត្តាមួយទៀតសំខាន់របស់ខ្មែរយើង គឺការប្ដេជ្ញាចិត្តទាំងស្រុង ឬក៏ "ឆន្ទះដែលប្រៀបបាននឹងដែកថែប" គិតប្រយោជន៍ជាតិ។

មែនហើយ អតីតកាល គឺអតីតកាល ទោះជាយើងចាត់ទុកសាសន៍ ទាំងពីរថាជាសត្រូវសួពូជរបស់យើង ក៏គ្មានអ្វីភ្លឺស្វាងអាចកើតមានឡើងដែរ។ អញ្ចឹងបានជាចេះ តែសង្ឃឹមឱ្យខ្មែរឆាប់ខ្លាំង។ មិនមែនឱ្យខ្លាំងខាងទ័ព ខាងតិចនិច ឬខាងវិទ្យាសាស្ត្រទេ គឺខាងកសិកម្ម ទស្សនវិជ្ជា អហឹង្សា ថែរក្សាសម្បត្តិធម្មជាតិដូចជាព្រៃព្រឹក្សាទន្លេបឹងបួរជាដើម ដែលជាធនធានធម្មជាតិសំរាប់សេដ្ឋកិច្ចយើង។

លោកវិមលតែងតែសរសើរពីម៉ែខ្ញុំ ដែលបានប្រៀនប្រដៅខ្ញុំឱ្យមានចារិតនិងចរិយាបានបទ។

ខ្ញុំមិនយល់ថា ខ្ញុំមានចារិតអ្វីជាពិសេស រហូតដល់លោកសរសើរខ្ញុំកប់ពពកបែបនេះទេ។ ប៉ុន្តែខ្ញុំហាក់ដូចជាអាចយល់បានពីទឹកចិត្តបំណងនេះ។ បើប្រទេសនៅតំបន់អាស៊ី មានកម្លាំងម្យ៉ាងៗទៅតាមថ្នាលរបស់ខ្លួន ការគោរពគ្នាទៅវិញទៅមកក៏កើតមានឡើង យើងទាំងអស់គ្នានឹងអាចឡើងចុះប្រទេសទៅវិញទៅមក នៅពេលដែលយើងចង់ ហើយពុំចាំបាច់អ្វីនឹងចង់ឱបក្រសោបទឹកដីទាំងអស់មកដាក់ក្រោមឱវាតរបស់ខ្លួនឡើយ។ ជនជាតិ ពូជសាសន៍ទាំងឡាយរស់ដោយសុខក្សេមក្សាន្ត រៀនភាសាខ្លួន និយាយភាសាខ្លួន នរណាចង់នៅទីណាទៅនៅទីនោះ អ្នកណាចង់រៀនភាសាអ្វីរៀននោះ គ្មានប្រយោជន៍ ឬក្ដីសប្បាយអ្វីនឹងឃើញពូជសាសន៍ផ្សេង រៀនភាសាខ្លួន ឬស្លៀកពាក់សំពត់អាវខ្លួនទាំងបង្ខំចិត្តនោះឡើយ។

លុះដល់វេលានេះទើប ខ្ញុំហាក់ដូចជាមានអារម្មណ៍ទទួលកំហុសយ៉ាងធ្ងន់ ដោយខ្ញុំពុំបានខិតខំរកលុយធ្វើដំណើរទៅសាកសួរលោក នៅទីបញ្ចប់របស់លោក។

នៅវេលាដែលផ្កាក្ងោករីកពេញពាសតាមដងវិថីសហភាពសូវៀត ដែលនៅមុខសាកលវិទ្យាល័យអក្សរសាស្ត្រដែលខ្ញុំទៅរៀនមួយអាទិត្យបីដង ដូចកាលដែលខ្ញុំធ្លាប់ចំណាយពេលទៅបង្រៀននាងតូចវិរៈផានដែរ ខ្ញុំបានទទួលសំបុត្រប្រញាប់មួយពីនាងតូចនេះដ៏វែងរៀបរាប់ពីឪពុករបស់នាង ដែលបានទទួលមរណភាព ដោយសារជម្ងឺមហារីកសួតដំណាក់កាលចុងក្រោយនៅអាទិត្យមុននេះទៅហើយ។ មហារីកសួតដ៏សាហាវ បានទាំងធ្វើឱ្យលោកវិមលបញ្ចេញសម្លេងលែងបាន នៅវេលាចុងបញ្ចប់របស់លោក។ ដូច្នេះលោកឥតអាចផ្ដាំផ្ញើអ្វីដល់នាងតូច ជាបុត្រីជាទីស្រឡាញ់ពេញចិត្តនេះបានឡើយ។

នាងតូចបានរៀបរាប់ថា លោកឪពុករបស់នាងបានស្លាប់ទៅប្រកបដោយទឹកមុខស្ងប់ស្ងាត់ណាស់។ មុននឹងលោកចេញដំណើរដ៏វែងឆ្ងាយទៅនេះ លោកបានយករូបថតទាំងឡាយដែលខ្ញុំផ្ញើរទៅលោក មកមើលហើយមើលទៀត រហូត

ដល់លោកផុតដង្ហើម។ លោកបានផ្ញើរបស់មួយទុកឱ្យនាងវិរៈផានកាន់មកឱ្យខ្ញុំផ្ទាល់ដៃ នៅវេលាដែលនាងមានលទ្ធភាពនឹងធ្វើដំណើរមកកាន់ប្រទេសកម្ពុជានៅវេលាណាមួយ។ រហូតទៅដល់ពេលនោះ នាងតូចមិនហ៊ានបើកកញ្ចប់នោះឡើយ។ នាងរក្សាវាដោយប្រិតប្រៀន ទុកលើអសនៈដែលនាងតំកល់រូបថតបិតានាងនៅផ្ទះដែលនាងរស់នៅជាមួយម្តាយរបស់នាង ឯជាយទីក្រុង។

ខ្ញុំចាំបានថា នៅពេលដែលអានសំបុត្រនោះ ខ្ញុំបានបង្ហូរទឹកភ្នែកយ៉ាង ច្រើន។ ខ្ញុំពុំអាចភ្ជង់អារម្មណ៏ទៅលើអ្វីមួយបានទាំងអស់។ ខ្ញុំទៅជាតុក្កតាដែលមានតែរូបរាង ប៉ុន្តែពុំមានព្រលឹងនៅក្នុងខ្លួន។ ខ្ញុំអាចដឹងតែនៅពេលដែលពេលវេលាបានកន្លងទៅប្រហែលជាមួយឆ្នាំ ពីទឹកចិត្តរបស់នាងបដាចារដែលក្លាយទៅជាវិកលចារឹត នៅពេលដែលមនុស្សជាទីស្នេហារបស់នាងទាំងឡាយបានបាត់បង់អស់ជាបន្តបន្ទាប់។

ម៉ែខ្ញុំបានពិបាកចិត្តនឹងខ្ញុំក្រៃលែង។ ម៉ែអង្គុយស្តាប់ការពណ៌នារបស់ខ្ញុំពីលោកវិមល ឥតមានធុញទ្រាន់។ ម៉ែឱបខ្ញុំ នៅពេលដែលខ្ញុំបង្ហូរទឹកភ្នែក។

ជីវភាពបែបនេះប្រព្រឹត្តទៅជាងដប់ខែ។ ខ្ញុំបានអរគុណម៉ែយ៉ាងខ្លាំងនៅថ្ងៃមួយដែលខ្ញុំបើកប្រាក់ខែ។ ម៉ែក្រសោបខ្ញុំព្រមទាំងនិយាយថា :

- កូនឯងនិយាយអ្វីផ្តេសផ្តាសអញ្ចឹង? កូនជាកូនតែមួយជាទីស្រឡាញ់ ជាទីពេញចិត្តនិងមានតម្លៃលើសអ្វីៗទាំងអស់របស់ម៉ែ។

ខ្ញុំបានប្រាប់ម៉ែថា មនុស្សខ្លះគេមិនស្រឡាញ់កូនអ្នកក្រៅដូចម៉ែអញ្ចឹងទេ។ ខ្ញុំមានសំណាងខ្លាំងណាស់ ដោយបានជួបនឹងមនុស្សដែលមានចិត្តធម៌សប្បុរសដូចម៉ែ។ ម៉ែបានឆ្លើយថា ម៉ែធ្លាប់ជាមនុស្សតែលតោល ជ្រកកោនជាអ្នកបំរើឪពុកម្តាយខ្ញុំពីដើម។ ម៉ែបានបីបមថ្នាក់ថ្នមខ្ញុំ បានខិតខំរស់ដោយសារតែមានវត្តមានខ្ញុំ ដែលរំពឹងលើម៉ែគ្រប់សព្វ។ សេចក្តីស្នេហារបស់ខ្ញុំចំពោះម៉ែ សេចក្តីត្រូវការម៉ែ ខានមិនបានរបស់ខ្ញុំ ជាកំឡាំងសំរាប់ឱ្យម៉ែសប្បាយនឹងរស់នៅ។ ម៉ែមិនដែលគិតថា ខ្ញុំជាអ្នករុកកួនម៉ែដល់ម្តងណាទេ ផ្ទុយទៅវិញ ម៉ែអរគុណខ្ញុំដោយខ្ញុំខិតខំស្រឡាញ់ម៉ែ រស់នៅជាមួយម៉ែ ផ្តល់សេចក្តីសង្ឃឹម នឹងទឹកដមដល់ជីវិតដ៏ដដែលៗ របស់ម៉ែ។ ខ្ញុំឱបម៉ែ ប្រាប់ម៉ែថា អស់ពីលោកវិមលទៅខ្ញុំមានតែម៉ែម្នាក់ទេ ដែលជាទីរំពឹង ជាបង្អែកនៃដួងចិត្តបន្តទៅមុខទៀត។

ម៉ែបានងក់ក្បាល ហើយអង្អែលក្បាលខ្ញុំ ដោយសេចក្តីមេត្តាក្រៃលែង។

ខ្ញុំនឹកលោកវិមល រឭកពាក្យសម្តីដ៏ពិរោះចុងក្រោយរបស់លោក ដែលថាលោកស្រឡាញ់ខ្ញុំ និងប្រាថ្នាសន្តិភាពនៅតំបន់ដែលយើងរស់នៅ។

នៅក្នុងសំបុត្រដែលយើងឆ្លើយឆ្លងគ្នាជាញឹកញាប់ យើងបានបើកទ្រូងរបស់យើងម្នាក់ៗប្រាប់គ្នាហើយៗខ្ញុំចាំសម្តីលោកជានិច្ច ដែលមានបំណងយ៉ាងខ្ជាប់ខ្ជួនថា ចំពោះប្រទេសកម្ពុជា មានតែទស្សនវិជ្ជា និងភាពថ្លៃថ្នូរ ចាស់ទុំចារឹតស្លូតបូតអហឹង្សាទេ ដែលអាចឱ្យយើងទាក់ទាញមនុស្សម្នា ភ្ញៀវបរទេសឱ្យមកទស្សនាប្រទេសយើងជួបជាមួយនឹងធម្មជាតិ ដែលល្អស្ងប់ស្ងាត់ និងប្រាសាទបុរាណដ៏ច្រើន។

អង្គរវត្ត និងប្រាសាទដទៃទៀត ជាប្រាសាទដែលសាងសង់ឡើងដោយជនជាតិខ្មែរ ដែលបានរៀនជាទ្រឹស្តីអរូបីពីឥណ្ឌាហើយប្រើរូបារម្មណ៏របស់ខ្លួន សាងសង់ជាវត្ថុមានរូប ដែលនៅប្រទេសឥណ្ឌាគេមិនអាចរកឃើញប្រាសាទបែបទស្សនវិជ្ជាសំបើមដូច្នេះបានឡើយ។ គួរយើងសាកល្បងគិតមើល គ្រូយើងផ្តល់មេរៀនមកយើងមែន ប៉ុន្តែបើកិរិតវប្បធម៌នៃយើងជាសិស្សទាប តើយើងអាចស្តាប់មេរៀនដែលជាទស្សនៈជាទ្រឹស្តីយល់ទេ? មិនត្រឹមតែយល់ទេ ខ្មែរថែម

ទាំងគិតឃើញដល់ទៅសាងសង់ជាប្រាសាទដែលយើងអាច ហៅថារូបហើយ យើងអាចស្រមៃបានថា នៅជំនាន់នោះនរណាក៏អាចយល់ពីន័យពីខ្លឹមសារដែលប្រាសាទនីមួយៗចង់បរិយាយប្រាប់មិនលែងឡើយ។ ព្រោះនៅជំនាន់នោះ ខ្មែរមានទាំងគម្ពីរវេទជាភាសាខ្មែរ និងគម្ពីក្បួនខ្នាតឯទៀតជាច្រើនរាប់មិនអស់ ហើយការពិតជាក់ស្តែងគម្ពីរវេទរបស់ខ្មែរមានរក្សាទុក នៅប្រទេសបារាំងផង។ ខ្មែរគួរកុំមើលស្រាលចំពោះរបស់ទាំងអស់នេះ ហើយគួរតែមានអ្នកឯកទេសដែលសិក្សាស្រាវជ្រាវក្នុងផ្ទាលទាំងនេះ ហើយទាក់ទាញនិស្សិតនានាពីបរទេសឱ្យមករៀនប្រទេសខ្មែរផ្តួបផ្សំជាមួយ នឹងប្រាសាទអង្គរទាំងឡាយ ពោលគឺយើងមានទាំងទ្រឹស្តី ទាំងរូបភាពពិតឱ្យគេឃើញ។ ខាងផ្នែកព្រះពុទ្ធសាសនា ក៏បែបនោះក្នុងចំណោមប្រទេសទាំងឡាយ ប្រទេសកម្ពុជាសម្បូណ៌ទៅដោយព្រះសង្ឃ ដែលបួសបានយូររៀនធមិអាចិបានជ្រៅជ្រះច្រើនណាស់។ នេះជាមោទនភាពមួយ ដែលយើងជាខ្មែរពុំសូវបានចាប់អារម្មណ៍។ យើងមិនបាច់ប្រឡងប្រជែងជាមួយប្រទេសជិតខាងនៅលើវិស័យបច្ចេកទេស ឬឧស្សាហកម្មទេ គិតពីកសិកម្មនិងប្រមូលភ្ញៀវទេសចរណ៍ ដោយឃោសនា ឱ្យបានច្រើនពីអង្គរវត្ត ផ្តួបផ្សំនឹងសេចក្តីមេត្តា សេចក្តីសន្តោស ពោលគឺ ទស្សនវិជ្ជានៃព្រហ្មវិហារធមិរបស់សម្តេចជ័យវរ្ម័នទី៧ ផ្សព្វផ្សាយឱ្យពិភពលោកកាន់តែបានដឹងឮព្រោងព្រាតថែមទៀត ព្រមទាំងបង្កើនផ្លូវគមនាគមន៍ ឱ្យប្រជាជនកាន់តែស្រួលក្នុងការដឹកជញ្ជូន។

ខ្ញុំតែងតែស្រឡាញ់លោកវិមលស្មោះអស់ពីជម្រៅចិត្ត ដោយសារលោកគិតពីប្រទេសខ្មែរ និងទំនាក់ទំនងរវាងប្រទេសយើងទាំងពីរ មិនដែលលោះពេល។ ខ្ញុំយំនឹកលោក នឹកស្តាយពីគំនិតតិរិះនិងទឹកចិត្តដ៏ល្អហួសពីការស្មាន ដែលលោកខ្លួនលោកគិតថា ជាការធម្មតាសំរាប់ជនដែលតាំងខ្លួនជាមនុស្សជាតិ។

វេលាដែលខ្ញុំយំ ម៉ែខ្ញុំតែងតែដុតធូបដប់សរសៃ ដែលគិតទៅពុំមានន័យអ្វីប៉ុន្មានទេ តែហាក់ដូចជា សាក្ខីភាព ឬជាបំណងដែលចង់ឱ្យការអធិដ្ឋានរបស់យើងទាំងពីរ ឮទៅដល់ព្រលឹងរបស់លោកវិមល។

ម៉ែបានពូនកូនភ្នំខ្សាច់មួយដាក់ក្នុងចាន ហើយរៀបនៅលើហ៊ឹងរបៀបដូចជាផ្នូរ ឬជាជំនឿមួយថា យើងអាចបញ្ជូនកុសលច្រើន ទៅជូនលោកវិមល។ យើងបានដាក់ដុំឈើខ្លឹមច័ន្ទក្រឹស្នាមួយដុំ នៅក្នុងភ្នំខ្សាច់នោះ។ ខ្ញុំតែងតែលបសច្ចាស្ងាត់ៗ នៅក្នុងចិត្ត នៅពេលដែលខ្ញុំអុជធូបបួងសួងម្តងៗ សូមឱ្យវិញ្ញាណលោកវិមលបានទៅកើតនៅសុគតិភព ហើយសូមឱ្យលោកជួយណែនាំតំរែតំរង់ខ្ញុំជានិច្ច។

ដប់ឆ្នាំបានកន្លងទៅហើយ។ នាងតូចវិរៈផានតោងតែបានអាយុ១៩ឆ្នាំ ហើយគំរប់ឆ្នាំនេះ។ ខ្ញុំតែងរង់ចាំនាងជានិច្ច ទោះបីជាខ្ញុំខានបានទទួលសំបុត្រពីនាងជាច្រើនឆ្នាំហើយក្តី។ ខ្ញុំមានអាយុ ៣២ ឆ្នាំ ហើយបានរៀបការជាមួយសាស្រ្តាចារ្យម្នាក់ ដែលចេញជំនាន់គ្នានៅពេលដែលខ្ញុំមានអាយុ២៨ឆ្នាំ។

មិត្តភាពរវាងលោកវិមលនិងខ្ញុំ ទោះបីជាថ្ងៃខែកន្លងទៅច្រើនហើយក្តី ហើយខ្ញុំអាចរសាយពីទុក្ខដ៏ធំធេងបានខ្លះៗមែន ប៉ុន្តែទឹកចិត្តគោរពស្រឡាញ់ចំពោះមនុស្ស ដែលមានលក្ខណៈលើសមនុស្សនេះ មិនដែលចុះស្តើង ឬស្លែតពណ៌ទាល់តែសោះ។

ខ្ញុំបានរៀនសូត្រតាមរយៈការរាប់អានរបស់យើងទាំងពីរថា មនុស្សជាតិអាចចងផ្ទាប់គ្នាយ៉ាងតឹងបានដោយសារចំណងពុទ្ធិ មេត្តាធមិ សេចក្តីស្នេហាខន្តី

និងសេចក្ដីសណ្ដោស ហើយចំណងនេះមានកំឡាំងខ្លាំងក្លាជាងការទ្នះ ឬព្យុះសង្ឃរាទៅទៀត ។

**ចប់**

# រតន៍នារី

និពន្ធដោយ ប៉ែន សេដ្ឋារិន

ឧទ្ទិសជូននារី

## ជំពូកទី១

ផ្ទះរបស់លោកឧកញ៉ា សុទ្ធ ក្រសេម ជាផ្ទះបុរាណ សាងសង់នៅលើដីឡូត៍ដ៏ធំល្វឹងល្វើយ ដូចជាវិមានដែលសង់ចំកណ្ដាលវាលស្មៅ និងសួនផ្កាក្នុងរឿងព្រេងនិទានបុរាណ។ ពិភពនេះខុសឆ្ងាយពីពិភពទាំងឡាយដែលខ្ញុំធ្លាប់ស្គាល់ធ្លាប់ដឹងតាំងពីពេលដែលខ្ញុំមកធ្វើការនៅប្រទេសកម្ពុជា។

ផ្ទះនេះបែរមុខទៅរកវិថីព្រះសីហនុ នៅចំពីមុខសួនច្បារវិមានឯករាជ។ គឺជាផ្ទះពណ៌ស សង់បែបផ្ទះបញ្ជឹមប្រទេស លាបពណ៌ពងមាន់ស្រាល សឹងតែមើលទៅឃើញថាជាពណ៌ស។ នៅចំពីមុខផ្ទះមានដើមចេកបារាំងប្រាំដើម ដាំរយាលពីគ្នាប្រហែលជា ដប់ម៉ែត្រ ដប់ម៉ែត្រ។ នៅចំកណ្ដាលទីធ្លា មានស្រះទឹករាងបួនជ្រុងទ្រវែងធំមួយ ដែលជីករបៀបដូចជាអាងហែលទឹក មានរៀបឥដ្ឋការ៉ូពណ៌ផ្ទៃមេឃនៅបាតនិងទទឹងបណ្ដោយ។ ប៉ុន្តែដោយសារមានផ្កាប្រលិតពាសពេញ គេពុំអាចមើលឃើញបានច្បាស់ឡើយ។

នៅជុំវិញអាងទឹកនោះមាន ដាំដើមឈើទាបៗ ដែលមានស្លឹកពណ៌បៃតងខ្ចីស្រស់ខ្ចបប្រាំងខ្ចបវស្សា។ ក្រៅពីផ្លូវ ដែលមានទទឹងប្រហែលជាប្រាំហត្ថ ដែលមានចាក់ស៊ីម៉ង់ពីលើទីធ្លានៃគេហដ្ឋាននេះ គ្របដណ្ដប់ទៅដោយស្មៅ ដែលគេថែទាំកាត់តរីមបានល្អហ្មត់ចត់ណាស់។

ដូចជាប្រទេសឯទៀតៗ នៅប្រទេសអាស៊ីភាគអាគ្នេយ៍ភាគច្រើនដែរ កម្លាតរវាងអ្នកមាននឹងអ្នកក្រ មានទំហំធំហួសប្រមាណណាស់ ហើយនេះជាលើកទីមួយហើយ ដែលខ្ញុំបានមកឃើញសភាពពិតនេះ។

លោកឧកញ៉ាសុទ្ធ ក្រសេម មានអាយុទើបតែ ៦៥ ឆ្នាំប៉ុណ្ណោះទេ តែលោកមានសក់ពណ៌សព្រោង ដើរយឺតៗ បញ្ជាក់ថា លោកមិនសូវជាមនុស្សដែលមានសុខភាពមាំមួនប៉ុន្មានទេ។

លោកស្លៀកខោបារាំង ពណ៌ពងជីងចក់ ពាក់អាវពណ៌លឿងស្រាលសឹងតែអាចថា ពណ៌ពងមាន់ ចងក្រាវ៉ាត់សូកូឡាឆើត មានបន្ដក់តូចៗដូចកូនផ្កាយសៗ។ មើលទៅឃើញថា ជាមនុស្សដែលទទួលអារ្យធម៌បារាំងក្រាស់ណាស់។

ពេលជួបខ្ញុំជាដំបូង លោកមានប្រសាសន៍ជាបារាំង ដែលជាទម្លាប់នៃជនជាតិនៃប្រទេសដែលធ្លាប់ស្ថិតនៅក្រោមអាណានិគមបារាំងទាំងឡាយ ដែលយល់ថា ជនបរទេសសុទ្ធតែជាបារាំង។

ខ្ញុំបានជំរាបលោកថា ខ្ញុំចេះភាសាខ្មែរជាងភាសាបារាំង។ លោកធ្វើមុខចម្លែកអេះអុញមួយសន្ទុះ ប្រហែលជាដោយសារចម្លើយនេះវាប្រថុចញ៉ុចពេក ហើយនាំឱ្យលោកច្រឡំបល់ លំបាកនឹងបញ្ចេញប្រតិកម្មភ្លាមៗបានក៏មិនដឹង។

ខ្ញុំឯនេះ ដោយឃើញលោកអេះអុញ ក៏ហាក់ដូចជាបានត្រូវព្រលែងចេញឱ្យផុតពីជម្ងឺច្រាបជាន់ ដោយឃើញលោកឧកញ៉ាមហាមន្ត្រីនៅនឹងមុខច្បាស់ក្រឡែតបែបនេះផង ដោយបរិយាកាសរុងរឿងជ្រុលហួសប្រមាណនៃទីនេះផង។

លោកឧកញ៉ាមហាមន្ត្រីលាដៃចង្អុលទៅកៅអីឱ្យខ្ញុំអង្គុយចុះ។ លោកក៏អង្គុយចុះទៅលើកៅអីដែលនៅពីមុខខ្ញុំដែរ ហើយចាប់ផ្ដើមមើលប្រវត្តិរូបដែលខ្ញុំជូនទៅលោក តាមទំនៀមទំលាប់ជប៉ុន នៅពេលដែលយើងចូលទៅធ្វើសម្ភាសន៍ការងារនៅកន្លែងណាមួយ។ ទំនៀមទម្លាប់នេះប្រហែលជាមិនទាន់ជ្រួតជ្រាបទូទៅនៅក្នុងសង្គមរបស់ខ្មែរនៅឡើយទេ។

នារីបំរើបានលើកភេសជ្ជៈម្យ៉ាង ដែលខ្ញុំមិនមានទម្លាប់នឹងទទួលទានសោះតាំងពីខ្ញុំមកនៅប្រទេសនេះ។ ខ្ញុំគិតថាប្រហែលជាទឹកដូង ឬទឹកត្នោត។ មានសាច់របស់ផ្លែវាជាសរសៃស១ រតាយ១ ហែលលាយជាមួយនឹងទឹក។ ពែងដែលដាក់ភេសជ្ជៈនេះមិនមែនជាកែវទេ គឺជារបស់មួយដែលធ្វើអំពីប្រាក់ ប្រកបដោយចម្លាក់សុះសព្វគ្មានឱ្យចន្លោះ។ ចំពោះយើងជាជប៉ុន ដែលទំលាប់ឃើញតែកូនបន្តក់មួយចំណុចនៃចម្លាក់ យើងឃើញថាជាការងារដែលពោរពេញទៅអំណត់ និងពេលវេលាជាប់បន្តគ្នាវែងណាស់។ នៅនឹងពែងនេះ ឥតមានបំពង់បឺតទេ ខ្ញុំតោងតែទទួលទានផ្ទាល់។

ខ្ញុំស្ទើរតែភ្លេចទទួលទានទឹក ដែលគេដាក់ឱ្យនេះ ពីព្រោះរវល់តែប្រមូលអារម្មណ៍ ឱ្យនៅហ្នឹងហ្ន ដើម្បីឱ្យខ្ញុំអាចឆ្លងឆ្លើយជាមួយនឹងលោកឧកញ៉ា។ មួយសន្ទុះមកលោកក៏មានប្រសាសន៍ថា :

- អ្នកឯងឈ្មោះ អា គី អូ ហ៊ីរ៉ាម៉ា ឬ ?

- ព្រះបាទ! ខ្ញុំព្រះបាទឈ្មោះ អាគីអូ ។

- អើ ចេះភាសាខ្មែរគ្រាន់បើផង។

លោកដកវ៉ែនតាពីប្រវត្តិរូបរបស់ខ្ញុំ ដកវ៉ែនតាចេញពីភ្នែក ហើយខិតជ្រៅទៅក្នុងកៅអី។

រួចហើយ លោកសួរតាមធម្មតា ហាក់ដូចជាបានធូរចិត្ត ដោយឃើញខ្ញុំចេះភាសាខ្មែរជ្រៅជ្រះក៏មិនដឹង។

- អ្នកឯងបង្រៀនអ្វីនៅមហាវិទ្យាល័យ?

- ព្រះបាទ បង្រៀនភាសាអង់គ្លេស ទានប្រោស។

- ក្រែងអ្នកជាជនជាតិជប៉ុនឬ?

- ព្រះបាទ ជប៉ុន ។

- ជប៉ុននិយាយអង់គ្លេសឬ?

- ប្របាទទេ។ ខ្ញុំព្រះបាទធ្លាប់ទៅរៀននៅប្រទេសអាមេរិក ហើយអាចនិយាយនិងសរសេរបានគ្រាន់បើ។

លោកឧកញ៉ាស្តាប់ខ្ញុំនិយាយ លោកមិនតបថាម៉េចទេ បែរជានិយាយពីប្រធានបទផ្សេង :

- ដូចអ្នកឯងដឹងស្រាប់ហើយ ពួកយើងសុទ្ធតែជាមនុស្សបុរាណ ចេះប្រើតែភាសាបារាំង។ ប៉ុន្តែសម័យឥឡូវនេះ នៅឯណាក៏គេប្រើភាសាអង់គ្លេស។ អញ្ចឹងហើយបានជា យើងចង់ឱ្យរតន៍នារីជាចៅស្រីតែមួយ រៀនអង់គ្លេសឱ្យចេះអាចនិយាយជាមួយជនជាតិនានាបាន។ ខ្ញុំឮល្បីថា អ្នកឯងនៅក្មេង ពូកែបង្រៀន មានគេអញ្ជើញទៅបង្រៀននៅសាលានេះ សាលានោះ ទើបអញ្ជើញអ្នកមកបង្រៀន។ ចូរអ្នកឯងខិតខំបង្រៀនឱ្យបានហ្មត់ចត់ណា៎។ ប្រាក់សាគុណយើងនឹងជូនឱ្យបានពេញចិត្ត។

- ព្រះបាទ។ ខ្ញុំព្រះបាទសូមអរព្រះគុណ។

លោកឧកញ៉ាមហាមន្ត្រីបានមានប្រសាសន៍ហ្នឹងហ្មាត់ តែដូចជាមានការទុកចិត្តមកលើខ្ញុំ មុននឹងលោកចាកចេញពីបន្ទប់ ថា :

- តាមពិតទៅ យើងមិនចង់អញ្ជើញគ្រូខ្មែរមក ដោយសារតែខ្លាចមានបញ្ហាស្នេហា អូនបង ណា៎។ ចៅខ្ញុំ មិនស្គាល់ពិភពលោក ឆាប់ជឿពាក្យមនុស្សប្រុសណាស់។ វាឆាប់អាណិតគេ ចិត្តទន់។ ខ្ញុំបារម្ភណាស់។ ដូច្នេះអ្នកតោងតែគោរពទឹកចិត្តរបស់ខ្ញុំ ហើយមិនត្រូវប្រើពាក្យសម្តីផ្តេសផ្តាសក្រៅពីការបង្រៀនវិជ្ជាទេ។ ឮឬទេ? ទោះបីជាអ្នកឯងប្រាថ្នា ក៏ពុំអាចទៅជាការពិតបាន

ដែរ ព្រោះរតន៍នារីមានគូកំណត់ដែលចាស់ៗនិយាយគ្នាទុកត្រូវរ៉ូវតាំងពីនាងនៅកូនង៉ាងនោះ ។

- ខ្ញុំព្រះបាទមិនធ្វើឱ្យព្រះតេជគុណខកចិត្តទេទានប្រោស ។

ខ្ញុំឆ្លើយបណ្តើរ ហាក់ដូចជាអន់ចិត្តបណ្តើរ ចំពោះការប្រើពាក្យរបៀបដូចជាបញ្ជោកូនគូលីជាចុងក្រោយ ។ គិតឱ្យសព្វទៅ ខ្ញុំគឺជាអានាគតគ្រូនៃចៅរបស់លោក មិនមែនខ្ញុំមកជាអ្នកបំរើរបស់លោកឡើយ ។

មួយសន្ទុះមក លោកឱ្យខ្ញុំចាំមួយភ្លែត ហើយលោកក៏ចេញទៅក្រៅ ។ នាងរតន៍នារីជាចៅរបស់លោក បានដើរចូលមកក្នុងបន្ទប់ជាមួយនឹងភីលៀងរបស់នាងពីរនាក់ ។

នាងមានមាឌតូចស្គម សម្បុរទង់ដែង ទងវង ។ ខ្ញុំឮលោកឧកញ៉ាមានប្រសាសន៍ថា ចៅរបស់លោកមានអាយុ ១៩ ឆ្នាំ ។ បើតាមតែរូបរាងសម្ពី សម្តៅការអៀនប្រៀន របស់នាង ខ្ញុំឃើញនាងមានអាយុតែ ១៤ ឬ១៥ តែ ប៉ុណ្ណោះ ។ នាងតូចញញឹមស្រស់ណាស់ មានរបៀបខុសប្លែកពីធិតាខ្មែរនានា បន្តិច ។ នាងរាដៃយ៉ាងទាបដាក់ខ្ញុំ ក្នុងន័យគំនាប់ខ្ញុំ ។ ភីលៀងរបស់នាងប្រញិបប្រញាប់កែតម្រូវកាយវិការនាង :

- អ្នកនាងតូច ទោះបីគេជាជនបរទេសក៏ដោយ គេជាគ្រូ របស់អ្នកនាង ណាំ ។

សូមអ្នកនាងលើកដៃសំពះគេ ។ ព្រះអើយបើលោកតាឃើញ បន្ទោសខ្ញុំស្លាប់ហើយ ។

ពេលឮបែបនេះ រតន៍នារី ក៏លើកដៃសំពះខ្ញុំ បង្អោនក្បាលនាងយ៉ាងទាបុដោយបន្ទន់ជើងនាងបន្តិច មើលទៅគួរឱ្យរំភើបចិត្តជាខ្លាំង ។នាងប្រៀបដូចជាកូនទេវតាដែលស្មោះត្រង់ មានចិត្តថ្លាឆ្វង់ដូចជាកែវចរណៃ ។ អកប្បកិរិយាទាំងអស់របស់នាង ធ្វើឱ្យខ្ញុំភ្លឹកភ្លាំង គយគន់មើលនាងធ្វើអ្វីៗទាំងបើកមាត់ចំហធ្លុងតែម្យ៉ាង ។

រតន៍នារីញញឹមស្រស់ទៀត រួចហើយនាងអង្គុយចុះ នៅលើទីកន្លែងដែលលោកឧកញ៉ាមហាមន្ត្រី អង្គុយអំបាញ់មិញ ។

- អ្នកនាងរតន៍នារី ចេះភាសាអង់គ្លេសទេ?

ខ្ញុំសួរទៅនាង ។

- ចាំ លោកគ្រូខ្ញុំអត់ចេះទេ ។ សូមលោកគ្រូមេត្តាបង្រៀនខ្ញុំពីសូន្យទៅ ។ ម្យ៉ាងទៀត ខ្ញុំឆ្លាតតែរាំ មិនឆ្លាតរៀនសូត្រទេ ។ ដូច្នេះប្រហែលខ្ញុំនឹងទៅជាកូនសិស្សអាក្រក់ណាស់ ។

សម្លេងនាងថើៗពិរោះ ដូចសារិកានិយាយ ។ ខ្ញុំបានតបទៅនាងវិញថា :

- លោកគ្រូអាចអត់អោន មិនខឹងចំពោះសិស្សដែលឧស្សាហ៍ ទោះជាសិស្សនោះមិនឆ្លាតក៏ដោយ ។ តែមិនចូលចិត្តសិស្សដែលឆ្លាតហើយខ្ជិលទេ ។

ភិលៀងទាំងឡាយបើកភ្នែកធំៗ ហាក់ដូចជាភ្ញាក់ ប្រហែលជាដោយសារខ្ញុំហ៊ាននិយាយច្បាស់ៗបែបនេះ ជាមួយនឹងនារីដែលគេយល់ថា មានឋានៈខ្ពង់ខ្ពស់ក៏មិនដឹង ។

រតន៍នារី មើលខ្ញុំនិយាយបណ្តើរ សើចញញឹមៗបណ្តើរតតថាអ្វី ។ ចំពោះសំរស់ដែលខ្ញុំអាចថាបានតែម្យ៉ាងថា ស្រស់ដូចផ្កាកុឡាបក្រពុំតូច នៅវេលាព្រឹកដែលមានទឹកសន្សើមដក់ជាប់ ពីលើនៅឡើយនិងភាពក្មេងខ្ចីប្រៀបបាននឹងកូនតូចរបស់នាង ខ្ញុំពុំអាចដាច់ចិត្តខឹងនាងបានទេ ប៉ុន្តែនៅវេលាដែលខ្ញុំគិតថា នាងចាត់ទុកពាក្យដែលខ្ញុំបានណែនាំនាង ថាជាពាក្យលេងសើច ខ្ញុំក៏ចាប់មាន កំហឹងហើយខ្ញុំនិយាយសង្កត់មួយៗយ៉ាងដាច់ហ្មាត់ថា :

- ស្តាប់ឱ្យបានណាំរតន៏នារី ។ លោកគ្រូមិននិយាយលេងសើចទេ ។ ឥឡូវនេះ គ្រូមិនយកទោសនាងទេ តែបើនាងមិនខិតខំរៀនទេ លោកគ្រូនឹងឱ្យសូន្យនាងហើយណាំ ។

រតន៏នារីយកដៃតូចៗ ពោរពេញទៅដោយឆ្អឹងរបស់នាងទាំងពីរ ខ្ទប់មាត់សើច ។ ទង្វើនេះ រិតតែធ្វើឱ្យខ្ញុំមិនសប្បាយចិត្ត ។ មួយសន្ទុះនាងក៏និយាយថា :

- លោកគ្រូមានប្រសាសន៏ជាខ្មែរ ដូចខ្មែរនិយាយខ្មែរ ។ ក៏ប៉ុន្តែលោកគ្រូជាជនជាតិបរទេសទេ មែនទេ?

- បាទខ្ញុំជាជនជាតិជប៉ុន ។

- ជនជាតិជប៉ុន? ជប៉ុនជាបារាំងដែរឬ?

ខ្ញុំហួសចិត្ត ។ ប៉ុន្តែខ្ញុំបានគិតជាថ្មីវិញ ហើយបានជម្នះចិត្តដែលកំរើករបស់ខ្លួនបាន ហើយយកដៃច្បូតច្រមុះខ្លួនឯងបន្តិច ។ រួចហើយខ្ញុំក៏និយាយមួយៗថា :

- ជប៉ុនក៏ស្ថិតនៅក្នុងទ្វីបអាស៊ីដូចជាខ្មែរដែរ ។ នៅប្រទេសខ្មែរមានចិនច្រើន ។ អ្នកនាងដឹងរឿងនេះទេ?

- ចាំខ្ញុំដឹងលោកគ្រូ ។

នាងឆ្លើយយ៉ាងស្ងប់ស្ងាត់ ហើយទន់ភ្លន់ណាស់ ។ ខុសពីនាងដែលនិយាយសំឡេងស្រាលៗដូចកូនបក្សី ភីលៀងនាងទាំងពីរនាក់មើលមុខគ្នាឡើនឡង់ខ្សឹបខ្សៀវគ្នាឮៗថា :

- ចិន គឺពួកលក់ឥវ៉ាន់នៅតាមផ្សារ ពួកថៅកែដែលយកស្រា នំចំណើមកផ្ទះយើងញឹកញាប់នោះឬ?

ខ្ញុំបានរើខ្លួនខ្ញុំ អង្គុយខិតចូលទៅក្នុង ឱ្យខ្ញុំអាចផ្អែកខ្នងទៅនឹងបង្អែកកៅអីបានហើយ ខ្ញុំក៏និយាយទាំងអារម្មណ៏គ្រោតគ្រាតថា :

- ខ្ញុំមិនដឹងថា មានចិនយកជំនូនមកជូននាងឬយ៉ាងណាទេ តែនៅស្រុកខ្មែរចិនច្រើនតែជាអ្នកធ្វើពាណិជកម្ម ឬលក់ដូរនៅទីផ្សារ ។

រួចមកខ្ញុំក៏បែរមករករតន៏នារីវិញ សួរនាងដោយសម្លេងធម្មតាថា :

- ចុះនាងដឹងទេថា ហេតុអ្វីបានជាមានជនជាតិចិននៅស្រុកនាងច្រើន?

- ចាំ លោកតាធ្លាប់មានប្រសាសន៏ថា ស្រុកយើងកក់ក្តៅ ប្រជាជនចិត្តស្លូតបូត ស្រួលរស់នៅ ទើបជនបរទេសចូលមកលេង ហើយមករស់នៅច្រើន ។

នៅពេលដែលឮនាងនិយាយបែបនេះ ខ្ញុំក៏យល់ថារតន៏នារី ជាកុមារី ដែលមិនលេងសើច ហើយនាងខិតខំស្វែងយល់ពីបញ្ហានានានៅក្នុងសង្គមដែរ ។ នេះច្បាស់ជាទិសដៅនៃការអប់រំរបស់លោកឧកញ្ញាមហាមន្ត្រី មិនលែងឡើយ ។

ហើយខ្ញុំក៏ទៅជាមានការសប្បាយចិត្តក្រៃលែង នឹងបង្រៀននាង ។ ទោះបីជាចម្លើយរបស់នាងនៅតែវិលវល់ជុំវិញតែរឿងប្រទេសនាង និងប្រជាជននាងហើយពុំឃើញមាននិយាយឱ្យច្បាស់លាស់ពីប្រវត្តិសាស្ត្រនៃប្រទេសនានាក្តី ក៏ខ្ញុំមានសង្ឃឹមច្រើនថា នារីតូចនេះនឹងលូតលាស់ ហើយនឹងទៅជាតារាដ៏ភ្លឺអស្ចារ្យមួយដួងនៃប្រទេសនៃភាពញញឹមនេះ ។

ខ្ញុំបានពន្យល់នាងពីប្រទេសជប៉ុន ពីទីកន្លែងភូមិសាស្ត្រនៃប្រទេសនេះ ពីប្រទេសចិនដែលនៅជិតជប៉ុន ហើយនាងខំស្តាប់ខ្ញុំដោយយកចិត្តទុកដាក់ ។

តាមពិតទៅ ប្រទេសកម្ពុជាដែលស្ថិតនៅឧបទ្វីបឥណ្ឌូចិន គួរតែយកចិត្តទុកដាក់ស្គាល់ប្រទេសចិននិងឥណ្ឌាទាំងពីរឱ្យច្បាស់ជាក់លាក់ជាការប្រសើរ តែផ្ទុយទៅវិញ ជនជាតិខ្មែរភាគច្រើនដែលខ្ញុំស្គាល់ ស្គាល់តែថា ចិនគឺជាជនជាតិភាគ តិចដែលរស់នៅលក់ដូរក្នុងផ្សារ ហើយដែលសឹងតែក្លាយទៅជាខ្មែរអស់ទៅ ហើយឯជនជាតិឥណ្ឌា គឺពួកឈ្មួញដែលលក់ក្រណាត់ ឬជរ ឬក្រណាត់សូត្រ សាតាំង

ក្រណាត់ថ្លៃៗនៅផ្សារតែប៉ុណ្ណោះ។ គេភាគច្រើនពុំដែលគិតថា ប្រទេសទាំងពីរធ្លាប់ជាប្រទេសដែលមានអារីយធម៌ខ្ពស់ ដែលមានកំណើតតាំងពីមុនគ្រឹស្តសករាជរាប់ពាន់ឆ្នាំហើយទេ។

នៅពេលដែលខ្ញុំបង្រៀនរតន៍នារី ខ្ញុំបានដឹងថានាងឈប់ទៅរៀនវិជ្ជានៅសាលារៀនធម្មតា ដូចកុមារដទៃទៀតហើយ។ នាងរៀនត្រឹមថ្នាក់ទី១ ទំនើបជាតិ (ថ្នាក់ទី១២សព្វថ្ងៃ) ក៏ឈប់រៀន ដោយសារនាងជាតារានៃល្ខោនក្បាច់បុរាណ ហើយនាងតោងតែហាត់ច្រើន ដើម្បីចេញទៅសំដែងនៅប្រទេសខាងអឺរុបអាស៊ីនៅពេលខាងមុខនេះផង។ ខ្ញុំតែងតែប្រុងប្រៀបអត្ថបទអង់គ្លេសដោយខ្លួនឯង និយាយពីប្រទេសកម្ពុជា ឱ្យនាងស្គាល់ប្រទេសនាង ហើយអាចពន្យល់ឱ្យគេដឹងពីប្រទេសនេះជាភាសាអង់គ្លេស ពីទីកន្លែងដែលប្រទេសនេះស្ថិតនៅ ដោយមើលផែនទីពិភពលោក ពីប្រាសាទអង្គរ ពីប្រទេសនានាដែលប្រទេសនាងទទួលឥទ្ធិពល ជាដើម។

ដំបូងខ្ញុំបង្រៀននាងពីប្រាសាទអង្គរ។ យើងបានលើកប្រធានបទពីប្រាសាទនេះ ហើយខ្ញុំឱ្យនាងតែងសេចក្តីពីប្រាសាទអង្គរវត្តជាភាសាអង់គ្លេស។

រតន៍នារីសរសេរថា ប្រាសាទនេះសាងសង់នៅសតវត្សទី១២ នៅក្នុងរាជនៃព្រះបាទសុរិយាវរ៍្មនទី២។ ខ្មែរទទួលឥទ្ធិពលពីជនជាតិឥណ្ឌាមែន ប៉ុន្តែខ្មែរពុំមែនយកវប្បធម៌គេទាំងដុលមកអនុវត្តទេ ខ្មែរយកមកច្នៃឱ្យទៅជាខ្មែរពិតប្រាកដ។

គំនិតនេះ ខ្ញុំតែងតែបានឮខ្មែរដែលបានរៀនសូត្រនិយាយសឹងតែគ្រប់គ្នា។ ដូច្នេះខ្ញុំបានគិតថា ប្រហែលជាឃ្លានេះមានសរសេរនៅក្នុងសៀវភៅប្រវត្តិសាស្ត្រដែលក្រសួងអប់រំជាតិដាក់ឱ្យសិស្សនិងនិស្សិតសិក្សាហើយ។

ខ្ញុំបានសួរនាងថា តើនាងដឹងថាប្រទេសឥណ្ឌាមានប្រាសាទ អ្វីខ្លះទេ?

រតន៍នារី បានឆ្លើយថា នាងមិនដឹងទេ។ ខ្ញុំក៏បានយករូបថតដែលបង្ហាញពីប្រាសាទអាហ្សង់តាដែលនៅក្នុងរូងភ្នំ ហើយដែលមានរូបរាងជាគុហាធម្មជាតិនៅខ្ពង់រាបដេកាំងដែលស្ថិតនៅភូមិភាគខាងលិចរបស់ប្រទេសឥណ្ឌា សាងសង់នាសតវត្សទី២ មុនគ្រឹស្តសករាជ ទៅដល់សតវត្សទី៧។ នៅក្នុងគុហាដែលប្រៀបបាននឹងភាគខាងក្នុងព្រះវិហារវត្តនោះ គេមានឆ្លាក់និងគូរពីរឿងព្រះពុទ្ធនិងប្រវត្តិព្រះពុទ្ធ។ គុហាមានទាំងអស់៣0 កំពស់២0ម៉ែត្រ ទទឹង ១៣ ម៉ែត្រ។ បន្ទាប់មក ខ្ញុំនិយាយប្រាប់នាងថា ក្រៅពីបូជនីយដ្ឋានបែបព្រះពុទ្ធសាសនាបែបនេះ មានបូជនីយដ្ឋានបែបសាសនាហិណ្ឌូ សាសនាជ័យនា សាសនាអ៊ីស្លាមជា ច្រើនសាងសង់នៅពាសពេញប្រទេសឥណ្ឌា។ ខ្ញុំបានបង្ហាញរូបប្រាសាទនានា ដូចជាប្រាសាទឱ្យលគា ដែលមើលមួយភ្លែតទៅ មានទ្រង់ ទ្រាយដូចជាប្រាសាទបន្ទាយស្រី ប្រាសាទកៃលាសណាតា តូចៗដូចប្រាសាទ សួរព្រ័តប្រាសាទរតនាគីរី និងប្រាសាទបែបអ៊ីស្លាមជាច្រើន មានតាជីម៉ាហាលដែលព្រះចៅអាក្បាល បានសាងសង់ជាសាក្ខីភាពនៃសេចក្តីស្នេហាចំពោះព្រះអគ្គមហេសីទ្រង់ ជាដើម។

នាងបានសួរខ្ញុំថា តើខ្ញុំដែលទៅមើលគុហា ឬប្រាសាទទាំងនោះផ្ទាល់ភ្នែកឬទេ? ខ្ញុំថាខ្ញុំដែលទៅមើលតែប្រាសាទអាហ្សង់តា អ៊ីឡូរ៉ា និងតាជីម៉ាហាលតែប៉ុណ្ណោះ។

នាងបាននិយាយថា ខ្ញុំមានសំណាងខ្ពស់ណាស់ ដោយបានឃើញពិភពលោកដ៏ធំទូលាយ។ ហើយនាងសួរខ្ញុំថា តើព្រះវិហារទាំងនោះល្អយ៉ាងណាទៅបើឥណ្ឌាជាគ្រូដែលបង្រៀនខ្មែរទៅហើយ។

ខ្ញុំបានប្រាប់នាងថា រឿងគ្រូនិងសិស្ស ពុំមានទំនាក់ទំនងខ្លាំងក្លាប៉ុន្មានទៅលើស្នាដៃ ថ្វីដៃ និងសិល្បៈទេ។ ដែលសំខាន់គឺ តើបុគ្គលនោះ មានទេពកោសល្យបែបណា មានញាណារម្មណ៍ធំទូលាយ មានទស្សនៈបែបណា ចេះប្រើមនោគតិរបស់ខ្លួន ឬអត់ឯនោះទេ។ ជួនកាលគ្រូចង់ថាអញ្ចេះទេ តែជួនកាលសិស្សយល់ថាអញ្ចុះផ្សេង ដោយសិស្សមានទេពកោសល្យខ្ពស់ ឬគំនិតប្លែកពីគំនិតរបស់គ្រូក៏មាន។ ដូច្នេះប្រាសាទទាំងឡាយរបស់ខ្មែរ សុទ្ធតែជាញាណារម្មណ៍ខ្មែរ ចំណង់ចំណូលចិត្តរបស់ខ្មែរ ទស្សនៈខ្មែរ ទេពកោសល្យខ្មែរទាំង អស់។

ត្រូវហើយ ចំណេះដែលក្រេបជញ្ជក់ពីគ្រូ បានក្លាយទៅជាជីវជាតិមួយ ជាបំណែកមួយនៃសិរះរបស់យើងនោះគឺជាការពិត។ ហើយបើនិយាយពីចម្លាក់ទាំងឡាយនៃគុហាអាហ្សង់ដាវិញ គ្រូគិតថា មានរបៀបបុរាណាចារ្យ ហើយបង្ហាញនូវជំនឿជាងទស្សនវិជ្ជា។ គឺជាទឹកចិត្តរំភើបរបស់ប្រជាជនធម្មតា ដែលស្រឡាញ់ ដែលគោរពព្រះពុទ្ធ ព្រះសាមណគោត្តម ដោយបានស្តាប់ធម៌របស់ព្រះអង្គ នោះហើយដែលនាំឱ្យប្រជាជនទាំងឡាយ ឬក៏ព្រះសង្ឃទាំងឡាយគូរឆ្លាក់រូបទាំងនោះ ដើម្បីគោរពបូជាជាប្រចាំ ដោយមិនបានគិតដល់អាវកាស ឬក៏ទស្សនវិជ្ជាខ្ពង់ខ្ពស់ឯណាទេ។ ដូច្នេះហើយបានជានៅពេលដែលទស្សនវិទូឥណ្ឌាម្នាក់ មកទស្សនាប្រាសាទអង្គរវត្តខ្មែរ លោកបានរំភើបចិត្តជាខ្លាំង នឹងឃើញការប៉ិនប្រសប់ក្នុងការបកស្រាយទស្សនៈអរូបីដ៏ខ្ពង់ខ្ពស់នៃគម្ពីរឧបនិស្ស័ទ ឬគម្ពីរឬក៏វេទ របស់ឥណ្ឌានៃជនជាតិខ្មែរនេះ ដោយប្រាសាទធំៗដែលពុំមាននៅស្រុកលោក។

ប្រាសាទអង្គររបស់នាង គឺជានិមិត្តរូប គឺជាការបង្ហាញនូវគំនិត នូវទស្សនៈរបស់ជនជាតិខ្មែរទៅលើអាវកាសនិងពិភពលោក។ កំពូលកណ្តាលជាភ្នំព្រះសុមេរ ហើយកំពូល៤ ទៀតជាទ្វីបទាំង៤ (ជំនាន់ដើម យើងយល់ថាទ្វីបមាន៤)។ ប្រាសាទនាគព័ន្ធ ក៏បែបនោះដែរ។ ឯប្រាសាទអង្គរធំវិញគឺជាសៀវភៅសីលធម៌ ដែលពន្យល់ពីព្រហ្មវិហារធម៌ផង ជាសៀវភៅដែលកត់ត្រាពីប្រវត្តិសាស្ត្រផង ជាសៀវភៅទស្សនវិជ្ជាបែបព្រះពុទ្ធសាសនាផង។

ប្រជាជនខ្មែរសាងសង់ប្រាសាទដែលបង្កប់ទៅដោយទស្សនវិជ្ជាច្រើនណាស់។ ខ្ញុំជឿថា ប្រហែលជាមានជនជាតិឥណ្ឌាឯទៀតជាច្រើន ដែលប្រាថ្នាចង់មកឃើញប្រាសាទអង្គរនេះ។

រតន៍នារីព្យាយាមស្តាប់ខ្ញុំភ្លឹក។

- នាងយល់ហើយឬនៅ ពេលគ្រូនិយាយមកដល់នេះ?

ខ្ញុំបញ្ជាក់នាង។ ខ្ញុំតែងតែបញ្ជាក់ជារឿយៗនៅពេលដែលខ្ញុំបង្រៀន ព្រោះខ្ញុំខ្លាចសិស្សរបស់ខ្ញុំមិនយល់។ រតន៍នារីងក់ក្បាល។ តែនាងសួរថា :

- លោកគ្រូអាចដឹងបានទេថា ទស្សនវិជ្ជារបស់ខ្មែរគឺអ្វី?

- ជាការស្មានរបស់គ្រូទេណា៎ ពីព្រោះប្រទេសនាងបានបាត់បង់ឯកសារ ច្រើន ហើយពុំមានអ្នកណាអាចដឹងឱ្យច្បាស់បានទេ។ គ្រូគិតថា គឺជាការបក ស្រាយ ការពន្យល់ទៅលើទ្រឹស្តីទាំងឡាយដែលពួកព្រាហ្មបាគូ និងទ្រឹស្តីព្រះពុទ្ធនៃជនជាតិខ្មែរ ទៅតាមមនោគតិដោយឡែករបស់ជនជាតិខ្មែរ តែម្តងនោះហើយ។

សិស្សរបស់ខ្ញុំមើលមកខ្ញុំមិនដាក់ភ្នែក។ ខ្ញុំដឹងថានាងមិនទាន់យល់ប៉ុន្មានទេ តែនាងបានកត់អ្វីដែលខ្ញុំនិយាយ នៅក្នុងសៀវភៅសរសេររបស់នាង។ ប៉ុន្តែនិយាយតាមត្រង់ទៅ បើប្រៀបធៀបពីកាលដែលខ្ញុំទើបនឹងជួបនាង នៅពេលនោះ នាងមិនដឹងសូម្បីតែជប៉ុនដែលបានធ្វើសហប្រតិបត្តិការទៅលើថ្នាលដ៏

ច្រើននៃប្រទេសកម្ពុជា នៅឯណាផង ឃើញថានាងបានចេះនិងយល់ច្រើនណាស់។

- លោកគ្រូចង់ប្រាប់នាងថា អតីតកាលដែលខ្មែរធ្លាប់ជាសិស្សរបស់ឥណ្ឌពុំមែនជាអាការៈខ្ចាស់អៀននឹងទាំងអស់។ វប្បធម៌តោងតែជួបប្រសព្វគ្នាដើម្បីបង្កើតវប្បធម៌ថ្មីមួយទៀត ឬដើម្បីឱ្យមានវឌ្ឍនភាព។

យើងរៀនជាមួយគ្នាបាន៧ខែហើយ ។ខ្ញុំឃើញថារតន៍នារីឆ្លាតណាស់។ នាងខិតខំចង់ដឹងពីវប្បធម៌របស់ប្រទេសនាង ឆ្លងកាត់តាមវប្បធម៌ប្រទេសផ្សេងទៀត ដោយនាងហាត់រាំរបាំក្បាច់បុរាណខ្មែរ ដែលមិនមែនចង់បង្ហាញភាពឆើតឆាយទេ តែជាការបង្ហាញនិងការហាត់ពត់ចិត្តឱ្យបរិសុទ្ធដូចទេពនារី ហើយផ្តល់ក្តីសង្ឃឹម សុភមង្គលដល់អ្នកដែលមកមើលរបាំនេះ។

នៅក្នុងជីវិតពិតប្រាកដ ក៏នាងជាទេពអប្សរដ៏រស់រវើកមិនអាចប្រកែកបាន។ នាងបានអញ្ជើញខ្ញុំទៅមើលការសម្តែងរបស់នាងដែរ ប៉ុន្តែខ្ញុំពុំដែលមានឱកាសទៅមើលម្តងណាទេ។

ពេលបន្ទាប់មកទៀត យើងបានរៀនពីប្រទេសចិន។

ខ្ញុំបានសរសេរអត្ថបទមួយ និយាយរៀបរាប់ពីប្រទេសចិន។ ប្រទេសចិនបានកសាងមហាកំពែង ដើម្បីទប់ទល់នឹងការឈ្លានពានរបស់ប្រទេសជិតខាង គឺប្រទេស គៀរ៉ាដូ (ម៉ុងហ្គោលី បុរាណ) នៅសតវត្សទី ២មុនគ្រិស្តសករាជ។

ខ្ញុំបានឱ្យនាងរកប្រទេសចិននៅក្នុងផែនទី។ ខុសពីកុមារនៅប្រទេសជប៉ុន រតន៍នារី រីករាយនឹងរកណាស់។ ខ្ញុំឃើញនាងសប្បាយដូចក្មេងកំពុងលេង ល្បែង។ បន្ទាប់មកនាងទាញយកចង្អុលដៃខ្ញុំទៅចុចលើទីកន្លែងដែនដីចិន។

- នេះ!

រួចហើយនាងសើចហាក់ដូចជាត្រេកអរសំបើមអស្ចារ្យ។ ប៉ុន្តែមួយសន្ទុះមក នាងឈ្ងោកសម្លឹងមើលយ៉ាងយូរ ហើយសួរខ្ញុំជាភាសាអង់គ្លេសមួយៗ ដោយថ្មីៗនេះ ខ្ញុំកំណត់នាងឱ្យរៀននិយាយជាអង់គ្លេសឱ្យបានច្រើននៅពេលរៀន :

- លោកគ្រូ ប្រទេសចិនធំណាស់។

- ត្រូវហើយ ប្រទេសចិនក្តី ឥណ្ឌាក្តី សុទ្ធសឹងជាប្រទេសមហាអំណាចធំណាស់នៅបុរាណកាល។ លោកគ្រូបានបង្រៀននាងថា ប្រទេសឥណ្ឌាលូតលាស់ខាងគំនិត និង ខាងទស្សនៈ។ គេមិនត្រឹមតែគិតពីបច្ចុប្បន្នកាល ឬ អនាគតកាល១០ឆ្នាំ ឬ ១០០ឆ្នាំទៅមុខទេ គេគិតដល់ទៅក្រោយវេលាដែលគេស្លាប់ហើយទៅទៀត។ នាងជាអ្នកកាន់ព្រះពុទ្ធសាសនា នាងដឹងហើយ។

រតន៍នារីនៅស្ងៀម។ នៅពេលដែលនិយាយពីប្រធានបទលំបាក ខ្ញុំបញ្ចូលភាសាខ្មែរខ្លះៗ ឱ្យនាងយល់។ វេលានោះ រតន៍នារី យកមាត់នាងមកដាក់ក្បែរត្រចៀកខ្ញុំ ខ្សឹបតូចៗថា :

- លោកគ្រូនិយាយខ្មែរទាំងអស់ទៅ រតន៍នារីមិនជំរាបលោកតាទេ។ នេះជាការសម្ងាត់រវាងយើងតែពីរនាក់គត់។

នៅពេលដែលនាងលោមកខ្សឹបក្បែរត្រចៀកខ្ញុំដោយស្មោះត្រង់សោះ ខ្ញុំទៅជាមានអារម្មណ៍ផ្តេសផ្តាស រវើរវាយ សឹងតែមិនជឿខ្លួនឯង។

បុរសភេទហាក់ដូចជាសត្វដែលរស់នឹងសភាវៈគតិ ឆាប់ស្រើប ឆាប់ទទួលអារម្មណ៍ ហើយដែលខ្ញុំពុំទាន់ជឿថា អារម្មណ៍នោះ ជាសេចក្តីស្នេហាបុរស-ស្ត្រី ឬក៏គ្រាន់តែជាអារម្មណ៍ ដែលកំរើកម្តងម្កាលនៅពេលដែលយើងស្រើបស្រាលរំភើប ដូចនៅពេលដែលយើងឃើញគំនូរល្អ ឬស្តាប់ភ្លេងពិរោះ ឬយ៉ាងណាឡើយ។

រតន៍នារីគឺជាកុមារីសុទ្ធសាធ។ ខ្ញុំជាគ្រូរបស់នាង ដែលនាងជឿ ហើយគោរពជានិច្ចជាកាល។ ដូច្នេះការគិត ឃើញសញ្ចេតនាបែបនេះ គឺជាការមិនគួរសមទាល់តែសោះ។ ហើយម្យ៉ាងទៀត គឺជាទង្វើក្បត់កិច្ចសន្យា រវាងលោកឧកញ៉ាជាជីតារបស់នាងថែមទៀតផង។

ខ្ញុំបាននិយាយពន្យល់នាងជាភាសាខ្មែរ តាមសំណូមពររបស់នាង។ ខ្ញុំធ្វើដោយជំនឿថា សិស្សរបស់ខ្ញុំអាចក្រេបចំណេះវិជ្ជាមួយជាការចាំបាច់សំរាប់នាងនៅពេលដែលនាងទៅជានារីពេញវ័យម្នាក់នៅវេលាក្រោយ ឬចំណេះនេះអាចមានប្រយោជន៍ដល់នាង នៅពេលដែលនាងចូលជំនុំចំណោមអន្តរជាតិនៅទីណាមួយ។ ខ្ញុំស្តាយតែម្យ៉ាង ដោយខ្ញុំពុំសូវដឹងពីខ្មែរ ព្រោះខ្ញុំពុំសូវចេះបារាំង។ ឯកសារដែលស្រាវជ្រាវពីខ្មែរ ច្រើនតែសរសេរដោយជនជាតិបារាំងផង ម្យ៉ាងទៀតខ្មែរមិនសូវមានឯកសារដែលនិយាយពីប្រជាជនធម្មតាផង ឬក៏ចំណារពីប្រវត្តិសាស្ត្រ ទំនាក់ទំនងជាមួយនឹងប្រទេសផ្សេងផង។

ជនជាតិខ្មែរនាជំនាន់មហានគរ ប្រហែលជារៀនវិជ្ជាទាំងឡាយពីព្រាហ្មណ៍បុរោហិត ដែលជាគ្រូពីទស្សនៈផ្សេងៗរបស់ឥណ្ឌាហើយ។ គេប្រហែលជារៀនពីព្រះពុទ្ធសាសនាផង ពីគម្ពីរវេទទាំងឡាយ និងឧបនិស្ស័ទផង ពីព្រហ្មញ្ញសាសនាផងក៏មិនដឹង។ ស្តាយណាស់ដោយវេលានោះ អ្វីៗដែលទាក់ទងទៅនឹងព្រះមហាក្សត្រ ទើបគេយល់ថាជាការសំខាន់ ហើយគេយកព្រឹត្តិការណ៍នោះ ទៅឆ្លាក់ជាអក្សរនៅលើថ្មទុក ឯព្រឹត្តិការណ៍ដទៃទៀត ដែលមនុស្សជំនាន់នោះយល់ថាជាការបន្ទាប់បន្សំ គេចារទុកនៅលើស្លឹករឹត ឬស្បែកសត្វ ដែលនាំឱ្យពុកបាត់បង់ ហើយពុំមានកំណត់អ្វីដែលចារពីប្រជាជនធម្មតា ឬហេតុការណ៍ដែលមិនមានទំនាក់ទំនងនឹងស្តេចគ្រងរាជឡើយ។

ជាការមួយគួរឱ្យស្តាយ គឺខ្មែរគ្មាននៅសល់កំណត់ណាមួយ ដែលចារពីទំនាក់ទំនងជាមួយចិនទេ។ ប៉ុន្តែនៅក្នុងគម្ពីប្រវត្តិសាស្ត្រចិនមានចារថា អ្នកប្រាជ្ញខ្មែរពីររូបដែលចេះភាសាសំស្ក្រឹត និងចិនច្បាស់លាស់ បានទៅជួយបកប្រែព្រះធម៌ដែលព្រះសង្ឃចិន (ព្រះគ្រូថាំងចេងទៅចម្លងធម៌)ទៅចម្លងពីឥណ្ឌាមក។ រឿងនេះមានសរសេរក្នុងរឿង សាមកុក ចិន។ ប៉ុន្តែខ្ញុំបានសរសេរត្រួសៗ ជាអត្ថបទសំរាប់បង្រៀននាង។

វប្បធម៌ចិន ក៏ជាវប្បធម៌មួយដ៏ចាស់ដែលមានអាយុ៥ពាន់ឆ្នាំហើយ។ យើងឃើញមានមហាកំពែង៦៧០០គីឡូម៉ែត្រ និងផ្នូរបុរាណដែលមានកប់ចម្លាក់ សេះចម្លាក់មនុស្សដែលមានទំហំប៉ុនទំហំពិត៧០០០រូប។ បន្ទាប់មក មានទស្សនវិទូរជាច្រើន ជាអាទិ៍គឺ កុងស៊ឺ ដែលជាប្រវត្តិវិទូរ ហើយជាអតីតអ្នកនយោបាយ។ ពាក្យប្រដៅដ៏ល្បីល្បាញរបស់កុងស៊ឺគឺ :

បើយើងខិតខំសិក្សារឿងរ៉ាវពីដើមឱ្យយល់ច្បាស់ យើងនឹងអាចទាញការពិសោធន៍ គំនិតថ្មីៗ និងចំណេះថ្មីៗ សំរាប់អនាគតកាលបាន។ ទោះបីជាយើងខិតខំរៀន ហើយមានចំណេះវិជ្ជាច្រើនយ៉ាងណាក៏ដោយ បើយើងមិនត្រិះរិះគិតឱ្យបានជ្រៅជ្រះពីអត្ថន័យនៃចំណេះវិជ្ជានោះទេ យើងនឹងមិនអាចយល់ន័យពិតប្រាកដនៃចំណេះនោះឡើយ។

តោងរៀនតាំងពីនៅតូច ព្រោះពេលវេលាចេះតែទៅមុខហើយ។

ទស្សនៈរបស់ចិន គឺបង្រៀនរបៀបរស់នៅរាល់ថ្ងៃ ធ្វើយ៉ាងម៉េចឱ្យទៅជាអ្នកមាន ធ្វើយ៉ាងណាឱ្យច្បាំងឈ្នះគេ ជាដើម។ រតន៍នារីបាននិយាយថាទស្សនៈចិននេះក៏ល្អម្យ៉ាងដែរ។ ឥណ្ឌាគិតពីទស្សនវិជ្ជាជីវិតដោយសុភមង្គលខាងផ្លូវស្មារតីនិងបរមសុខ ឯចិន គិតពីសុភមង្គលផ្នែកសម្ភារៈនិងលោកិយ។

# ជំពូកទី២

រតន៍នារីហើយនិងខ្ញុំ បានស្គាល់គ្នាជាងមួយឆ្នាំហើយ។ ហើយក្នុងរយៈកាលនេះ នាងបានអញ្ជើញខ្ញុំឱ្យទៅមើលនាងសំដែងរបាំ ពីរដង។ លោកឧកញ្ញាក៏បានបង្ហាញភាពរាក់ទាក់មកលើខ្ញុំជាងមុនបន្តិចដែរ។ នៅពេលដែលនាងរាំ ខ្ញុំបានចាប់អារម្មណ៍ថា បេះដូងរបស់ខ្ញុំ តែងតែកំរើកអស្ចារ្យ ចាប់តាំងពីពេលដែលវង់ភ្លេងពិណពាទ្យចាប់ទូងស្គរខ្លុងចាប់ផ្តើមប្រគុំម្ល៉េះ។ ទឹកមុខដ៏ញញឹម តូចខ្ពង់ខ្ពស់របស់នាង នាំឱ្យខ្ញុំឃើញនាងខុសពីរូបនាង ដែលជាកុមារីសុទ្ធសាធ នៅពេលដែលនាងរៀនវិជ្ជាជាមួយខ្ញុំ។ នាងលាបម្សៅ គូសភ្នែក ពាក់រោមភ្នែកដាក់ ពាក់អាវវាលរីតក្លឹ ជាប់នឹងខ្លួន នាំឱ្យឃើញរាងកាយនាងទាំងមូល ច្បាស់។

វេលាដែលខ្ញុំទៅមើលនាងរាំលើឆាក គឺជាពេលដែលចិត្តខ្ញុំគិតឥតសំរាកពីនាង។ តើអារម្មណ៍នោះជាអ្វី? តើរតន៍នារីដែលនៅលើឆាក និងរតន៍នារីដែលនៅជិតខ្ញុំ នៅល្ងាចថ្ងៃច័ន្ទ និងថ្ងៃពុធ ជារូបរាងផ្សេងគ្នា ឬយ៉ាងណា?

ខ្ញុំតែងតែរំឭកឃើញនាង ដែលនិយាយថា ភាសាអង់គ្លេសក៏ម្យ៉ាងដែរ ប៉ុន្តែរតន៍នារី ចង់រៀនភាសាជប៉ុនណាស់។ នាងសរសើរខ្ញុំថា ខ្ញុំស្លូត ហើយទន់ភ្លន់។ នាងគិតថា ភាសាជប៉ុនប្រហែលជាទន់ភ្លន់ ហើយពិរោះណាស់។ ខ្ញុំបានបង្រៀននាង ពីពាក្យជប៉ុនខ្លះៗ ដូចជាពាក្យថា អរគុណ ពាក្យថា ឆ្ងាញ់ ពាក្យថា សប្បាយ ជាដើម។

ពេលដែលឃើញនាងរាំនៅលើឆាក ហើយដែលខ្ញុំបានចាត់ទុកថា នាងជានារីពេញរូបរាងនោះ ហើយដែលនាំឱ្យខ្ញុំចាប់លបលួចគិតពីនាង ហើយសញ្ចេតនាដ៏ស្រងេះស្រងោចម្យ៉ាងបានមកលងខ្ញុំ នាំឱ្យខ្ញុំ ទៅជារំភើបនូវគ្រប់កាយវិការដដែល ឥតកែប្រែរបស់នាងផង ទៅលើការយកចិត្តទុកដាក់មកលើភាសាខ្ញុំ ប្រទេសខ្ញុំ ផង ។

នៅវេលាដែលឃើញនារីដ៏ខ្ពង់ខ្ពស់ថ្លៃថ្នូរនេះ ស្រឡាញ់និងបង្ហាញនូវការជាប់ជំពាក់ចិត្តមកលើប្រទេសជាតិរបស់ខ្ញុំបែបនេះ ខ្ញុំក៏ចាប់លបលួចគិតថា នាងមានអារម្មណ៍យ៉ាងម៉េចមកលើខ្ញុំ? ទោះបីជាខ្ញុំដឹងថា នេះគឺជាសុបិននិមិត្ត សុទ្ធសាធ ព្រោះយើងមិនអាចនឹងទៅជាប្តីប្រពន្ធនឹងគ្នា នាអនាគតបានឡើយ ក៏ដោយ។ នៅពេលដែលខ្ញុំត្រឡប់ទៅស្រុកជប៉ុនវិញ ការពិតដែលរង់ចាំខ្ញុំគឺ ខ្ញុំមិនច្បាស់ ថាខ្ញុំនឹងធ្វើការងារអ្វីទេ។ ឪពុកម្តាយខ្ញុំជាអ្នកមានបង្គួរមែន ប៉ុន្តែទំនៀមទំលាប់យើង មិនអនុញ្ញាត ឱ្យយើងទទួលជំនួយពីគាត់ ឬឱ្យឪពុកម្តាយយើងជួយចិញ្ចឹមយើងដែលមានដៃមានជើងឡើយ។ មុននឹងចេញមកប្រទេសកម្ពុជា ខ្ញុំមានតែគំនិតម្យ៉ាងគឺ នៅពេលអនាគត បើខ្ញុំវិលមកប្រទេសជប៉ុនវិញ ខ្ញុំនឹងចូលទៅធ្វើការនៅក្រុមហ៊ុនតូចតាច ល្មមតែឱ្យខ្ញុំបានប្រាក់ខែសំរាប់ចិញ្ចឹមជីវិត ឬក៏រកភរិយាដែលធ្វើការដែរ ដើម្បីជួយទប់ទល់គ្នាទៅវិញទៅមក។ បើមិននោះសោតទេ ខ្ញុំនឹងរស់នៅស្រុកខ្មែររហូត រៀបការជាមួយនារីណាម្នាក់ ដែលខ្ញុំស្រឡាញ់ ហើយដែលស្រឡាញ់ខ្ញុំដែរ។ ខ្ញុំមិនដែលយល់សប្តិ ឬមួយគិត ឃើញទាល់តែសោះថា ខ្ញុំនឹងជំពាក់ចិត្តនឹងនារីដែលស្ថិតនៅក្នុងឋានៈខ្ពស់បែប នេះ។

ឧបមាថា រតន៍នារី ក៏មានចិត្តបេត្តី មកលើរូបខ្ញុំដែរទៅចុះ ហើយខ្ញុំត្រូវនាំនាងមករស់នៅតូក្យូ តើខ្ញុំអាចឱ្យរតន៍នារីចេញទៅធ្វើការ រកលុយមកបង្គ្រប់ជីវភាពរបស់យើងបានឬទេ។ ហើយបើខ្ញុំនៅប្រទេសកម្ពុជាធ្វើការងាររកលុយម៉ោង ពុំមានយសសក្តិបែបនេះ លោកឧកញ្ញាច្បាស់ជាមិនឱ្យចៅលោក មកមនុស្សដែលមិនមានឋានៈ នាំឱ្យអាប់កិត្តិយសរបស់លោកឡើយ។ និយាយពីគូ

កំណត់របស់នាង គេមានមុខមាត់មិនសូវស្អាតបាតមែន តែគេជាកូនប្រធានក្រុមហ៊ុនធំមួយ។ គេតែងតែមកលេងនាងញឹកញាប់ណាស់ បើតាមខ្ញុំដឹង។

ថ្ងៃមួយ នៅពេលដែលខ្ញុំមកដល់បន្ទប់ដែលយើងរៀនជាមួយគ្នារាល់ដង ខ្ញុំឃើញនាងអង្គុយចាំខ្ញុំ ហើយនាងនិយាយទាំងស្រងូតថា : លោកគ្រូ ខ្ញុំនឹងរៀបការហើយ។ ដោយជាការប្រថុចញ៉ុចពេក ខ្ញុំពុំមានពេលគិត ឬសោកសង្រេងឡើយ ខ្ញុំបានជូនពរនាង តែនាងធ្វើមុខស្រងូត។ ខ្ញុំក៏សួរនាងថា តើនាងមិនសប្បាយចិត្តនឹងរៀបការទេ ឬ? រតន៍នារី ឆ្លើយថា រៀបការ ឬមិនរៀបការជាមួយនាង គឺជាការធម្មតា មិនមែនជាបញ្ហាអ្វីទាល់តែសោះ។ តែនាងលំបាកចិត្តដោយនាង នឹងឈប់បានជួប ឈប់បានរៀន ឈប់បានស្តាប់មេរៀន ដ៏សប្បាយដ៏គួរឱ្យចាប់អារម្មណ៍ របស់ខ្ញុំទៀតហើយ។

ខ្ញុំភ្ញាក់ក្រៃលែង។ នាងគិតថា រៀបការ ឬមិនរៀបការ ជាការធម្មតា? បានន័យថា ទោះជារៀបការជាមួយនឹងមនុស្សដែលនាងពុំមានសេចក្តីស្នេហាទាល់តែសោះ ក៏នាងព្រមដែរឬ? នេះជាទំនៀមទំលាប់មួយ ដែលខ្ញុំមិនអាចយល់បានទាល់តែសោះ។ តើរបបរៀបការជាស្វាមីភរិយារបស់ជនជាតិខ្មែរ គឺសំរាប់តែបន្តពូជតទៅមុខទៀតតែម្យ៉ាងទេ ឬយ៉ាងណា? ខ្ញុំទៅជាមិនសុខ មិនសាប់ ចិត្ត។ ខ្ញុំហាក់ដូចជាដុះទឹកចិត្តម្យ៉ាងចម្លែកថា ខ្ញុំគោងតែការពាររតន៍នារី ត្រូវតែឱ្យនាងរៀបការជាមួយបុរស ដែលនាងស្រឡាញ់។ ប្រហែលជានៅក្នុងជំរៅចិត្តរបស់ខ្ញុំ ៗ ចង់ដឹងថាតើនាងស្រឡាញ់នរណា? ពេលនោះ ខ្ញុំក៏ដើរតួ ធ្វើជាអ្នកដែលទទួលភារកិច្ចពិគ្រោះបញ្ហាផ្លូវចិត្តរបស់នាង។ រតន៍នារី និយាយយ៉ាងស្មោះត្រង់ថា នាងពុំមានស្រឡាញ់អ្នកណាទេ។ តែនាងចង់នៅជិតខ្ញុំ ចង់សាកសួរពីអ្វីៗជាច្រើន។ នាងប្រហែលជាស្រឡាញ់ខ្ញុំ ជាខ្លាំងបាត់ទៅហើយ។ ហើយប្រសិនបើខ្ញុំមិនស្រឡាញ់នាងទេ សូមឱ្យខ្ញុំបំភ្លេចពាក្យនេះ។

ខ្ញុំរំភើបចិត្តស្ទើរតែស្រែកប្រកាសប្រាប់មនុស្សម្នាទាំងឡាយថា ខ្ញុំឈ្នះហើយ។ ខ្ញុំជាមនុស្សមានជោគជ័យ មានសំណាង ជាងមនុស្សប្រុសនានា ឯណាទាំងអស់នៅក្នុងពិភពលោកយើងនេះ។ ខ្ញុំអង្វរនាង កុំឱ្យនាងរៀបការ។ ខ្ញុំនឹងពន្យល់លោកឧកញ្ញាមហាមន្ត្រីឱ្យលោកយល់ ឱ្យលោកបានជ្រាបថា សម័យឥឡូវ ខុសពីសម័យមុន។ គេគោងតែស្រឡាញ់គ្នាទើបរៀបការជាមួយគ្នា រស់នៅជាមួយគ្នាទៅមានសុភមង្គល។

ប៉ុន្តែ លោកឧកញ្ញាមិនព្រមយល់ទាល់តែសោះ។ លោកមានប្រសាសន៍ថា អ្វីដែលខ្ញុំនិយាយ គឺសំអាងទៅលើគំនិត និងស្មារតីរបស់ជប៉ុន ឬបញ្ចឹមប្រទេសទាំងអស់។ ខ្មែរតាំងពីដូនតាឯណាមក ធ្លាប់តែប្រកាន់ទំនៀមទម្លាប់នេះ ហើយមិនដែលឃើញខ្មែរឯណាលែងលះប្តីប្រពន្ធ ដែលឪពុកម្តាយផ្គុំផ្គងឱ្យទេ។ ហើយលោកបានបង្ខំខ្ញុំឱ្យឈប់លូកដៃចូលក្នុងរឿងគ្រួសាររបស់លោក។

ខ្ញុំនឹកឃើញដល់រឿងកុនមួយ ដែលលេងនៅកម្ពុងឆ្នាំ១៩៧៧ -៧៨ ដែលតួឯកប្រុសទៅពង្រត់តួឯកស្រីដែលកំពុងតែរៀបការ នៅព្រះវិហារ។ ខ្ញុំមិនប្រាថ្នាដល់ទៅធ្វើបែបនេះ នៅប្រទេសកម្ពុជាទេ ប៉ុន្តែខួរក្បាលខ្ញុំនៅតែគិតថា បើយើងទាំងពីរស្រឡាញ់គ្នា ហើយរតន៍នារីចង់នៅជិតខ្ញុំ ខ្ញុំចង់នៅជិតនាង យើងមានសិទ្ធិពេញទំហឹង នឹងរស់នៅជាមួយគ្នា។ អ្វីដែលខ្ញុំបានគិតពីមុន ដែលជាគំនិតពិតជាក់ស្តែង ស្រាប់តែរលុបរលាយបាត់ពីខ្លួនខ្ញុំអស់រលីង។

ខ្ញុំបានសួរទៅលោកឧកញ្ញាមហាមន្ត្រីថា តើខ្ញុំត្រូវមានលក្ខណៈអ្វីខ្លះ ដើម្បីឱ្យខ្ញុំអាចយកជ័យជម្នះក្នុងការដណ្តើមយករតន៍នារីបាន។ លោកបានឆ្លើយជា

ដាច់អហង្កាថា គ្មានអ្វីទាំងអស់។ ខ្ញុំបានពន្យល់លោកថា សូម្បីតែព្រះរាម ក៏លោកមានសិទ្ធិនឹងលើកធ្នូរស ដើម្បីយកនាងសីតាដែរ។

លោកឧកញ្ញាមហាមន្ត្រី ជាមនុស្សរឹងរូសណាស់ ព្រោះលោកជាអ្នកកាន់ការងារសំខាន់ក្នុងប្រទេស ហើយទំលាប់លោកបានក្លាយទៅជា ទំនៀមមួយ ដែលខ្ញុំជាអ្នកដទៃពិបាកនឹងកែប្រែណាស់។

ឯរតន៍នារីវិញ នាងទៅជាស្រពោនស្ងប់ស្ងាត់ដោយឃើញខ្ញុំប្ដូរផ្ដាច់ស្រឡាញ់នាងជម្នះចង់បាននាងបែបនេះ។ ដោយនាងជំពាក់ចិត្តមកលើខ្ញុំស្រាប់ផង នាងអាណិតខ្ញុំ នៅពេលដែលខ្ញុំសំពះអង្វរករជីតារបស់នាង ហើយលោកមិនព្រមខិតខំស្ដាប់ពាក្យពន្យល់របស់ខ្ញុំ បែរជាប្រើតែពាក្យដាច់អហង្កាថា ទេ តែមួយម៉ាត់ ដែលមើលទៅឃើញថា ការចង់ចូលជំនុំចំណោមអន្តរជាតិ និងគំនិតចាស់គំរិលរបស់លោក វាឃ្លាតគ្នាឆ្ងាយដូចមេឃហើយនឹងដី។

ថ្ងៃមួយ ខ្ញុំឃើញនាងជូនដំណើរលោកដែលហៀបនឹងឡើងឡាន ទៅក្រៅ។ រាល់ដងនាងតែងតែម្ចិកម្ចក់ដាក់លោក តែពេលនោះ នាងគ្រាន់តែថើបតបជីតានាងដែលឱនថើបថ្ងាសនាង របៀបអឺរ៉ុប។ ខ្ញុំចាំឱ្យលោកឧកញ្ញា ចេញដំណើរផុត នឹងអាលចូលទៅជួបនឹងនាង។

ឆ្មាំទ្វារដែលតែងតែលើកដៃគំនាប់ខ្ញុំ បានគំនាប់ខ្ញុំតាមធម្មតា។ នៅពេលដែលនាងឃើញខ្ញុំ រតន៍នារី បានញញឹមយ៉ាងស្ងប់ស្ងាត់មករកខ្ញុំ ហើយអញ្ជើញ ខ្ញុំចូលទៅបន្ទប់ទទួលភ្ញៀវ។

នាងបាននិយាយថា នាងបានជំរាបជីតានាងថា តើនាងអាច កែប្រែមិនរៀបការជាមួយនឹងលោកសំណាង បានទេ? ពីព្រោះ នាងបានស្រឡាញ់ខ្ញុំខ្លាំងណាស់។ ជីតានាងបានឆ្លើយថា ប្រសិនបើខ្ញុំ អាចនៅរស់ក្នុងប្រទេសកម្ពុជារហូត ហើយអាចរកប្រាក់មកទិញបុណ្យសក្តិ ជាឧកញ្ញាបាន ប្រហែលជាមានផ្លូវ។

ខ្ញុំបានសួរនាងថា តើត្រូវមានប្រាក់ប៉ុន្មាន? រតន៍នារីនិយាយថា យើងតោងតែមានប្រហែលជា១០ម៉ឺន ឬ ២០ម៉ឺន ដុល្លា។ រួចហើយខ្ញុំត្រូវតែចូលសញ្ជាតិខ្មែរ។

ការចូលសញ្ជាតិជាខ្មែរ ខ្ញុំគិតថាពុំមានបញ្ហាអ្វីធំដុំទេ ចំពោះខ្ញុំដែលគិតថារស់នៅទីណាក៏បាន នៅពេលដែលខ្ញុំចាកចេញពីជប៉ុនដំបូង។ ប៉ុន្តែចំពោះរឿងប្រាក់កាស គឺជាការលំបាក។ ប៉ុន្តែខ្ញុំចង់ខិតខំរកឱ្យអស់សមត្ថភាពសិនមុននឹងថាពុំអាចធ្វើបាន ពីព្រោះខ្ញុំក៏បានជាប់ជំពាក់ចិត្តទៅលើនាងខ្លាំងណាស់ទៅហើយដែរ។

ខ្ញុំនឹកឃើញ អ៊ី-មែល ចម្លែកមួយដែល បានផ្ញើចូលមកក្នុងប្រអប់មែលរបស់ខ្ញុំ។ ជាទូរសារពីមេធាវី ជនជាតិនីហ្សេរីម្នាក់ឈ្មោះជីវ៉ាថា : មានមេទាហានចូលនិវត្តន៍ នីហ្សេរីម្នាក់មានលុយចំនួន ១៥ លានដុល្លា ផ្ញើទុកនៅកន្លែងផ្ញើមួយ នៅប្រទេសហុលឡង់ដ៍។ ដោយសារតឡូវនេះ អាមេរិកកំពុងទាមទារឱ្យស្រាវជ្រាវសើរើរឿងពុករលួយរបស់មន្ត្រីធំៗពីដើម គេចង់ឱ្យអ្នកណាម្នាក់ដែលអាចចេញចូល បរទេសបានដោយសេរី ទៅទទួលយកលុយ នោះជំនួសគេ ហើយយកទៅបើកគណនីយមួយដើម្បីប្រើលុយនោះសំរាប់វិនិយោគទុនជំនួសគេ។ ជាសាគុណគេនឹងជូន ៣០ ភាគរយ ។

ខ្ញុំធ្លាប់បានគិតថា មិនដែលមានរឿង ដែលរកលុយបានធូរ បែបនេះដោយគ្មានរនុកទេ។ ប៉ុន្តែនៅខណៈដែលខ្ញុំត្រូវការលុយ ខានមិនបានបែបនេះ ខ្ញុំបានគិតផ្សេងទៅវិញថា ទូរសារពីមនុស្សដែលខ្ញុំមិនស្គាល់នេះ ប្រហែលជាព្រេង

វាសនាអ្វីដែលសំរាប់ផ្ទាប់ខ្ញុំនិងរតន៍នារី ឱ្យបានជាគូស្រករនឹងគ្នាហើយ។ ខ្ញុំបានតប អ៊ីមែល ទៅមេធាវីអាហ្វ្រិកនោះថា ខ្ញុំស្ម័គ្របំពេញការងារនោះជំនួសពួកគេដែលមិនអាចចេញក្រៅប្រទេសបាន។ គេបានផ្ញើរសំបុត្របញ្ជាក់តាមផ្លូវច្បាប់ចារឈ្មោះខ្ញុំស្រួលបួល ថាជាអ្នកដែលមានសិទ្ធិទៅទទួលលុយដែលផ្ញើពីនីហ្សេរី ទៅអាំស្ទែរដាំ តាមក្រុមហ៊ុនដឹកជញ្ជូនមួយឈ្មោះ យូនីហ្គុឡូប។

មុនពេលដែលខ្ញុំចេញដំណើរទៅហុលឡង់ដ៏ គេបានផ្ញើរអ៊ីមែលថ្មីមួយទៀតមកថា គេតម្រូវឱ្យខ្ញុំចេញថ្លៃ រក្សាលុយនោះចំនួន មួយម៉ឺនពីរពាន់ដុល្លាសំរាប់រយៈពេលពីរឆ្នាំកន្លងមកហើយមុនសិន។ ខ្ញុំមិនយល់សោះ ពីចិត្តរបស់ខ្ញុំនៅពេលនោះ ដែលខិតខំធ្វើតាមពាក្យរបស់គេ ដោយគ្រាន់តែឃើញសំបុត្របញ្ជាក់ជាផ្លូវការបោះត្រាត្រឹមត្រូវ នឹងរូបថតប្រាក់ដុល្លាមួយកេសដែកធំ ដែលគេផ្ញើតាមអ៊ីមែលមកឱ្យខ្ញុំឃើញ។

មេធាវី បាននិយាយថា គេទុកចិត្តខ្ញុំ សូមកុំឱ្យខ្ញុំក្បត់គេឱ្យសោះ។ គេពុំអាចបើកគណនីយ ឈ្មោះគេបានទេ ព្រោះគេតោងតែលាក់ឈ្មោះគេផង គេទៅខ្លួនគេពុំបានផង។ ម្ចាស់គណនីយនៃប្រាក់១៥ លានដុល្លានេះគឺរូបខ្ញុំមែន ប៉ុន្តែម្ចាស់លុយពិតប្រាកដ គឺលោកមេទាហានចាស់ឯនោះទេ សូមឱ្យខ្ញុំស្បថ កុំក្បត់សន្យាឱ្យសោះ។

ខ្ញុំប្រមូលលុយដែលខ្ញុំខិតខំសន្សំទាំងប៉ុន្មាន ធ្វើដំណើរទៅហុលឡងដ៏។

មេធាវីបានឱ្យខ្ញុំទាក់ទងទៅនឹងក្រុមហ៊ុនផ្ញើរបស់នោះ មុននឹងចេញដំណើរទៅ។ យើងបានពិភាក្សាគ្នាថា ពេលខ្ញុំទៅទទួលយកលុយហើយ តើបុគ្គលិកក្រុមហ៊ុនដឹកជញ្ជូន អាចរកឡាន ព្រមទាំងរកមនុស្សជូនដំណើរខ្ញុំទៅដល់ធនាគារ បានឬទេ? អ្នកដែលនិយាយទូរស័ព្ទ បានឆ្លើយថា គេអាចធ្វើបាន។ គេបានប្រាប់ខ្ញុំថា ការិយាល័យរបស់គេ នៅក្បែរអាកាសយានដ្ឋាន។ បើជិះឡានត្រូវការពេលតែ ៥ នាទីទេ។

ខ្ញុំបានកក់បន្ទប់មួយនៅសណ្ឋាគារសេរ៉ាតុន ដែលនៅជិតអាកាសយានដ្ឋាន។

នៅពេលដែលខ្ញុំទៅដល់អាំស្ទែរដាំ ធាតុអាកាសរងា សឹងតែរឹងថ្គាម។ នៅប្រទេសកម្ពុជាកក់ក្តៅ ហើយខ្ញុំភ្លេចគិតថា នៅលើលោកយើងនេះ មានទីកន្លែងដែលរងាបាត់ទៅហើយ។ ខ្ញុំទាញអាវធំគ្រលំបិទ កុំឱ្យខ្យល់ត្រជាក់ប៉ះទ្រូងខ្ញុំបាន។ រួចហើយ ខ្ញុំក៏ប្រញិបប្រញាប់ធ្វើដំណើរទៅសណ្ឋាគារ។ បន្ទាប់ពីបានធ្វើសំបុត្រស្នាមសំរាប់សំរាក ហើយឡើងទៅដល់បន្ទប់ហើយ ខ្ញុំក៏ទូរស័ព្ទទៅក្រុមហ៊ុន យូនីហ្គូឡូប។ វេលាយប់នោះ មានជនជាតិស្បែកខ្មៅម្នាក់ មកគោះទ្វារបន្ទប់ខ្ញុំ ហើយចូលមកដោយនិយាយថា គេជាបុគ្គលិកនៃក្រុមហ៊ុនដឹកជញ្ជូននោះ។ ជននោះដកនាមប័ណ្ណតូចមួយឱ្យមកខ្ញុំ។ គេនិយាយភាសាអង់គ្លេសដែលមិនសូវជាច្បាស់ថ្លៃផ្ទរទេ ហើយប្រាប់ខ្ញុំថា ស្អែកម៉ោង១០ ព្រឹក គេនឹងឱ្យគ្នាគេយកឡានមកទទួលខ្ញុំទៅក្រុមហ៊ុនគេ។

វេលាព្រឹកនៅស្រុកនេះ មេឃស្រទំហាក់ដូចជាធ្ងន់ ស្ទើរតែរលំស្រុតមក។ អារម្មណ៍របស់ខ្ញុំនៅពេលនោះក៏ធ្ងន់ដូចជាមេឃនោះដែរ។ ខ្ញុំនៅតែមិនអស់ចិត្តនឹងទង្វើដែលខ្ញុំកំពុងតែធ្វើនេះ។ តើវាជាអ្វី? ខ្ញុំកំពុងតែយល់សប្តិ ឬកំពុងតែស្ថិតនៅក្នុងសេចក្តីពិត។ ខ្ញុំរង់ចាំមនុស្សស្បែកខ្មៅដែលប្រាប់ខ្ញុំពីយប់ម្សិលថា គេនឹងមកទទួលខ្ញុំនៅម៉ោង ១០ ព្រឹក។ នៅតែបន្តិចទៀត នឹងដល់ម៉ោងសន្យាហើយ។ ខ្ញុំចាំគេយ៉ាងយូរច្រាសច្រាល់។ ១០ នាទី, ១៥នាទី, ៣០នាទី។ ខ្ញុំនៅមិនសុខមិនសាប់ទាល់តែសោះ ដោយខ្ញុំគោរពពេលវេលាខ្ញុំជានិច្ចជាកាល។

ខ្ញុំបានទូរស័ព្ទទៅទូរស័ព្ទដៃរបស់ដៃគូរបស់ខ្ញុំ។ គេបានប្រាប់ខ្ញុំថា ចាំគេទូរស័ព្ទសួរគ្នាគេសិន។ ប៉ុន្តែខ្ញុំពុំឃើញគេទូរស័ព្ទតបមកខ្ញុំវិញទេ។ លុះដល់ម៉ោង ១១ នៅពេលដែលពុំឃើញគេទូរស័ព្ទមកខ្ញុំៗក៏ទូរស័ព្ទទៅទៀត។

ជននោះបានមកគោះទ្វារបន្ទប់ខ្ញុំ នៅម៉ោង ១១: ២០ នាទី ។ ខ្ញុំបាននាំគេចុះទៅក្រោម ដើម្បីខ្ញុំធ្វើសំបុត្រស្នាមចេញពីហូតែលនេះផងដែរ។ យើងបានចុះជណ្តើរយន្ត ហើយយើងបាននិយាយគ្នា សាកសួរគ្នាធម្មតា។ ខ្ញុំបានសួរពីគេដើម្បីឱ្យដឹងថា តើជននេះ មានស្ថានភាពគ្រួសារបែបណាផង តើគេជាមនុស្សត្រឹមត្រង់ ឬយ៉ាងណាផង។

យើងបានចេញទៅក្រៅ។ គេបាននាំខ្ញុំទៅដល់ឡានមួយ។ នៅក្នុងនោះ មានជនជាតិស្បែកខ្មៅម្នាក់អង្គុយនៅកៅអីកាន់ចង្កូត។ ជននេះមានមាឌធំ ដូចជាក្របីពាលី នៅក្នុងរឿងរាមកេរ្តិ៍។ គេទាំងពីរនាក់ចូលបាំងខាងមុខ ឯខ្ញុំ ចូលទៅអង្គុយនៅបាំងខាងក្រោយ។

ដោយយើងទាំងអស់គ្នា មិនដែលស្គាល់គ្នាផង ភាសានិយាយ ក៏ខុសគ្នាផង ពួកគេខ្មៅៗ មានមាឌធំ ខុសពីជប៉ុន ឬខ្មែរ ដែលខ្ញុំធ្លាប់និងសាំជិតជិត ខ្ញុំហាក់ដូចជាមានអារម្មណ៍មិនសុខមិនសាប់ក្នុងចិត្ត ខ្លាចតែពួកគេបោកឱ្យខ្ញុំយកលុយមកឱ្យគេ នឹងអាលគេសម្លាប់ខ្ញុំបំបាត់តាង។

ទោះបីជាគិតឃើញបែបនេះក្តី ខ្ញុំបានខិតខំសាកសួរគេ ពីនេះពីនោះ។ អ្នកទាំងពីរប្រហែលជាស្តាប់ភាសាអង់គ្លេសមិនសូវយល់ឬយ៉ាងណា ចំពោះសំណួរដែលខ្ញុំសួរគេ បួន ប្រាំឃ្លា ចម្លើយដែលតបមកវិញមានតែ មួយឃ្លា ឬជួនកាលគេធ្វើមិនឮក៏មាន។ សំណួរដំបូងរបស់ខ្ញុំ ចំពោះគេគឺ ហេតុអ្វីបានជាអ្នកមកយឺត? ខ្ញុំសួរមិនមែនដើម្បីចង់ឱ្យគេសុំទោសខ្ញុំទេ តែខ្ញុំឆ្ងល់ ដោយពីម្សិល គេបានប្រាប់ខ្ញុំថា ទីកន្លែងការិយាល័យរបស់គេ នៅជិតហូតែលរបស់ខ្ញុំផង ហើយឥឡូវនេះ យើងជិះឡានមកនេះ លើសប្រាំនាទីឆ្ងាយណាស់មកហើយ។

ចំពោះសំណួរនេះ គេធ្វើជាមិនឮ។

យើងបានជិះឡានយ៉ាងយូរ។ នៅពេលដែលរថយន្តបានធ្វើដំណើរប្រហែល ជា ២០ ឬ៣០ នាទី ទូរស័ព្ទរបស់បុរសដែលមកជួបខ្ញុំពីម្សិល ក៏រោទិ៍ ហើយគេបានឆ្លើយឆ្លងគ្នាជាភាសាដែលខ្ញុំមិនយល់ទាល់តែសោះ។ ប្រហែលជា ភាសាហុលឡង់ដ៏។ ខ្ញុំភ័យជាខ្លាំង ព្រោះខ្លាចតែគេហៅគ្នាគេមកស្ទាក់ផ្លូវ។

ប្រហែលជាកន្លះម៉ោង យើងក៏បានទៅដល់ការិយាល័យ យូនីហ្គឡូប។ អ្នកទាំងអស់អត់មាននិយាយអ្វីសោះ។ ក្នុងចំណោមនោះ មានម្នាក់ជាជនជាតិ ស្បែកស ។ គេស្លៀកពាក់ខោអាវធំ ខុសពីអ្នកឯទៀតដែលស្លៀកពាក់ខោអាវកម្មករ។

ការិយាល័យរបស់គេនៅជាន់ទី៣ នៃអាគារមួយដ៏ស្ងាត់ច្រៀប។ ប៉ុន្តែមានមណ្ឌលមួយដែលគេដាក់ការហេគ្គ ឬ វ៉ាហ្គុង ដូចទូរទេះភ្លើង តម្រៀបត្រៀបត្រា។ នៅមុខអាគារនោះ មានអាគារល្វែង របៀបដូចជា ផ្ទះល្វែងឈ្នួល។

បរិដ្ឋាននៅទីនោះស្ងាត់ណាស់ គ្មានមនុស្សដើរឡើយ។ ខ្ញុំបានគិតថា មនុស្សទាំងឡាយ ប្រហែលជាចេញទៅធ្វើការអស់ហើយ។

ការិយាល័យ ដឹកជញ្ជូននេះ មិនសមរម្យនឹងទទួលការដឹកជញ្ជូន របស់មានតម្លៃរាប់លានដុល្លា ដូចដែលគេ ផ្ញើសារប្រាប់ខ្ញុំទាល់តែសោះ។ បន្ទប់មានទំហំប្រហែលជា ៣០ ម៉ែត្រការេ មានតុពីរ។ តុមួយ មានម៉ាស៊ីន កុំព្យូទ័រមួយគ្រឿងនៅពីលើ ម៉ាស៊ីនថតចម្លងមួយ និងម៉ាស៊ីន ហ្វាក់ មួយ។ ឯតុមួយទៀត

ឥតមានអ្វីនៅពីលើទេ។ ជនសក់ស ឱ្យខ្ញុំបំពេញបែបបទសំណុំរឿងបញ្ជាក់ថា អ្នកនៅខាងនីហ្សេរីគេឱ្យមកទទួលតវ៉ាន់ជំនួសគេ។

វេលានោះ ពួកបុគ្គលិកដែលជាជនជាតិស្បែកខ្មៅពីរនាក់នោះបានថយទៅក្រោយ។ ខ្ញុំបានហុចនាមប័ណ្ណមួយសន្លឹកទៅអ្នកស្បែកស ដែលនៅជិតខ្ញុំ មើលខ្ញុំបំពេញក្រដាស។ គេបានរាវរកនាមប័ណ្ណ របស់គេដែរប៉ុន្តែមិនមាន។

ពេលដែលខ្ញុំហុច លិខិតបញ្ជាក់ពីអ្នកច្បាប់ថា ខ្ញុំជាអ្នកមានសិទ្ធិត្រឹមត្រូវនឹងមកទទួលរបស់បញ្ញើ ជនសក់ស ឆ្លើយថា គេជឿខ្ញុំហើយ មិនបាច់បង្ហាញទេ។ ខ្ញុំហាក់ដូចជាមានអារម្មណ៍ត្រេកអរក្រៃលែង ដោយគេជឿខ្ញុំ។ នៅទីនេះអ្វីៗហាក់ដូចជាប្រព្រឹត្តទៅដោយការជឿទុកចិត្តគ្នាទៅវិញទៅមកទាំងអស់។

គេបានឱ្យខ្ញុំបង់លុយដែលម្ចាស់លុយ ពុំមានលទ្ធភាពនឹងបង់សំរាប់ថ្លៃផ្ញើពីរឆ្នាំ ហើយនិងថ្លៃធានារ៉ាប់រងរបស់នោះ។ គេបានឱ្យខ្ញុំដឹងថា នៅពេលដែលមេទាហាននោះផ្ញើពីប្រទេសគេមក គេដាក់ថាទ្រព្យសម្បត្តិ ហើយគេបង់ប្រាក់ធានារ៉ាប់រងសំរាប់ ១៥ លានដុល្លា។ ខ្ញុំបានបញ្ចេញ ត្រាវេល័រហ្សេកមកបង់។ ប៉ុន្តែគេនិយាយថា នៅស្រុកនេះគេមិនទទួលហ្សេកទេ។ ខ្ញុំបានបំពេញទាំងសំបុត្រស្នាមសំរាប់បើកគណនីយ នៅធនាគារទៀតផង។

ខ្ញុំបាននិយាយសួរនាំគេលេងថា តើក្រុមហ៊ុនគេនេះ ទទួលអ្វីច្រើន។ គេឆ្លើយថា របស់ភាគច្រើនៗតែជាពេជ្យ ពីប្រទេសអាហ្វ្រិក។ ជនសក់ស បានបញ្ជាឱ្យអ្នកបើកឡានដែលដឹកខ្ញុំពីហូតែលមក ជូនខ្ញុំទៅដូរហ្សេកនៅធនាគារ។

នៅតាមផ្លូវ ខ្ញុំបានខិតខំរកប្រធានបទមកនិយាយ ជាមួយអ្នកបើកឡាននោះ។ ប៉ុន្តែ គេមិននិយាយជាមួយខ្ញុំទេ។ គេនៅស្ងៀម។ យើងធ្វើដំណើរតាមរថយន្ត ខ្លួនខ្ញុំពុំមានអារម្មណ៍នឹកចង់មើលក្រុង ឬប្រទេសរបស់គេឡើយ ខ្ញុំដូចជាមានការបារម្ភក្នុងចិត្តឥតល្ហែ។ តើខ្ញុំអាច ជឿពួកអ្នកនេះបានឬអត់។ នៅពេលដែលត្រូវដឹកប្រាក់កាក់ ខ្ញុំគោងតែធ្វើយ៉ាងណា? ខ្ញុំក៏និយាយជាមួយគេជាថ្មីទៀត។ តើនៅក្រុងនេះ កន្លែងណាសប្បាយ។ តើនៅក្រុងនេះសន្តិសុខល្អទេ។ គេឆ្លើយចុងមាត់ចុងក។

ប្រហែលជា២០នាទី យើងបានទៅដល់ធនាគារតូចមួយ ឈ្មោះ ហុងកុងសៀងហៃ បាំងគីង កាំប៉ានី។ គេរកកាតវីសារបស់ខ្ញុំ ។ ភ័ព្វល្អខ្ញុំមាន ខ្ញុំក៏អាចដូរហ្សេក ជាទឹកប្រាក់បាន។ ខ្ញុំបានត្រឡប់មកឡានវិញ ហើយឱ្យព្ធរប័រ(កម្រៃក្រៅ) អ្នកខំជូនខ្ញុំមក ៥០ ដុល្លាម្នាក់។ នៅវេលាដែលពួកគេបានលុយ គេក៏ចាប់ផ្តើមរាក់ទាក់ដាក់ខ្ញុំ។

ពួកគេនិយាយអង់គ្លេសបានធម្មតា ហើយពន្យល់ខ្ញុំថា អឺរ៉ុបសប្បាយណាស់។ យើងមានតែកាតសំគាល់ខ្លួន នឹងអាចដើរទៅប្រទេសនេះប្រទេសនោះ។ ខ្ញុំបានគិតថា បើពិភពលោកទាំងមូល ទៅជាបែបនេះ ជាការប្រសើរណាស់ ។

ខ្ញុំបាននិយាយលេងជាមួយអ្នកទាំងនេះ ក៏ធូរចិត្តបន្តិច។

នៅពេលដែលយើងត្រឡប់ទៅដល់ការិយាល័យវិញ ជនជាតិស្បែកសបានចុះមកទទួលខ្ញុំ។

ខ្ញុំបានបង់លុយឱ្យគេគ្រប់ចំនួនហើយ គេក៏ធ្វើហ្វាក់ទៅមន្ទីគយ។ ខ្ញុំចាំនៅក្នុងការិយាល័យ ១៥ នាទី។ មនុស្សពីរនាក់ដែលគេបាននិយាយប្រាប់ខ្ញុំថា ជាបុគ្គលិកមន្ទីគយបានសែង កេសដែកមួយមក។ គឺជាកេសដែក ដែលខ្ញុំបានឃើញរូបថត នៅក្នុងអ៊ីមែល។ គេបានបើកកេស នៅមុខខ្ញុំ ហើយឃើញច្បាស់ថាពិតជាលុយមែន។ ពួកគយនិយាយថា គេត្រូវការសំបុត្របញ្ជាក់ថាលុយនេះជាលុយដែលមិនមានទំនាក់ទំនងនឹងការធ្វើភេរវកម្ម និងគ្រឿងញៀន

ទេ។ ក្រោយពីភេរវកម្មនៅសហរដ្ឋអាមេរិក នៅខែកញ្ញាឆ្នាំ២០០១ មក ការបញ្ចេញលុយមានការតឹងរឹងណាស់។ គេឱ្យខ្ញុំសុំសំបុត្របញ្ជាក់ពីក្រសួងហិរញ្ញវត្ថុនៃប្រទេសម្ចាស់លុយ។ នៅពេលនោះ ជនជាតិសក់ស បានលោដៃ ទៅរកស្ពាបលុយ។ តែបុគ្គលិកគយបានគៀសដៃគេចេញ។ គេនិយាយថាលុយនេះនៅក្នុងឱវាតគយនៅឡើយ ដូច្នេះពុំអាចមានសិទ្ធិប៉ះពាល់បានទេ។

ខ្ញុំបានទូរស័ព្ទទៅនីហេរ្យី សួរមេធាវី។ មេធាវីថា គេនឹងទូរស័ព្ទទៅនាយទាហានជាម្ចាស់លុយ សួរយោបល់ពីគាត់សិន។

ខ្ញុំនៅចាំទូរស័ព្ទពីនីហេរ្យីរហូតដល់ម៉ោង៣ល្ងាច។ ពួកបុគ្គលិកយូនីគ្រូឡូបបានជូនដំណើរខ្ញុំដោយរថយន្តរបស់គេ ទៅហូតែលថ្មីរបស់ខ្ញុំ កាត់តាមភូមិរបស់ពួកអ្នកកាន់សាសនាអ៊ីស្លាមមួយ។ ទីនោះមានសរសេរអ្វីក៏ជាអក្សរ ដែលគេឃើញនៅក្នុងគម្ពីរកូរ៉ង់ដែរ។

ពួកគេជូនខ្ញុំទៅដាក់ហូតែលដែលខ្ញុំបានកក់ទុកតាមអ៊ីនធើរណេត។

គឺជាហូតែលតូចមួយ ដែលមានកូនច្រកទ្វារចូលតូចមួយ បិតទ្វារជិតឈឹង។ ខ្ញុំបានលាបុគ្គលិកក្រុមហ៊ុនដឹកជញ្ជូន ដែលសឹងតែបានក្លាយទៅជាមិត្តរបស់ខ្ញុំទៅហើយៗខ្ញុំបានធូរចិត្តបន្តិចថា លែងខ្លាចពួកគេដែលដឹងថា ខ្ញុំនឹងដឹកប្រាក់ដ៏ច្រើនទៅធនាគារ ហើយគេប្លន់ខ្ញុំ។

កូនហូតែលដែលខ្ញុំទៅសំណាក់នេះ មានម្ចាស់ជានារីអាល្លឺម៉ង់។ ការិយាល័យរបស់គេនៅជាន់ទី២។ មានបន្ទប់បាយនៅក្បែរនោះ។ អ្នកបំរើជា ជនជាតិអេហ្ស៊ីប។ គេនិយាយថា គេចូលចិត្តជប៉ុនណាស់ដោយជប៉ុនមិនរញ៉េរញ៉ៃដូចជនជាតិដទៃ។

នៅពេលយប់ខ្ញុំបានទទួលអ៊ីមែលពីមេធាវីនីហេរ្យី ថាគេមិនអាចធ្វើសំណូមពរទៅក្រសួងហិរញ្ញវត្ថុឱ្យចេញសំបុត្របញ្ជាក់ឱ្យទេ។ មូលហេតុគឺថា ខ្លាចរដ្ឋាភិបាលដឹង ហើយនឹងរឹបអូសយកប្រាក់អស់។ ឥឡូវនេះគណនីធនាគារទាំងអស់របស់ម្ចាស់ប្រាក់នោះបានត្រូវរដ្ឋាភិបាលបិទអស់រលីងហើយៗ គេពុំមានទាំងលុយដែលសំរាប់សងថ្លៃផ្ញើលុយនោះទុក និងថ្លៃធានារ៉ាប់រងលុយនោះ នៅក្រុមហ៊ុនដឹកជញ្ជូនផង ដូចដែលខ្ញុំឃើញស្រាប់មកហើយនេះ។

មេធាវីបានឱ្យខ្ញុំទាក់ទង សួរពួកក្រុមហ៊ុនដឹកជញ្ជូននោះ ថាតើពីមុនមកធ្លាប់មានករណីយ៏ បែបនេះឬទេ? ហើយឱ្យខ្ញុំទូរស័ព្ទទៅប្រាប់គេផង។

ខ្ញុំបានទូរស័ព្ទសួរជនដែលមករកខ្ញុំដំបូងបង្អស់នៅសណ្ឋាគារសេរ៉ាតុន។ អ្នកនោះបាននិយាយថា យើងចាំបាច់ត្រូវការរកមេធាវីម្នាក់ ឱ្យទៅទាក់ទងនឹងបុគ្គលិកមន្ត្រីនៃសហពន្ធ័ហិរញ្ញវត្ថុនៃអឺរ៉ុប ដើម្បីឱ្យគេបញ្ជាក់ថា លុយនេះមិនមានទំនាក់ទំនងអ្វីនឹងភេរវកម្ម ឬក៏គ្រឿងញៀនទេ។

គេបាននិយាយទៀតថា បើខ្ញុំចង់ឱ្យគេទាក់ទងឱ្យ គេអាចរត់ការឱ្យខ្ញុំបាន ប៉ុន្តែតោងតែបង់ប្រាក់ឱ្យមេធាវី យកទៅសូកមន្ត្រីដែលគេចេញសំបុត្រស្នាមឱ្យយើងទើបបាន។

ខ្ញុំមិនដែលនឹកឃើញទាល់តែសោះថា នៅអឺរ៉ុបក៏មានមន្ត្រីស៊ីសំណូកត្រង់ៗ បែបនេះ។ នៅប្រទេសខ្មែរ ដូចខ្ញុំធ្លាប់ឮភីលៀងរបស់រតន៏នារីនិយាយ គឺចិនឬថៅកែធំៗច្រើនតែយកសំណូកទៅសូកនាហ្មឺន ឬប្រពន្ធនាហ្មឺន ដើម្បីឱ្យខ្លួនអាចធ្វើអ្វីបានស្រេចតែអំពើចិត្ត ខុសច្បាប់ប្រទេស ក៏ពុំមានការចាប់ចង។ ហើយអំពើខុសច្បាប់នេះ នាំឱ្យខូចប្រយោជន៏ជាតិខ្លាំងណាស់។ ហើយខ្ញុំតែងតែស្អប់និងមើលងាយទង្វើ ឬអ្នកដែលប្រព្រឹត្តអំពើនេះណាស់។

ខ្ញុំរួញរាជាខ្លាំង។ ជនជាតិស្បែកខ្មៅបាននិយាយណែនាំខ្ញុំថា បើមិនមានសំបុត្រនោះទេ លុយតោងតែនៅទើត្រឹមគយហើយ ពុំដឹងធ្វើម៉េចទេ មានតែប្រើមធ្យោបាយនេះតែប៉ុណ្ណោះ។ ហើយការជូនកម្រៃទៅមេធាវី ឬមន្ត្រីសហព័ន្ធអឺរ៉ុប នេះមិននាំឱ្យអាក្រក់ទេ វានាំឱ្យគេអាចយកលុយទៅប្រើជាប្រយោជន៍សំរាប់ឱ្យប្រទេសបានលូតលាស់។

ដោយខ្ញុំបានជឿចិត្តគេទាំងស្រុងបាត់ទៅហើយ ខ្ញុំក៏សាកសួរគេទាំងមិនដឹង ខ្លួនឬក៏ថាដោយក្ដីចង់ដឹងតែមួយមុខថា បើយើងទៅពឹងមេធាវី តើត្រូវចំណាយលុយប៉ុន្មានទៅ រួមទាំងប្រាក់សំណូកទៀត?

ចម្លើយដែលខ្ញុំបានមកវិញ គួរឱ្យព្រឺក្បាល។ គេថា ត្រូវការ ១៨ម៉ឺនដុល្លាអាមេរិក។ ព្រះអើយ ខ្ញុំអស់សង្ឃឹមរលីងពីក្នុងខ្លួន។ បើខ្ញុំគ្មានប្រាក់នេះទេ អ្វីៗដែលខ្ញុំបានចំណាយ ខំបានធ្វើមក មិនទៅជាពពុះទឹកអស់ទៅហើយទេឬ? ខ្ញុំដាក់ទូរស័ព្ទចុះ។ ខ្ញុំបានគិតច្រើនណាស់។ អារម្មណ៍របស់ខ្ញុំគិតទៅ រតន៍នារីផងគិតទៅអ្វីៗដែលខ្លួនបានចំណាយហើយបែរទៅជាសូន្យបែបនេះផង។ បើខ្ញុំមានតែ ១៨ ម៉ឺនដុល្លាទៀត ខ្ញុំនឹងអាចបានទទួលជិត ៤លានដុល្លា ហើយខ្ញុំអាចចូលហ៊ុនជាមួយម្ចាស់លុយធ្វើវិនិយោគទុន ហើយជីតារបស់រតន៍នារី នឹងទទួលខ្ញុំដែពីរជាចៅប្រសាររបស់លោកផង។

វេលាយប់ នៅពេលដែលខ្ញុំកំពុងតែគិតហើយកង្វល់ចិត្ត មិនដឹងជាត្រូវពិគ្រោះជាមួយនរណា ជនជាតិស្បែកខ្មៅបានទូរស័ព្ទមកលេងខ្ញុំ។

ខ្ញុំសប្បាយចិត្តជាខ្លាំង។ តាមពិតខ្ញុំចង់ទូរស័ព្ទទៅពិគ្រោះជាមួយគេជាខ្លាំង។ ទទួលជាគេទូរស័ព្ទមកបែបនេះ ក៏ធូរចិត្តដែរ។ គេសួរខ្ញុំមុនៈ

- អាគីអូអ្នកគេងហើយទេដឹង?

ខ្ញុំឆ្លើយថា :

- ទេមិនទាន់ទេ។ ខ្ញុំកំពុងតែគិតថាតើត្រូវធ្វើបែបណា។ នែជោន(គេឈ្មោះជោន) បើអ្នកឯងជាខ្ញុំវិញ តើអ្នកឯងធ្វើយ៉ាងណា ?

ជោនហាក់ដូចជាគិតមួយសន្ទុះ រួចហើយគេក៏ថា :

- ខ្ញុំស្ដាយលុយដែលគេនឹងឱ្យអ្នកឯងណាស់។ បើខ្ញុំវិញ ខ្ញុំនឹងចំណាយលុយដើម្បីបើកយកលុយនោះហើយ។ (ខ្ញុំធ្លាប់បានសន្យាជាមួយ ជោន ថា ឱ្យតែខ្ញុំអាចដឹកជញ្ជូនលុយនោះទៅដាក់ធនាគារដោយសុវត្ថិភាព ខ្ញុំនឹងឱ្យកម្រៃគេ ១០ម៉ឺនដុល្លា)។

ខ្ញុំគិតថា អញ្ចឹងមែនហើយ រឿងហ្នឹង។ វាតោងតែអញ្ចឹង។ ខ្ញុំក៏សួរទៅគេទៀតថា :

- តើជោនឯង អាចនិយាយនឹងមេធាវីនោះ ឱ្យរកលុយ ពីណាទៅបង់ឱ្យមន្ត្រីដែលស៊ីញ៉េសំបុត្រស្នាមឱ្យយើងមុនបានទេ? បើបានខ្ញុំសុខចិត្តចំណាយប្រាក់បន្ថែម២០ភាគរយជូនគេជាសាគុណ។

ជោនបានសន្យានឹងខ្ញុំថា គេនឹងនិយាយជាមួយមេធាវីនោះល មើលឱ្យ។ សូមកុំឱ្យពិបាកចិត្តពេក ហើយសំរាកឱ្យបានសប្បាយទៅ។ ខ្ញុំបានអរគុណជោនយ៉ាងខ្លាំង ព្រោះខ្ញុំបានធូរចិត្តជាខ្លាំង ហើយ បានមើលទូរទស្សន៍ ដែលភ្សរយ៉ាងខ្ពស់នៅក្នុងបន្ទប់ដែលមានតែកូនគ្រែ តូចមួយ នឹងកូនតុសរសេរ តូចមួយ ។

វេលាព្រឹក ជោនបានទូរស័ព្ទមកខ្ញុំថា មេធាវីនិយាយថា គេមិនអាចចេញលុយទាំងអស់សិនបានទេ តែបើមាន១០ម៉ឺនដុល្លាបង់ឱ្យគេសិន គេព្រមធ្វើឱ្យ។

ខ្ញុំបានឆ្លើយថា ឥឡូវនេះ ខ្ញុំឥតមានលុយជាប់នៅនឹងខ្លួនទេ។ ខ្ញុំនឹងទៅជប៉ុនសាកល្បងខ្ចីលុយ ពីម្ដាយឪពុកខ្ញុំ ផ្ញើទៅឱ្យគេ។

ដោនហាក់ដូចជាអាណិតខ្ញុំ។ គេនិយាយថា ខ្ញុំសូមបន់ព្រះ ឱ្យឪពុកម្តាយអាគីអូសុខចិត្តឱ្យអាគីអូ ខ្ចីលុយ។ ខ្ញុំស្តាយជួសអ្នកណាស់។ បើខ្ញុំជាអ្នកវិញ ខ្ញុំនឹងខ្ចីលុយពីនេះពីនោះឱ្យខាងតែបាន ដើម្បីប្តូរយកសម្បត្តិមហាសាលនេះហើយ។

ខ្ញុំដឹងថា ចិត្តនរណាក៏ដូចជានរណាដែរនៅពេលនេះ។

# ជំពូកទី៣

ខ្ញុំបានត្រឡប់ចូលទៅជប៉ុនសិន ដើម្បីពិគ្រោះជាមួយនឹងឪពុកម្ដាយខ្ញុំ ដែលខ្ញុំពុំសូវសង្ឃឹមថា នឹងបានទទួលការយល់ព្រមឱ្យខ្ចីលុយ ដ៏សន្ធឹកសន្ធាប់បែបនេះឡើយ។

ដំបូងឡើងម្ដាយខ្ញុំចាប់ច្រឡោត នៅពេលដែលខ្ញុំរៀបរាប់ដំណើរដើមទង ហើយនិងទុក្ខធុរៈដែលនាំឱ្យខ្ញុំត្រូវការលុយខានមិនបាន។

- បើដឹងថា គេមានឋានៈខ្ពស់ឈោងមិនដល់បែបនេះ ម៉េចក៏ទៅឈោង? ស្មានថាយកកូនអ្នកខ្ពង់ខ្ពស់ មកធ្វើប្រពន្ធស្រួលឬ? នរណាគេដែលដណ្ដឹងប្រពន្ធមកសម្រាប់ដាក់ទូលលើហ៊ឹងនោះ? ហើយរឿងទៅទទួលលុយសម្បត្តិមហាសាលក៏បែបនោះដែរ។ វាមិនដែលមានមនុស្សណាគេសប្បុរសឱ្យអ្នកដែលមិនស្គាល់សោះ ទៅទទួលយកលុយ រាប់លានដុល្លា ប្រកាសតាម អ៊ីនទែរណេតអញ្ចឹងទេ។ បើគេធ្លាប់ធ្វើដល់ទៅមេទាហានជាន់ខ្ពស់ ខ្វះអ្វីអ្នកបរទេសដែលគេមានទំនាក់ទំនងជាមួយនោះ ដែលគេរាប់អានអាចនិយាយការសម្ងាត់ជាមួយបាននោះ។

អាគីអូ កូនឯងនេះ មានអត្តចារិតមួយដែលរឹងរូស ដែលស្រឡាញ់ការស្អាត ស្អំតែឯងត្រង់ធ្លូណាស់។ ឯងមិនដែលមានទំនាក់ទំនង នឹងសង្គមខាងក្រៅៗ ពីការរៀនសូត្រនៅសាលារៀន ទោះជាកូនឯងចេញពីសាកលវិទ្យាល័យតូក្យូដ៏សំបើមក៏ដោយ កូនឯងបរិសុទ្ធ ណាស់។

ឯឪពុករបស់ខ្ញុំវិញ ដោយលោកជាមនុស្សប្រុស លោកប្រហែលជាយល់សញ្ចេតនាជាប្រុសដូចគ្នាក៏មិនដឹង ពោលគឺប្រុសតែងតែមានមហិច្ឆតា ប្រុសលះបង់គ្រប់សព្វដើម្បីមនោសញ្ចេតនាមួយ។ លោកដកដង្ហើមធំ ហើយនិយាយតែមួយម៉ាត់ថា :

- អាគីអូ ចូរកូនស្ដាប់ម៉ែឯងដែលស្រឡាញ់កូនស្មើនឹងជីវិតល្អជាង។

រួចហើយ ឪពុកខ្ញុំក៏ដើរចេញទៅ។

ម្ដាយខ្ញុំនិយាយត្រមាំងត្រមោកបន្ត ថា :

- ម៉ែមិនឱ្យធ្វើបន្តទៀតជាដាច់ខាត។ ហើយតិចទៅខ្ចីលុយពីកន្លែងចងការយកទៅបន្តការងារនេះចុះ។ ម៉ែនឹងមិនអនុញ្ញាតឱ្យកូនឯងធ្វើជាដាច់ខាត។ អនុញ្ញាតឱ្យទៅនៅបរទេស ដើម្បីឱ្យកូនឯងមើលឃើញពិភពលោកល្វឹងល្វើយ មិនមែនឱ្យទៅធ្វើឧកញ្ញាសេនាបតី ចោលឧត្ដមគតិខ្លួនឯងទេ។

រួចហើយ គាត់ក៏ដើរលាំងៗទៅបន្ទប់គាត់បាត់ទៅ។

ខ្ញុំសែនពិបាកចិត្តអស្ចារ្យ។ បើម្ដាយខ្ញុំមិននិយាយពាក្យមួយម៉ាត់ថា តិចទៅខ្ចីលុយពីកន្លែងចងការ,,,និងឮពាក្យរបស់ឪពុកខ្ញុំទេ ខ្ញុំច្បាស់ជាទៅខ្ចីគេមកហើយ ព្រោះចិត្តដែលពុះកញ្ជ្រោលឆាបឆ្ឈូលនេះ មានកម្លាំងជាងអ្វីទាំងអស់។ ខ្ញុំអង្គុយក៏មិនសុខ ដេកក៏មិនសប្បាយ ទទួលទានអ្វីក៏ពុំចូល ធ្វើអ្វីក៏ពុំកើត។ ក្ដៅចិត្តនឹងខ្លួនដែលគ្មានលុយយកទៅបង្គ្រប់ ដើម្បីយកសម្បត្តិដ៏ច្រើនលើសលុប។

ឪពុកម្ដាយក្ដី ប្ដីប្រពន្ធក្ដី ហេតុអ្វីក៏គ្មានសុបិននិមិត្តអ្វីបន្តិចសោះអញ្ចឹង?

គេគ្មានស្រឡាញ់កូន ឬប្រពន្ធប្ដីរបស់ខ្លួនឱ្យស្មើនឹងសាម៉ីខ្លួនៗគេទេ។ ប្រាកដហើយពួកអ្នកអស់នេះស្គាល់តែ "ចូល" ទេ។ បើអាត្មាអញយកលុយនោះបាន

មកដល់ដៃ តើគេនឹងថាម៉េចទៅវិញ? វេលានោះ ខ្ញុំដូចជាមានអារម្មណ៍ខឹងនឹងម្ដាយខ្ញុំជាខ្លាំង ហើយមានការមិនពេញចិត្តចំពោះឪពុកខ្ញុំ ដែលនៅតែពីក្រោមកន្ទុយក្បិនម្ដាយរបស់ខ្ញុំ គ្មានគំនិតឯករាជ្យផ្ទាល់ខ្លួនឱ្យទាល់តែសោះ។

ដោយមានអារម្មណ៍ងងឹតបែបនេះ ខ្ញុំក៏រៀបចំឥវ៉ាន់ ធ្វើដំណើរទៅព្រះរាជាណាចក្រកម្ពុជាជាថ្មីទៀត។

ម្ដាយឪពុកខ្ញុំឥតមានហាមឃាត់ខ្ញុំទេ។ ខ្ញុំបានធ្វើដំណើរតែម្នាក់ឯង ទៅចំណតអាកាសយាន ណារីតា ហើយជិះ យន្តហោះដែលកាត់តាមប្រទេសថៃចូលទៅកម្ពុជា។

អាកាសយានបានឈានទៅដល់ដែនអាកាសដែលស្ថិតនៅពីលើ វាលស្រែដ៏ធំល្វឹងល្វើយ ដាច់ស្រយាល និង ផ្ទៃទឹក សស្វាចចាំងព្រិច១ដូចជា កំទេចប្រាក់ ដោយសារពន្លឺព្រះអាទិត្យ។ តាមរយៈការផ្សាយដំណឹងនៅក្នុងយន្តហោះ ខ្ញុំអាចដឹងបានដោយប្រាកដថា យន្តហោះរបស់យើង បានទៅដល់ជាយក្រុងភ្នំពេញហើយ១ប្រុងប្រៀបនឹងចុះចតនៅវាលកប៉ាល់ហោះពោធិចិនតុងឆាប់១នេះហើយ។

ខ្ញុំបំពេញក្រដាសស្នាម ដែលនារីបំរើយន្តហោះទាំងឡាយចែកឱ្យ ហើយរង់ចាំឱ្យ យានចុះចត។

ទីទទួលទិដ្ឋាកាត្តិ ទីអន្តោប្រវេសន៍ក្តិ បានប្ដូរទីកន្លែងរបស់ខ្លួនអស់ ក្នុងរយៈពេលជិតកន្លះខែ ដែលខ្ញុំមិនមានវត្តមាន។

មិនត្រឹមតែប៉ុណ្ណោះ គេថាក្រដាសស្នាមដែលខ្ញុំបានបំពេញហើយជាក្រដាស់ចាស់ ហើយគេហុចក្រដាសថ្មីដែលមានទំហំតូច មានរូបទង់ជ័យខ្មែរមានពណ៌មកឱ្យខ្ញុំបំពេញជាថ្មី។

ចេញពីនោះទៅដល់កន្លែងគយដ៏ស្ងាត់ច្រៀប ខ្ញុំឃើញបុគ្គលិកម្នាក់អង្គុយស្ងាបលើកៅអីនៅក្នុងទីដ៏ងងឹតមួយ មិនដឹងជាតាំងពីអង្កាលមកហើយទេ។ គេដើរតយង៉យមកសាកសួរខ្ញុំថាតើនៅក្នុងកាបូបរបស់ខ្ញុំមានអ្វីខ្លះ។ ខ្ញុំបានឆ្លើយថាមានតែខោអាវពីរបីកុំប្លែតែប៉ុណ្ណោះទេ។ គេបានអនុញ្ញាតឱ្យខ្ញុំចេញទៅក្រៅហើយគេបានដើរតយង៉យទៅអង្គុយទីដ៏សុខរបស់គេវិញ។

វាលកប៉ាល់ហោះបានប្រែប្រួលយ៉ាងខ្លាំង ពីព្រោះការប្រជុំ អាស៊ាន ១០ នៅទីក្រុងភ្នំពេញ នៅខែ១១ នេះឯង។ វេលានោះ ខ្ញុំកំពុងតែនៅអាំស្ទែរដាំ។ រតន៍នារីច្បាស់ជារវល់អស្ចារ្យមិនលែងឡើយ ដោយនាងត្រូវតែរាំទទួលមហាមិត្តដែលសុទ្ធសឹងជាវរជនសំបើម១នៅដែនដីអាស៊ីភាគអាគ្នេយ៍នេះ។

ទិដ្ឋភាពទូទៅទំនើប ហើយតាំងពីកៅអីអង្គុយនៅបន្ទប់រង់ចាំឡើង មានរចនាបថ និងបរិយាកាសទីក្រុងណាស់។

មានដាំដើមផ្កានៅគ្រប់ទីកន្លែង ដែលគេអាចគ្រលៀសភ្នែកទៅដល់បាន។ ជាពិសេស ដើមផ្កាក្រដាសមានដាំនៅគ្រប់ទីកន្លែង។

ខ្ញុំឡើងជិះតាក់ស៊ី សំដៅទៅបេះដូងនៃទីក្រុង។ ទីក្រុងទាំងមូល ហាក់ដូចជាមិនមានការផ្លាស់ប្ដូរអ្វីប៉ុន្មានទេ។ អ្វីដែលផ្លាស់ប្ដូរគឺទឹកចិត្តរបស់ខ្ញុំតែប៉ុណ្ណោះ។ នៅពេលដែលចេញដំណើរទៅ ខ្ញុំពោរពេញទៅដោយសេចក្ដីសង្ឃឹម ហើយឥឡូវនេះ ខ្លួនខ្ញុំទាំងមូលគឺ មានតែសំបកក្រៅ គ្មានព្រលឹង គ្មានវិញ្ញាណ។

តាក់ស៊ីបានជូនខ្ញុំទៅដល់មុខផ្ទះរបស់ខ្ញុំ។ ខ្ញុំបង់តម្លៃហើយ ចុះទៅបើកទ្វាររបងខ្ពស់ពណ៌បៃតង មានលាបទឹកមាសលើគែម១ដែលបិទជិត ហើយថែមទាំងមានព័ទ្ធលួសបន្លាពីក្រៅថែមទៀត។ ដូចជាគេហដ្ឋានដែលសង់នៅពេលថ្មី១នេះភាគច្រើនដែរ ផ្ទះនេះលាបពណ៌កំបោរមានបីល្វែង សង់ពីរជាន់។

គេហដ្ឋាននេះ ជាផ្ទះព្រឹទ្ធបុរស នៃមហាវិទ្យាល័យដែលខ្ញុំទៅបង្រៀនភាសាអង់គ្លេស។ ម្ចាស់ផ្ទះរស់នៅជាន់ខាងក្រោមទាំងអស់ ជាមួយគ្រួសាររបស់លោក។ ឯជាន់ខាងលើ មួយល្វែងទៀត មានជនជាតិកូរ៉េរស់នៅ។ នៅប្រទេសនេះ ជនជាតិកូរ៉េ ហាក់ដូចជាចូលចិត្តប្រឡងប្រជែងចង់ឈ្នះចាញ់ ជាមួយជប៉ុនជាខ្លាំង។ ដោយខ្ញុំរវល់បង្រៀនច្រើនកន្លែងផង រៀនភាសាខ្មែរខ្លួនឯងផង ខ្ញុំពុំសូវមានឱកាសបានជួបសំណេះសំណាលជាមួយនឹងគេទេ។

ខ្ញុំឡើងជណ្ដើរទៅជាន់ទី២ ដែលនៅខាងឆ្វេងដៃ។ បន្ទប់ខ្ញុំងងឹត ពីព្រោះនៅចំពីមុខផ្ទះមានដើមអំពិលបាំងធំមួយ ដែលមានចំណាស់មិនដឹង ជាប៉ុន្មានសិបឆ្នាំទៅហើយទេ។ ខ្ញុំបើកភ្លើងអំពូលម៉ែត្រ ហើយចុចមើលទូរស័ព្ទរកមើលថាតើមាននរណាទូរស័ព្ទមកឬអត់។

សម្លេងរតនីនារីលាន់ស្រាលៗ ដូចដែលនាងនិយាយធម្មតា។ នាងសួរថា តើខ្ញុំមកវិញឬនៅ។ នាងរឭកខ្ញុំណាស់ ហើយនាងបានដឹងថា ប្រសិនបើនាងមិនបានឃើញខ្ញុំ នាងបារម្ភជាខ្លាំង។

មុនពេលដែលខ្ញុំចាកចេញពីប្រទេសកម្ពុជា ខ្ញុំបានប្រាប់នាងថា ខ្ញុំនឹងខិតខំរកលុយ តាមដែលខ្ញុំអាចធ្វើបាន ដើម្បីស្ដីដណ្ដឹងយកនាង មកធ្វើជាភរិយាពេញច្បាប់។

នាងបានសួរខ្ញុំថា ឪពុកម្ដាយខ្ញុំនឹង ចំណាយលុយជំនួសខ្ញុំឬទេ? សំនួរនេះបើយោលទៅតាមគំនិតខ្មែរ គឺពុំមានអ្វីឆ្ងាំឆ្ងល់ទាល់តែសោះ ពីព្រោះប្រជាជននៅប្រទេសនេះ គេរំពឹងលើឪពុកម្ដាយរហូតទាល់ថ្ងៃស្លាប់។ គ្រាន់តែបញ្ចេញឈ្មោះថា ជាកូនលោកនេះ ជាចៅអ្នកនេះ ឬជាក្មួយលោកនោះ ទោះជាសាមីខ្លួននោះពុំមានធ្វើអ្វី ដើរទាត់ខ្យល់ ក៏គេមាន "ឋានន្តរសក្តិ" របស់គេមួយបាត់ទៅហើយ។ ហើយបើនិយាយពីរឿងលុយកាក់ទៅវិញ ទ្រព្យសម្បត្តិឪពុក ម្ដាយគឺទ្រព្យសម្បត្តិរបស់កូនទាំងស្រុងតែម្ដង។ អស់ពីឪពុកម្ដាយទៅ ពួកគេនឹងទទួលយកមកធ្វើរបស់គេទាំងអស់។ ជាការពិតណាស់ ពេលឪពុកម្ដាយគេរស់នៅក៏គេមានសិទ្ធិនឹងចាយវាយទ្រព្យទាំងនោះ ដោយសេរីដែរ។

ខ្ញុំបានឆ្លើយប្រាប់នាងថា ឪពុកម្ដាយខ្ញុំ ពុំមានប្រាក់ច្រើនដល់ម្លឹងទេ។ រតនីនារីធ្វើមុខចម្លែក។ តាំងពីនាងរៀនជាមួយខ្ញុំមក នាងចេះគិតថា ប្រទេសជប៉ុនជាប្រទេសដែលជួយកម្ពុជាច្រើនជាងគេ នាងចាប់មានការចង់ដឹងពីទំនាក់ទំនងអន្តរជាតិ។ បើប្រទេសជប៉ុនមានហូរហៀរដល់ទៅជួយមកដល់ខ្មែរទៅហើយ វាមិនបានន័យថា ជនជាតិជប៉ុនម្នាក់ៗ មានកប់ពពកទេឬ ?

ខ្ញុំបានប្រាប់នាងថា មួយឆ្នាំៗ ជប៉ុនគេកំណត់ថវិកាសំរាប់ជំនួយលើកិរិតអន្តរជាតិប៉ុន្មានៗ ហើយគេជួយទៅតាមនោះ។ ជនជាតិជប៉ុនម្នាក់ៗមិនសូវជាធូរធារទេ។ កុំថាឡើយដល់ទៅមិនសូវ ធូរធារ អ្នកខ្លះក្រ គេងនៅនឹងស្ថានីយរថភ្លើង ខ្លះរងាកកឡើងស្លាប់ ដោយសេដ្ឋកិច្ចជប៉ុនឥឡូវក៏មិនសូវល្អ ប្រជាជនដែលមានការលំបាកក្នុងការរស់នៅ កាន់តែមានចំនួនច្រើនឡើងៗ ពីមួយថ្ងៃទៅមួយថ្ងៃ។ ក្រុមហ៊ុនរលំជាបន្តបន្ទាប់ ធនាគារក៏រលំ។ ប្រជាជនដែលតោងតែទ្រទ្រង់គ្រួសារជាច្រើនបាត់បង់ការងារ។ អត្តឃាតនៃបុរសអាយុពាក់កណ្ដាលមនុស្សក៏កើនច្រើនដែរសព្វថ្ងៃ។

រតនីនារីស្ដាប់ខ្ញុំ ហើយនាងនៅស្ងៀម សញ្ជឹងគិត។ បន្ទាប់មកនាងនិយាយ ថា :

- អញ្ចឹង លោកគ្រូអញ្ជើញទៅបរទេសធ្វើអ្វី?

ពាក្យសម្ដីរបស់នាងពោរពេញទៅដោយការព្រួយបារម្ភដ៏ខ្លាំងក្លា។ នាងងើយទៅលើដោយមុខក្រហម ភ្នែករលីងរលោង។ មួយសន្ទុះ ខ្ញុំឃើញទឹកភ្នែកថ្លាឆ្វង់ រមៀលជាខ្សែធ្លាក់ចុះមក។ រតន៍នារីក្ដាប់ដៃស្ដាំនាង ហើយយកម្រាមចង្អុរដៃដែលនៅលើគេ ទប់ត្របកភ្នែកនាង ហាក់ដូចជាកុំឱ្យខ្សែទី២ ទី៣ ធ្លាក់មកបាន។ រួចហើយនាងលាដៃនាង ជូតទឹកភ្នែក។

ខ្ញុំអាណិតនាងខ្លោចចិត្ត។ ខ្ញុំពុំបានប្រាប់នាងថា ខ្ញុំទៅផ្សងព្រេងទេ។ ហើយខ្ញុំបានសន្មតនៅក្នុងចិត្តថា មានតែម្យ៉ាងទេដែលនៅសល់ ចំពោះរូបខ្ញុំ គឺរត់ចេញឱ្យផុតផែនដីនេះឈប់ ឱ្យរតន៍នារីឃើញមុខខ្ញុំ ហើយខ្ញុំក៏ឈប់ជួបនាង។

ខ្ញុំបានខិតខំកាត់ចិត្តជាខ្លាំង ហើយការនេះតម្រូវឱ្យខ្ញុំទ្រាំនឹងការចុកចាប់ក្នុងបេះដូងអស្ចារ្យណាស់។

ខ្ញុំមិនឆ្លើយទៅនាងវិញទេ។ តែខ្ញុំដឹងថានាងកំពុងតែព្រួយបារម្ភខ្លាំងណាស់អំពីរូបខ្ញុំ ហើយទង្វើរបស់ខ្ញុំនេះប្រៀបបាននឹងទារុណកម្មដ៏ឃោឃៅមួយទៅលើនាង។ ខ្ញុំបានគិតហើយគិតទៀតមិនអស់មិនហើយ តើខ្ញុំត្រូវធ្វើយ៉ាងម៉េច។ តែខ្ញុំបានសំរេចថា ទោះជាទូរស័ព្ទទៅនាង ក៏មិនបានការអ្វីក្រៅពីធ្វើឱ្យនាងរឹតតែពិបាកចិត្តទេ។ នៅពេលនោះ ទូរស័ព្ទបានរោទិ៍ឡើង។ ខ្ញុំគិតថា ច្បាស់ជាទូរស័ព្ទដែលមកពីសាលារបស់ខ្ញុំហើយ។ ខ្ញុំក៏លើក។ រតន៍នារីនិយាយទាំងត្រេកអរ ដូចជាកុមារីតូច :

- លោកគ្រូ ! លោកគ្រូ អញ្ជើញមកវិញហើយឬ? រតន៍នារីមានរឿងល្អណាស់ជំរាបលោកគ្រូ។

- រតន៍នារីមានរឿងអ្វី ?

- កាលពីខែ ១១ នៅពេលប្រជុំអាស៊ាន រតន៍នារី រាំរបាំថ្មី ដែលលោកគ្រូអ្នកគ្រូ ទើបនឹងរកឃើញ ហើយបានទទួលការលើកទឹកចិត្តជាខ្លាំង។

- ល្អ ណាស់ គ្រូ ក៏សូមសរសើរនាងដែរ។

- មិនមែនតែប៉ុណ្ណេះទេ លោកគ្រូ ,,,,

រតន៍នារីហាក់ដូចជារង់ចាំការវិលត្រឡប់របស់ខ្ញុំ ដើម្បីរ៉ាយរ៉ាប់ នូវអ្វីៗដែលកើតឡើងទៅលើរូបនាងជាខ្លាំង ដូចដែលនៅពេលដែលនាងរៀនជាមួយខ្ញុំ។

ខ្ញុំនៅស្ងៀម ចាំស្ដាប់នាងរៀបរាប់។

- ឯកឧត្ដម ឆាយ៉ាវ៉ណ បានសរសើររតន៍នារីថា រតន៍ជាមនុស្សស្រីក្មេងដែលប្រកបទៅដោយការចេះដឹង នៅលើថ្នាលវប្បធម៌ណាស់ ហើយលោកនឹងអញ្ជើញរតន៍ឱ្យទៅចូលរួមក្នុងសិក្ខាសាលាមួយ នៅប្រទេសថៃ ខែ ៩ ឆ្នាំក្រោយ។ លោកតាអរខ្លាំងណាស់។ រតន៍បានជំរាបលោកតាថា រៀនពីលោក គ្រូ។ លោកតាក៏មានប្រសាសន៍លាន់មាត់ថា ចំណេះវិជ្ជាមានតម្លៃដល់ថ្នាក់ នេះហ្ន៎ ! ហើយលោកតាបានឱ្យរតន៍ជំរាបសុំលោកគ្រូឱ្យបង្រៀនរតន៍តទៅ ទៀត។

ខ្ញុំទៅជាភាំង។ រតន៍នារីអញ្ជើញខ្ញុំឱ្យទៅផ្ទះនាងនៅម៉ោង ៦ ល្ងាចនេះ ដើម្បីចូលរួបរួមក្នុងពិធីជប់លៀងជាគ្រួសារតូចមួយ។ ខ្ញុំទីទើណាស់ ដោយសារខ្ញុំកំពុងតែពិបាកចិត្តខ្លាំងផង តើខ្ញុំអាចរួសរាយសប្បាយជាមួយគេឯងបានកើតឬទេ។ ខ្ញុំអង្វរនាង សុំនាងសំរាក។ ប៉ុន្តែរតន៍នារីកន្ទក់កន្ទិញចង់ជួបខ្ញុំជាខ្លាំង។ នាងបានអង្វរករខ្ញុំ សុំឱ្យខ្ញុំខិតខំសំរាកឥឡូវឱ្យបានឆ្អែត ហើយឱ្យខ្ញុំទៅចូលរួបរួមកុំខាន។

ឡានមែរសីដេសខ្មៅសំរាប់រតន៍នារីបានមកទទួលខ្ញុំនៅម៉ោង ៥:៤០។

ខ្ញុំហាក់ដូចជាបានធូរចិត្តបន្តិច ហើយបានភ្លេចគិតរឿងដែលធ្វើឱ្យខ្ញុំលំបាកចិត្ត នៅអឺរុបមួយរយៈ។ ខ្ញុំបានទិញផ្កាមួយកន្ត្រកធំយកទៅជូននាង។

រថបានដឹកខ្ញុំទៅដាក់នៅមុខវិមាន លោកឧកញ្ញា សុទ្ធ ក្រសេម។ រតន៏នារីឈរចាំខ្ញុំនៅលើថ្នាក់ក្រោមបង្អស់នៃជណ្តើរផ្ទះនាង។ នាងស្លៀកផាមួងបៃតងមានសែសយ និងអាវតូចខ្លី មានខ្សែឆ្នារពីរ ដែលមានពណ៌ដូចគ្នា នឹងសំពត់របស់នាង។

នាងញញឹមស្រស់សែនស្រស់ លើកដៃសំពះមកខ្ញុំ។ អ្នកបើកឡានបានស្ទុះមកបើកទ្វារឡានឱ្យខ្ញុំចុះ។ រតន៏នារីដើរទទ្ទឹមនឹងខ្ញុំ និយាយដោយសម្លេងថើៗពិរោះ។ គឺជាសម្លេងដែលខ្ញុំខានឮជាងពីរអាទិត្យហើយៗគឺជាសម្លេងដែលខ្ញុំរឭកចង់ឮជាងអ្វីទាំងអស់។

យើងបានចូលទៅដល់សាលមួយ ដែលមានមនុស្សប្រហែលជា ដប់នាក់។

ម្នាក់ៗមានកាន់ភេសជ្ជៈ។ ការជប់លៀងពុំទាន់ចាប់ផ្តើមនៅឡើយទេ។ ខ្ញុំបានទទួលស្រាទំពាំងបាយជូរក្រហមមួយកែវមក ហើយទទួលទានជាមួយរតន៏ នារី។ នាងនាំខ្ញុំទៅដល់មុខជីតានាង ដែលទើបនឹងអញ្ជើញចូលមក។ ខ្ញុំលើកដៃជំរាបសួរលោក តែលោកលោដៃទាំងពីររបស់លោកមកចាប់ដៃខ្ញុំ ថ្លែងអំណរគុណខ្ញុំ។

- លោកគ្រូ ខ្ញុំទើបនឹងដឹង លោកគ្រូវិសេសមែន ទើបបានជា មានគេអញ្ជើញទៅបង្រៀន ឯនេះ ឯនោះ។ រតន៏នារីនឹងត្រូវមិត្តថៃខ្ញុំអញ្ជើញទៅរាំ ហើយឱ្យនិយាយពីរបាំខ្មែរឱ្យគេស្តាប់។ មកដល់ពេលនេះ យើងផ្ចង់អារម្មណ៍ និងសង្កត់ខ្លាំងទៅលើតែបច្ចេកទេសនៃរបាំ។ រតន៏បាននិយាយថា តាំងពីគេចាប់រៀនជាមួយលោកគ្រូមក គេបានគិតពីភាគខាងផ្លូវចិត្តនិងគំនិត រួមជាមួយនិងក្បាច់ និង បច្ចេកទេស ដូច្នេះនាំឱ្យរបាំដែលគេរាំ កាន់តែមានភាពជាទស្សនវិជ្ជាឡើង។ ខ្ញុំសូមអរគុណលោកគ្រូជាខ្លាំង។

បន្ទាប់ពីនោះ នាងនាំខ្ញុំទៅជំរាបសួរ គួរសមមនុស្សស្រ្តី វ័យកណ្តាលបីនាក់និងវ័យចំណាស់ម្នាក់យ៉ាងគោរពក្រៃលែង ហើយនាងប្រាប់ថាអ្នកទាំងនោះជាគ្រូរបាំរបស់នាង។ រួចមកនាងណែនាំខ្ញុំឱ្យស្គាល់នារីក្មេងៗបួនប្រាំនាក់។

នៅពេលដែលពិធីជប់លៀងចាប់ផ្តើម យើងទាំងអស់គ្នា បាននាំគ្នាចូលទៅបន្ទប់ទទួលទានបាយ ដែលមានតុវែង មានផ្កាស្រស់ដែលគេរៀបចំតាមវិធីរៀបផ្កាចម្លែក វែងពីចុងមូលចំកណ្តាលតុទៅ បន្តទៅចុងទាំងសងខាង ល្អសមរម្យឥតទាស់ភ្នែក។ ខ្ញុំអង្គុយខាងឆ្វេងលោកឧកញ្ញាមហាមន្ត្រី។ រតន៏នារីអង្គុយខាងស្តាំលោក។ លោកឧកញ្ញាបានឱ្យកិត្តិយសយ៉ាងខ្លាំងមកខ្ញុំ។ វេលានោះលោកសំណាងឥតមានវត្តមាននៅទីនោះទេ។ ហើយខ្ញុំមិនយល់រឿងនេះទាល់តែសោះ។

អ្នកដែលមកចូលរួបរួមនៅក្នុងពិធីជប់លៀងនេះ មានអ្នកគ្រូរបាំ ៤-៥ នាក់ក្មួយៗ របស់លោកឧកញ្ញា២-៣ នាក់ និងមិត្តរតន៏នារី ២-៣ នាក់ ។ គឺជាការជប់លៀងដែលមានសភាពជាគ្រួសារ។ គេបំរើម្ហូបបារាំងដែលរៀបចំឱ្យមានរសជាតិដូចម្ហូបខ្មែរ ឆ្ងាញ់ចម្លែកណាស់។

នៅថ្ងៃនោះ ខ្ញុំបាននៅនិយាយលេងជាមួយរតន៏នារីប្រហែលជាកន្លះម៉ោងបន្ទាប់ពីការជប់លៀងមក ដើម្បីពិភាក្សាពីពេលវេលាដែលយើងត្រូវរៀនជាមួយគ្នាបន្តទៅទៀត។

ពេលនាងជូនដំណើរខ្ញុំចេញទៅផ្ទះ ខ្ញុំបានសាកសួរនាងពីលោកសំណាង។ នាងបាននិយាយថា លោកសំណាងមាននារីកំណាន់ច្រើន ហើយមានរឿងជា

មួយជីតានាង ដោយលោកតាមានប្រសាសន៍រឿងសុំឱ្យលើកពេលវេលារៀបការជាមួយនាង។ គេបានប្រមាថលោកថាលោកជាមនុស្សចាស់មិនគោរពកិច្ចសន្យា។ ដំបូងលោកតាពិបាកចិត្តជាខ្លាំង ចំពោះការដែលនាងបានប្រកែកមិនចង់រៀបការជាមួយគេ។ ប៉ុន្តែនៅពេលក្រោយទៅក៏បានដឹងថា លោកសំណាងមាននារីកំណាន់ច្រើននាក់ ហើយនារីខ្លះថែមទាំងមានបុត្រទៅទៀត។ ពេលមួយ លោកឧកញ្ញាបានអញ្ជើញលោកសំណាងមកសួរ ហើយបានដឹងការពិត។ ឥឡូវនេះ គ្រួសារនាង និងលោកសំណាង ពុំមានទំនាក់ទំនងនឹងគ្នាទៀតទេ។

ខ្ញុំហាក់ដូចជាបានធូរចិត្តបន្តិច។ ក៏ប៉ុន្តែ ទោះជានាងទៅជាទំនេរ ឥតមានជំពាក់ទាក់ទាញ ជាមួយនឹងបុរសដទៃឯទៀត ក៏ខ្ញុំគ្មានសង្ឃឹមថា នឹងបាននាងមកធ្វើជាគូគ្រងរបស់ខ្ញុំដែរ។

ខ្ញុំមិនបានសួរនាងវែងឆ្ងាយតទៅទៀតទេ។ ថ្ងៃនោះខ្ញុំត្រឡប់មកដល់ផ្ទះវិញយប់ក្រៃលដែរទៅហើយ ៗមានអារម្មណ៍ហត់ផង ក៏ប្រាសខ្លួនទៅលើគ្រែស្រមុករហូតដល់ថ្ងៃរះខ្ពស់ផុតចុងឈើទៅ។

ថ្ងៃបន្ទាប់នោះ ខ្ញុំតោងតែទៅអើតសាលាបន្តិច ព្រោះបរវេសនកាលបានចូលមកហើយៗខ្ញុំមានថ្នាក់៤ ដែលត្រូវបង្រៀន នៅឆ្នាំសិក្សាថ្មីនេះ។ បន្ទាប់មកមានការបង្រៀននៅសាលាឯកជន មួយថ្ងៃ ពីរ ឬបី ម៉ោងទៀត និងបង្រៀនរតន៍នារីប្រាំមួយម៉ោងក្នុងមួយអាទិត្យ ដើម្បីរកលុយចាប់ផ្ដើមពីសូន្យមកវិញ។

ខ្ញុំនៅតែមិនអស់ចិត្តនឹងរឿងប្រាក់មហាសាលរបស់ខ្ញុំដដែល ទោះជាបានធូរចិត្តរឿងរតន៍នារីលែងរៀបការវិញហើយក៏ដោយ។ រឿងនេះប្រៀបបាននឹងការស្រមៃចំពោះអនាគតកាល មួយរបស់មនុស្សប្រុសគ្រប់គ្នា នៅក្នុងលោកយើងនេះ ហើយវាជារឿងដែលគ្មានទំនាក់ទំនងនឹងរឿងស្នេហាទាល់តែសោះ។

ព្រះរាមតស៊ូចំពោះនាងសីតា មិនមែនដោយសារតែទ្រង់ស្នេហានាងងប់ងុលអត់ពុំបានទេ។ គឺជាអស្មិមានៈមួយរបស់មនុស្ស ដែលមិនចូលចិត្តចុះចាញ់ដោយធូរៗ។ បើនាងសីតាពុំបានត្រូវរាពណ៍ចាប់ទៅទេ ក៏ទ្រង់គង់តែនឹង ច្បាំងតស៊ូយកឈ្នះចាញ់នៅក្នុងរឿងអ្វីផ្សេងទៀត មិនខានឡើយ ។

ខ្ញុំបានគិតហើយ បានជម្ពះនៅក្នុងចិត្តថា តោងតែតស៊ូបន្តទៅមុខទៀត ទោះបីជាម្ដាយឪពុករបស់ខ្ញុំបានហាមឃាត់ដាច់អហំង្កាក្ដី។ ប៉ុន្តែតើទៅរកលុយពីណា?

ខ្ញុំបានទូរស័ព្ទទាក់ទងនឹងមេធាវីនីហ្សេរីជាថ្មីទៀត ពិគ្រោះគេថា តើគេអាចទៅរកលុយពីណាពីណើឱ្យបានទេ? បើត្រឹមតែលុយធ្វើដំណើរទៅយកលុយទៅបើកគណនីយ នៅធនាគារខ្ញុំអាចរកបាន តែខ្ញុំពុំអាចរកលុយសំរាប់ទៅសូកមេធាវី និងមន្ត្រីដែលទទួលស៊ីញ៉េ បញ្ជាក់ឱ្យយើងបានទេ ។ មេធាវីហាក់ដូចជាពិបាកចិត្តជាមួយនឹងខ្ញុំជាខ្លាំង ប៉ុន្តែគេនិយាយថា គេនឹងខិតខំរក។

ឯជនជាតិស្បែកស ដែលខ្ញុំបានជួបនៅអាំស្ទែរដាំ ជាបុគ្គលិកក្រុមហ៊ុនដឹកជញ្ជូនយូនីហ្គឡួប ក៏បានទូរស័ព្ទមកខ្ញុំដែរថា ឱ្យតែខ្ញុំបញ្ជូនលុយទៅគណនីយរបស់គេៗនឹងធ្វើបានឱ្យខ្ញុំភ្លាម កុំឱ្យខ្ញុំបារម្ភឱ្យសោះ។

ខ្ញុំមិនដឹងជាទៅរកលុយឯណាទេ មានតែរង់ចាំដំណឹងពីមេធាវីនៅនីហ្សេរីតែប៉ុណ្ណោះ ។ នៅពេលដែលខ្ញុំចាំចម្លើយដ៏យូរពីមេធាវីនោះ ម្ដាយខ្ញុំបានទូរស័ព្ទពីជប៉ុនមកថា គាត់បានឃើញដំណឹងនៅក្នុងទូរទស្សន៍ជប៉ុនថា មានជនជាតិនីហ្សេរីដែលផ្ញើអ៊ី-មែល របៀបដូចដែលគាត់បានឮពីខ្ញុំ ទៅជនជាតិជប៉ុនជាច្រើន។ មានអ្នកខ្លះបានបាត់ខ្លួននៅពេលដែលទៅទទួលលុយនោះ។ ម្ដាយខ្ញុំបានស្ដីបន្ទោសខ្ញុំថា តើខ្ញុំបានឃើញថា ខ្ញុំចាញ់បោកគេឬនៅ ?

ខ្ញុំបានរាវរកតាមសែតីអ៊ីនទែរណេត ដើម្បីបញ្ជាក់ថា តើដំណឹងដែលម្ដាយ ខ្ញុំផ្ដល់មក គួរឱ្យជឿបានឬអត់។

ខ្ញុំធ្លាក់ថ្លើមក្ដុក។ មានរឿងបែបនេះកើតជាច្រើននៅសហរដ្ឋអាមេរិក ដូចម្ដាយខ្ញុំនិយាយមែន។ មានមនុស្សច្រើននាក់បាត់ខ្លួន ហើយអ្នកដែលបានរត់រួចខ្លួន បានសរសេរពីការពិសោធន៍ដ៏គួរឱ្យព្រឺក្បាលរបស់ខ្លួន ផ្សាយតាមសែតីនោះ។ ហើយអ្នកខ្លះបានបាត់បង់លុយរាប់សិបម៉ឺនដុល្លារអាមេរិក។

ខ្ញុំដឹងបែបនេះក៏ភិតភ័យ នឹកដល់ជីវិតខ្លួន ដែលអាចបាត់បង់យ៉ាងផុយបំផុត ដោយសារដៃពួកអ្នកលេងដៃឆៅទាំងឡាយ។ ខ្ញុំនៅមិនអស់ចិត្តនឹងពួកគេដែលមានអាការៈល្អដាក់ខ្ញុំ ដែលនិយាយពិរោះដោយភាសារបៀបកម្មករគួរឱ្យជឿថា ជាពួកដែលមកលត់ដំលំបាកនៅស្រុកគេ ហើយមើលទៅគួរឱ្យអាណិតនិងស្រឡាញ់ណាស់។

ខ្ញុំបានសម្ងំស្ងៀម មិនតបនឹងអ៊ីមេល ដែលជនសក់សសរសេរមកខ្ញុំ ឱ្យប្រញាប់ប្រញាល់រកលុយទៅយកសម្បត្តិមហាសាលនោះទៀតទេ។

ខ្ញុំបានផ្ញើសំណុំរឿងទៅប្ដឹងប៉ូលិសនៅអាំស្ទែរដាំ។ ប៉ូលិសបានទទួលពាក្យបណ្ដឹងរបស់ខ្ញុំ ហើយបានផ្ញើរ អ៊ីមែល មួយមកខ្ញុំថា គេនឹងធ្វើការស៊ើបអង្កេតឱ្យខ្ញុំ ។ រួចហើយ ប្រហែលជាពីរអាទិត្យក្រោយមកទៀត គេបានផ្ញើ អ៊ីមែល មួយទៀតមកថា គេបានប្រមានពួកក្រុមដែលខ្ញុំដាក់ពាក្យបណ្ដឹង ថាឈប់ឱ្យទាក់ទងជាមួយខ្ញុំ ឈប់រករឿងកោសរូសរកលុយពីខ្ញុំ។

ខ្ញុំហួសចិត្តនឹងទង្វើរបស់ប៉ូលិសនោះអស្ចារ្យ។ ករណីយ៍ខ្ញុំជាករណីយ៍ជីវិតប្រាកក៏ពិតមែនហើយ ប៉ុន្តែវាជារឿងបោកប្រាសដែលប៉ូលិសតោងតែធ្វើការចាប់ចងពួកជនឧក្រិដ្ឋ ។

ខ្ញុំមានការក្ដៅក្រហាយនឹងជនដែលបោកប្រាសខ្ញុំហើយ ខឹងរកយល់មិនកើតពីចម្លើយនៃប៉ូលិស អាំស្ទែរដាំ។ ខ្ញុំបានពិគ្រោះជាមួយនឹងមិត្តខ្ញុំម្នាក់ ដែលធ្វើមេធាវី ប៉ុន្តែគេបានឆ្លើយថា ចំពោះរឿងឧក្រិដ្ឋកម្មឆ្លងប្រទេសបែបនេះ មេធាវីពុំសូវចង់ធ្វើទេ ពីព្រោះគេតោងតែសិក្សាស្រាវជ្រាវពីច្បាប់របស់ប្រទេសនោះឱ្យច្បាស់លាស់ទើបបាន។ ភាសាហុលឡង់ដ៏ ជាភាសាដែលពុំសូវមាននរណាចេះទៀត ម្ល៉ោះហើយ មេធាវីក៏មិនសូវសង្ឃឹមថាធ្វើក្ដីឈ្នះគេដែរ។

# ជំពូកទី៤

ខ្ញុំអាចបំភ្លេចការក្តៅក្រហាយរបស់ខ្ញុំបានបន្តិចម្តងៗ ដោយសាររតន៍នារី ។

ខ្ញុំបានសួរនាង អំពីសេចក្តីបំណងរបស់នាងទៅអនាគត ។ បើនិយាយតាមពាក្យ របស់ជនដែលនៅបញ្ចឹមប្រទេស គេហៅថា សុបិននិមិត្ត ។

នាងបានឆ្លើយថា សុបិននិមិត្តរបស់នាង គឺបង្កើតវង់របាំក្បាច់បុរាណខ្មែរមួយផ្ទាល់ខ្លួននាងនៅផ្ទះនេះ ។ ជីតានាងបានផ្តល់សេរីភាពដល់នាងគ្រប់យ៉ាងក្នុងការចាត់ចែង ។ នាងបានអញ្ជើញខ្ញុំឱ្យជួយនាង ។ នាងនិយាយថា តើពាក្យដែលខ្ញុំសន្យានឹងនាង ថាខិតខំរកលុយដើម្បីរៀបការជាមួយនាង នៅមាននៅក្នុងខួរក្បាលរបស់ខ្ញុំទៀតឬទេ?

ខ្ញុំបានឆ្លើយថា ខ្ញុំស្រឡាញ់នាងជានិច្ច ឥតកែប្រែទេ មានតែរឹតតែស្រឡាញ់នាងលើសពីមុនទៅទៀត ។ ប៉ុន្តែខ្ញុំពុំអាចរកលុយបានទេ ។ ខ្ញុំបានខំអស់ពីសមត្ថភាពហើយ ។ ក្រៅពីលុយ ឱ្យខ្ញុំធ្វើអ្វី ក៏ខ្ញុំនឹងធ្វើទាំងអស់ ។

រតន៍នារីបាននិយាយថា លុយនាងមានឥតខ្វះទេ ។ នាងដឹងថាខ្ញុំបានស្វះស្វែងដើម្បីនាង ហើយនាងរំភើបចិត្តណាស់ ។ នាងសុំតែម្យ៉ាងពីខ្ញុំ គឺឱ្យខ្ញុំជួយចូកចែវមន្ទីររបាំនាងផង ។ នាងចង់បង្កើតឱ្យមានជាមន្ទីរវប្បធម៌មួយ ហើយចង់ឱ្យខ្ញុំធ្វើប្រធានមន្ទីរនោះជាមួយនាង ។ ខ្ញុំអាចនៅជាជប៉ុនដូច្នេះរហូត ហើយធ្វើអ្វីដែលខ្ញុំចង់ ដូចជាបង្រៀននៅសាកលវិទ្យាល័យ ដូចសព្វថ្ងៃដដែល ។

ខ្ញុំបានឆ្លើយថា ខ្ញុំនឹងលើកថ្នាក់ភាសាអង់គ្លេស និងជប៉ុនរបស់ខ្ញុំទាំងអស់មកមន្ទីរវប្បធម៌របស់នាង ចាប់ពីពេលដែលនាងបើកមន្ទីរវប្បធម៌ទៅ ។ ខ្ញុំនឹងទៅជាអ្នកបង្រៀនភាសាផង ពីវប្បធម៌ផង ហើយបើរតន៍នារីមិនយល់ទាស់ទេ សូមអនុញ្ញាតឱ្យខ្ញុំនៅជិតនាងរហូតដល់ខ្ញុំក្ស័យជីវិតផង ។

រតន៍នារីសើចចេញធ្មេញយ៉ាងស្រស់ ។ ជាលើកទីមួយហើយ តាំងពីខ្ញុំស្គាល់នាងមក ។ ព្រោះថា របាំក្បាច់បុរាណខ្មែរមិនអនុញ្ញាតឱ្យតួរបាំ សើចបញ្ចេញធ្មេញឡើយ ។ ទេពអប្សរតោងតែញញឹមតូច ជានិមិត្តរូបនៃនារីក្រមុំព្រហ្មចារី ។ ពេលគឺនាងមានសុភមង្គលក្នុងចិត្តលើសពីពេលណាទាំងអស់ តាំងពីនាងបានកើតជាមនុស្សមក ។ ខ្ញុំក៏បានសើចតបទៅនាងវិញ ដោយខ្ញុំក៏បានគិតដែរថា ខ្ញុំជាមនុស្សដែលមានភ័ព្វវាសនាលើសមនុស្សណាៗទាំងអស់នៅក្នុងលោកនេះ ។

យើងទាំងពីរសើចពីជម្រៅបេះដូងរបស់យើង ជាមនុស្សដើម្បីទទួលយកសុភមង្គលថ្មីមួយដែលនឹងចូលមកហើយ និងដើម្បីជម្នះលើសេចក្តីលំបាកនានាដែលនឹងអាចកើតមានឡើងដែរ ដោយកម្លាំងរបស់យើងទាំងពីរនាក់ ។

**ចប់**